ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩**

**សវនាការលើកទី៧៤**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CATWRIGHT)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក លឹម ស៊ុយហុង

កញ្ញា ណាតាសា វិីស៊ែល រីសឺ

*(Ms. Natacha WEXELS-RISER)*

លោក ម៉ាតេអូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីលៀម ស្មីត *(Mr.William SMITH)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

លោក ចាន់ រ៉ាវុធ

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ុនណា

លោក គង់ ពិសី

កញ្ញា ម៉ុច សុវណ្ណារី

លោក ហុង គឹមសួន

លោក ការីម ខាន (Mr. Karim KHAN)

លោកស្រី ស៊ីលឃិ ស្ទុតហ្ស៊ីនស្គី

*(Ms. Silke STUDZINSKY)*

លោកស្រី ម៉ាទីន ហ្សាកកាំង

*(Ms. Martine JACQUIN)*

លោក ហ្វីលីព កាណុន

*(Mr. Philippe CANNONE)*

លោក ព្យែរ អូលីវីយេ សួរ

*(Mr.Pierre- Olivier SUR)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ជា លាង | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០១:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ស្តាប់សេចក្តីថ្លែងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគី។

ក្រឡាបញ្ជី សែ កុលវុឌ្ឍី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី ដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន, ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់ឈើរាងវង់ក្រចកសេះ ដែលរៀបចំសម្រាប់ជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះ។

ជាកិច្ចបន្តអង្គជំនុំជម្រះសូមអញ្ជើញសហព្រះរាជអាជ្ញាឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហើយអង្គជំនុំជម្រះសូមជម្រាបសហព្រះរាជអាជ្ញាថា សហព្រះរាជអាជ្ញាមានពេលវេលាប្រាំម៉ោង គឺស្មើនឹងមួយថ្ងៃ គឺថ្ងៃនេះ ក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់បញ្ចប់កិច្ចពិភាក្សាដេញដោល។ សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការទាំងមូល។ សហព្រះរាជអាជ្ញានឹងធ្វើការបែងចែកសេចក្តីសន្និដ្ឋាននេះជាពីរផ្នែក គឺផ្នែកទីមួយ ខ្ញុំនឹងលើកឡើង ហើយផ្នែកទីពីរ គឺលោក វីលៀម ស្មីត នឹងលើកបន្ទាប់។ ដូចកាលពីម្សិលមិញ លោក លោកស្រីចៅក្រមបានស្តាប់ឮនូវសំឡេងរបស់ជនរងគ្រោះជាថ្មីម្តងទៀត នៅក្នុងសំណុំរឿងនេះ តាមរយៈមេធាវីរបស់ពួកគាត់ដែលបានរំឭកឡើងវិញអំពីការឈឺចាប់ និងផងប៉ះពាល់ដែលមានមិនចេះចប់នៃសកម្មភាពរបស់ជនជាប់ចោទទៅលើក្រុមគ្រួសារ

និងមិត្តភក្តិរបស់ពួកគាត់ដែលទទួលរងនូវការធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរស-២១។

[០៩:០៤:៣៥]

ដោយបានស្តាប់ឮនូវការបាត់បង់ដ៏គួរឲ្យរន្ធត់របស់ពួកគាត់ យើងអាចមានអារម្មណ៍ហាក់ដូចជាមានកាំបិតមួយស្ថិតនៅក្នុងខ្លួនរបស់គាត់ ដែលកាំបិតនោះបន្តរុកផ្កៀលនៅក្នុងខ្លួនរបស់ពួកគាត់គ្រប់ៗគ្នាពេញមួយជីវិតរស់នៅរបស់ពួកគាត់ ដែលបេះដូងដ៏ឈឺចាប់នេះមិនអាចនឹងស្ងប់បានឡើយ។

ក្នុងនាមសហព្រះរាជអាជ្ញា ត្រូវមានភារកិច្ចតំណាងឲ្យជនរងគ្រោះទាំងអស់នេះ ជនរងគ្រោះជាងមួយម៉ឺនពីរពាន់នាក់ផ្សេងទៀត ក្រុមគ្រួសាររបស់ពួកគាត់ មិត្តភក្តិរបស់ពួកគាត់សាធារណជនកម្ពុជា និងសាធារណជនពិភពលោកទាំងមូល។ ការទទួលខុសត្រូវរបស់យើង គឺធ្វើតំណាងឲ្យអត្ថប្រយោជន៍របស់ជនរងគ្រោះនិងរបស់សាធារណជនទូទៅឲ្យបាន និងប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ដោយមានការគោរពយ៉ាងពេញលេញនៃសិទ្ធិរបស់ជនជាប់ចោទ។ យើងមិនមែនត្រូវបានជំរុញទឹកចិត្តឲ្យមានការអំពាវនាវឲ្យមានការសងសឹក ឬការអត់ឱន និងការបំភ្លេចចោលនោះទេ។ តួនាទីរបស់យើងគឺជាតួនាទីតាមផ្លូវច្បាប់ ដើម្បីបញ្ជាក់អះអាងអំពីអង្គហេតុនានាឲ្យហួសពីវិមតិសង្ស័យ ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបន្ទាប់ពីនោះមក គឺដើម្បីសុំឲ្យអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវស្តីពីការកាត់ទោសឲ្យជាប់ទោស ដោយឈរលើបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌។

អង្គសវនាការជាទីគោរព, នៅទូទាំងដំណើរការនៃសវនាការនេះ លោក លោកស្រីចៅក្រមបានស្តាប់ឮអំពីរបៀបដែលមនុស្សប្រុសស្រី និងកុមារជាងមួយម៉ឺនពីរពាន់នាក់ ត្រូវបានគេធ្វើទារុណកម្ម និងសម្លាប់ជាប្រព័ន្ធនៅគុករបស់ខ្មែរក្រហម ដែលគេស្គាល់ថាមន្ទីរស-២១។ ជនរងគ្រោះទាំងនេះត្រូវបានគេចាប់ខ្លួនពីកន្លែងផ្សេងៗគ្នានៃប្រទេសកម្ពុជាទាំងមូល ដោយសារតែពួកគេត្រូវបានចាត់ទុកថា ជាខ្មាំងនៃខ្មែរក្រហម ពួកគេត្រូវបានគេនាំខ្លួនដោយដាក់ច្រវាក់មកកាន់ភ្នំពេញ បានដាក់នៅក្នុងឃុំឃាំងក្នុងលក្ខខណ្ឌដ៏គួរឲ្យរន្ធត់ដោយគ្មានអាហារ អនាម័យ ការថែទាំសុខភាពគ្រប់គ្រាន់ទេ។ ពួកគាត់ស្ទើរតែទាំងអស់ត្រូវបានដាក់ឲ្យនៅក្រោមកម្មវត្ថុនៃការជ្រើសរើសមួយនៃការធ្វើបាប ដែលរួមមានការគំរាមកំហែង ការបំភិតបំភ័យ ការវាយដំ ការឆក់នឹងខ្សែភ្លើង ការជ្រមុជឲ្យឈ្លក់ទឹក ការបូមឈាមដោយបង្ខំការធ្វើពិសោធផ្នែកពេទ្យ ការបង្ខំឲ្យស៊ីអាចម៍មនុស្ស និងអំពើឃោរឃៅយង់ឃ្នង់មិនអាចនិយាយរួចដទៃទៀត។ ជាចុងក្រោយពួកគេទាំងអស់ត្រូវបានគេបញ្ជូនដោយបង្ខំទៅកាន់អំពើដ៏គគ្រក់ជាចុងក្រោយបង្អស់ គឺការស្លាប់ដ៏អនាមិកនៅក្នុងភាពងងឹតនៃវាលពិឃាដនៃជើងឯក ដោយពួកគាត់ត្រូវបានគេស្រោត

សម្លៀកបំពាក់ចេញអស់ មុននឹងសាកសពត្រូវបានគេទាត់ទម្លាក់ចូលទៅក្នុងរណ្ដៅកប់សពរួម។

[០៩:០៨:០៥]

ជនរងគ្រោះភាគច្រើនបំផុតគឺជាប្រជាជនកម្ពុជាដែលត្រូវបានសម្លាប់ដោយកម្ពុជាគ្នាឯង ប្រសិនបើជនរងគ្រោះទាំងអស់នោះ នៅរស់រានជីវិតដល់សព្វថ្ងៃម្ល៉េះសមបន្ទប់សវនាការនេះ ត្រូវបានបំពេញទៅដោយជនរងគ្រោះនៃមន្ទីរស-២១ របស់ខ្មែរក្រហមច្រើនជាងនេះដល់ទៅជាងម្ភៃប្អូនដងឯណោះ។

នៅចន្លោះពីខែសីហា ឆ្នាំ១៩៧៥ ដល់ដើមឆ្នាំខែមករា ឆ្នាំ១៩៧៩ ជនជាប់ចោទពីដំបូងជាអនុប្រធាន និងបន្ទាប់មកជាប្រធានមន្ទីរស-២១ សម្រាប់រយៈពេល៤១ខែនៃប្រតិបត្តិការទាំងមូលរបស់ខ្លួន។ តាមន័យជាទូទៅ គាត់បានសារភាព អំពីការទទួលខុសត្រូវជាទូទៅរបស់គាត់ចំពោះបទឧក្រិដ្ឋទាំងនេះ ក៏បានចូលរួមជាសហការជាបុគ្គលជាមួយអង្គជំនុំជម្រះនៅទូទាំងកិច្ចដំណើរការនីតិវិធី គាត់បានសម្ដែងនូវវិប្បដិសារី និងការគោរពចំពោះជនរងគ្រោះផងដែរ ។ ប៉ុន្តែការសារភាពរបស់ជនជាប់ចោទ គ្រាន់តែជាផ្នែកមួយអាចជឿបាន ប៉ុន្តែមួយផ្នែកទៀតជនជាប់ចោទនៅតែបដិសេធដូចដែលមេធាវីតំណាងដោយដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងកាលម្សិលមិញហើយ ទោះបីមានភ័ស្តុតាងបង្ហាញក៏ដោយ។

គាត់បានហៅសាក្សីជំនាញខាងអត្តចរិតមកនិយាយ អំពីជីវិតរបស់គាត់តាំងពីមុន និងក្រោយពេលការចូលរួមរបស់គាត់ជាមួយបក្សកុម្មុយនីស្តកម្ពុជាឬយើងហៅថាប.ក.ក ប៉ុន្តែឧក្រិដ្ឋកម្មដែលគាត់កំពុងតែទទួលរងការកាត់ឲ្យជាប់ទោសនេះ គឺជាបទឧក្រិដ្ឋដែលមានសភាពធ្ងន់ធ្ងរជាទីបំផុត និងដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងមនុស្សយ៉ាងច្រើន ដែលធ្វើឲ្យគេយល់បានយ៉ាងសាមញ្ញថាគ្មានអ្វីអាចនឹងជំនួសបានឡើយក្រៅអំពីការកាត់ទោសរូបគាត់ឲ្យជាប់ក្នុងពន្ធនាគារក្នុងរយៈពេលដ៏យូរមួយនេះទេ។

របបដែលអង្គជំនុំជម្រះបានកំណត់ដើម្បីធ្វើការពិនិត្យនេះ ត្រូវបានគេស្គាល់ថា ជារបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែវានៅដាច់ឆ្ងាយណាស់ពីប្រជាធិបតេយ្យ ក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ដែលក្នុងសម័យកាលនេះប្រទេសទាំងមូល ត្រូវបានហែកដាច់ជំរៀកៗ ហើយជនស៊ីវិលជាងមួយលានប្រាំពីរសែននាក់ត្រូវបានសម្លាប់យ៉ាងរង្គាល។

តុលាការនេះមិនមានវិសាលធ្វើការពិនិត្យឲ្យបានពិស្ដារ អំពីហេតុអ្វីបានជាទីក្រុងនានាត្រូវបានគេជម្លៀស? ហេតុអ្វីបានជាប្រជាជនត្រូវគេបង្ខំឲ្យធ្វើការតាមសហករណ៍ដ៏ធំល្វឹងល្វើយនៅតាមជនបទនានា? ហេតុអ្វីក្រុមគ្រួសារត្រូវបានគេបំបែក? ហេតុអ្វី និងរបៀបណាបានជាប្រជាជនបានស្លាប់ក្នុងចំនួនយ៉ាងច្រើនដោយការអត់អាហារ ជំងឺ និងការងារច្រើនហួសកំណត់ទេ? ប៉ុន្តែ សវនាការនេះបាន

ផ្តោតទៅលើតែទិដ្ឋភាពនៃរបបនៃតែប៉ុណ្ណោះ គឺការពង្រឹងការអនុវត្តមនោគមវិជ្ជាដាច់ខាតពាក់ព័ន្ធនឹងអំពើហិង្សានយោបាយគ្មានក្តីមេត្តា ស្រដៀងនឹងរបបជ្រុលនិយមដទៃទៀតដែរ ដូចជារបបផ្តាច់ការរបស់ស្តាលីននៃប្រទេសរុស្ស៊ី និងណាហ្ស៊ីរបស់អាល្លឺម៉ង់ ចំណុចដៅនៃអំពើហិង្សានេះ គឺជនទាំងឡាយណាដែលមិនសម្របខ្លួនតាម ឬក៏មិនចំណុះ ហើយក៏ស្រដៀងគ្នានឹង N.K.V.D របស់ស្តាលីន របស់អ៊ីត្លែរដែរ គឺថានគរបាលសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ឬដែលគេហៅថា សន្តិបាល នោះបានប្រដេញតាមរកយ៉ាងប្រកិតដោយគ្មានក្តីមេត្តា នូវជនណាដែលគេចាត់ទុកថា ជាខ្មាំងនៃរបបនេះ។ តាមភាសាបដិវត្តន៍របស់កម្ពុជាប្រជាធិបតេយ្យបក្ស កុម្មុយនីស្តកម្ពុជាបានប្រើពាក្យថា "កម្ទេច" ដើម្បីពិពណ៌នាអំពីសកម្មភាពជាក់ស្តែងនៃការសម្លាប់ជនណាម្នាក់ ដែលគេសង្ស័យថា ជាខ្មាំង។

[០៩:១២:២៨]

ពាក្យសម្រាប់សម្តែងមនោសញ្ចេតនាបែបបហិង្សាមួយឃ្លាខ្លីដ៏ពិសេសនេះ ចង្អុលប្រាប់យើងថា វាមិនមែនមានន័យសាមញ្ញត្រឹមតែថា ជនណាម្នាក់នឹងត្រូវបានគេសម្លាប់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានន័យដែរថា កម្ទេចឲ្យទៅចំណិតតូចៗ ធ្វើឲ្យបាត់ដាន បំបាត់ឲ្យផុតពីភពផែនដី។ អំពើឃោរឃៅដ៏ធំមហិមានេះបានសម្រេចរួចហើយនូវអំពើឃោរឃៅ ដែលធ្លាក់បានកើតឡើងនៅក្នុងពេលដទៃទៀតក្នុងប្រវត្តិ-សាស្ត្រដែរ តាមរយៈការធ្វើឲ្យបាត់បង់ជាប្រព័ន្ធនូវភាពជាមនុស្ស និងតាមរយៈការបំពាក់បំប៉នមនោ-គមវិជ្ជាយ៉ាងទូលំទូលាយរបស់ជនល្មើស។

សវនាការនេះ ផ្តោតលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងគុកមួយតែប៉ុណ្ណោះ គឺមន្ទីរសន្តិ-សុខនៃសន្តិបាលស-២១ ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ ប៉ុន្តែស-២១ មិនមែនជាគុកធម្មតាឡើយ វាជាគុកនយោបាយគំរូរបស់កម្ពុជាប្រជាធិបតេយ្យ។ វាជាឧបករណ៍សំខាន់បំផុតដែលបានបង្កើតឡើងដោយគណៈកម្មធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា សម្រាប់កំណត់អត្តសញ្ញាណខ្មាំងនៃរបបនេះ ធ្វើការឃុំខ្លួនពួកគេស្រង់យកចម្លើយសារភាព តាមរយៈការធ្វើទារុណកម្ម ហើយបន្ទាប់មកសម្លាប់ពួកគេចោលនៅពេលដែលព័ត៌មានបានទទួលបានគ្រប់គ្រាន់ហើយ

សវនាការនេះ ផ្តោតទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់មនុស្សតែម្នាក់គត់គឺ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយបានជ្រើសរើសដោយបក្សកុម្មុយនីស្តកម្ពុជា ធ្វើជាអនុប្រធាន និងបន្ទាប់មកជាប្រធានគុកនេះ។ ជនជាប់ចោទបានប្តេជ្ញាចិត្តចំពោះមនោគមវិជ្ជាកុម្មុយនីស្ត ស្មោះស្ម័គ្រចំពោះមេដឹកនាំ និងបានទទួការបណ្តុះបណ្តាលយ៉ាងល្អប្រសើរួចជាស្រេចនៅក្នុងការងារសន្តិសុខ ដោយសារតែគាត់

ធ្លាប់បានចាត់ចែងគុកមួយស្រដៀងគ្នានេះដែរកាលពីមុន មុនពេលដែលខ្មែរក្រហមឡើងកាន់អំណាច។ គាត់ជាមនុស្សជាទីទុកចិត្តរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងការកំណត់អត្តសញ្ញាណអំពីគម្រោងការអាក្រក់នានាប្រឆាំងនឹងបដិវត្តន៍ ក្នុងការជជីកឈ្លេចរកជនណាដែលត្រូវបានគេចាត់ទុកថាជាជនក្បត់ ឬខ្មាំង។ គាត់ជាតួអង្គគំរូឥតខ្ចោះ ល្អឥតខ្ចោះ នៃប្រសិទ្ធផលដ៏គ្មានមេត្តា។ គាត់ជាមនុស្សមិនចេះអើពើនឹងការឈឺចាប់របស់ជនរងគ្រោះឡើយ។ គាត់ជាបេក្ខជនឥតខ្ចោះសម្រាប់ការចាត់ចែងមន្ទីរស-២១។

[០៩:១៥:០៧]

នៅទូទាំងដំណើរការសវនាការ ទាំងមូល លោកប្រធាន លោក លោកស្រីចៅក្រម បានធ្វើដំណើរការឆ្លងកាត់ក្នុងចម្ងាយមួយយ៉ាងវែងក្នុងការផ្តល់កាលានុវត្តភាពគ្រប់បែបយ៉ាងនាំឲ្យជនជាប់ចោទបានលើកឡើងអំពីសាក្សី និងភ័ស្តុតាងនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

ជនជាប់ចោទរូបនេះ តែងទទួលបាននូវការប្រព្រឹត្តិមកលើខ្លួនយ៉ាងត្រឹមត្រូវក្នុងសេចក្តីថ្លៃថ្នូរនៅក្នុងភាពជាមនុស្ស។ គ្មានមន្ទិលសង្ស័យទេដែលថា មេធាវីការពារក្តីរបស់គាត់បានទទួលស្គាល់នូវទម្ងន់នៃភស្តុតាងប្រឆាំងនឹងកូនក្តីរបស់ខ្លួន។ គ្មានមន្ទិលសង្ស័យទេ និងពិតជាការត្រឹមត្រូវណាស់ដែលថា មេធាវីការពារក្តីរបស់គាត់បានផ្តល់យោបល់ឲ្យគាត់ទទួលយកការសារភាពពេញលេញចំពោះឧក្រិដ្ឋដែលមានលក្ខណៈធ្ងន់ធ្ងរយ៉ាងដូច្នេះ ពាក់ព័ន្ធដល់ការឈឺចាប់ជនរងគ្រោះច្រើននាក់ និងដែលធ្វើឲ្យ រន្ធត់ដ៏ជ្រាលជ្រៅដូច្នេះ ចំពោះមនសិការ ការឆ្លើយតបតែមួយគត់ គឺអាចជាការកាត់ទោសរយៈពេលវែងមួយ។

វាមិនចាំបាច់ថាជននោះជាអ្នកមានមុខនាទីខ្ពស់ វាមិនចាំបាច់ថា ទាល់តែមានជនណាម្នាក់ស្ថិតនៅក្នុងរបបនោះ អាចថានឹងមានការទទួលខុសត្រូវដែលបានប្រព្រឹត្តឡើង សូម្បីតែក្នុងទំហំមួយធំជាងក៏ដោយ។ វាមិនចាំបាច់ ទោះជាគ្មានជនដទៃណាផ្សេងមកទទួលសារភាពពីទោសកំហុសរបស់ខ្លួន ឬជនខកខានមិនបានសហការជាមួយអជ្ញាធរក៏ដោយ។ យុត្តិធម៌ទាមទារនូវពេលថា នៅពេលណា កម្រិតនៃស្ថានភាពធ្ងន់ធ្ងរបានធ្វើរួចហើយ នោះទណ្ឌកម្មជាចុងក្រោយបំផុត ត្រូវតែបានធ្វើឡើងចំពោះបទឧក្រិដ្ឋដែលបានធ្វើឲ្យរង្គោះរង្គើដល់មូលដ្ឋានគ្រឹះសង្គម។

លោក លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព, នៅក្នុងករណីនេះ លោកប្រធាន លោក លោកស្រីបានឮរួចហើយអំពីភស្តុតាងនៃបទឧក្រិដ្ឋទាំងនេះ។ នៅក្នុងសេចក្តីសន្និដ្ឋានបិទសវនា-ការរបស់យើងនាថ្ងៃនេះត្រូវបានធ្វើឡើងទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន៩៤(ខ) នៃវិធានផ្ទៃក្នុងក្នុងការ

សម្រាប់ អ.វ.ត.ក ដែលចែងថា អង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដើម្បីធ្វើការសន្និដ្ឋានប្ដឹងសុំដោយផ្ទាល់មាត់ ដែលខ្លួនយល់ឃើញថា សមស្របនឹងផលប្រយោជន៍នៃយុត្តិធម៌។

ដូច្នេះ ដើម្បីស្វែងរកយុត្តិធម៌ យើងខ្ញុំនឹងប្រើប្រាស់ពេលវេលាប្រាំម៉ោង ដែលលោកប្រធានអង្គជំនុំជម្រះបានផ្ដល់ឲ្យយើងខ្ញុំ។ ទោះជាយ៉ាងនេះក្ដី ដោយចងចាំក្នុងចិត្តនូវវិធាននេះ និងអំពីការពិតដែលថាមេធាវីការពារក្ដី ត្រូវបានផ្ដល់រយៈពេលរហូតដល់ប្រាំពីរម៉ោងសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានរបស់គេ ប្រសិនបើចាំបាច់ យើងខ្ញុំនឹងស្នើសុំការអនុញ្ញាតពេលវេលាបន្ថែមបន្តិចបន្តួចទៀត។

ក្នុងនាមសហព្រះរាជអាជ្ញានៃតុលាការនេះ ខ្ញុំនឹងសហការីរបស់ខ្ញុំលោក វីលៀម ស្មីត នឹងចង្អុលបង្ហាញនៅក្នុងសេចក្ដីសន្និដ្ឋានចុងក្រោយរបស់យើងខ្ញុំ នូវចំណុចសំខាន់ៗចំនួនបួន ដែលយើងខ្ញុំសូមជម្រាបថា គួរតែត្រូវបានយកមកពិនិត្យឲ្យបានពេញលេញក្នុងសាលក្រមរបស់លោក។

ទីមួយ មូលដ្ឋានគ្រឹះនៃយុត្តាធិការ មូលដ្ឋានគ្រឹះនៃច្បាប់នៃអង្គជំនុំជម្រះនេះ មានក្នុងការវិនិច្ឆ័យទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

ទីពីរ ភ័ស្ដុតាងដែលបានគាំទ្រឧក្រិដ្ឋកម្មទាំងនេះ និងរបៀបដែលភស្ដុតាងទាំងនេះគួរតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ ជាបទឧក្រិដ្ឋដែលបានចែងនៅក្នុងច្បាប់។

ទីបី ភ័ស្ដុតាងអំពីតួនាទីជាក់ស្ដែង ដែលបានធ្វើឡើងដោយជនជាប់ចោទ និងចេតនាដែលគាត់មាននៅពេលប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ និងរបៀបដែលភស្ដុតាងនេះគួរមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ ទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់នៅក្រោមច្បាប់។

និងចំណុចចុងក្រោយជាចំណុចទីបួន កត្តានានាដែលយើងខ្ញុំបានដាក់ គួរតែត្រូវបានយកទៅពិចារណាក្នុងការកំណត់សម្រេចអំពីការទោសរបស់លោក លោកស្រីចៅក្រម។

ដូចលោកប្រធានជ្រាបស្រាប់ហើយ ប៉ុន្ដែសាធារណជនមិនទាន់បានដឹងនៅឡើយ យើងខ្ញុំបានដាក់ជូនកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ នូវសេចក្ដីសន្និដ្ឋានបញ្ចប់សវនាការដេញដោលរបស់យើងទាំងសេចក្ដីសន្និដ្ឋានសម្ងាត់ និងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលបានលុបចេញនូវផ្នែកខ្លះទាំងភាសាខ្មែរ អង់គ្លេស បារាំង ជាមួយនឹងដីមបណ្ដឹងរដ្ឋប្បវេណីដទៃទៀត និងមេធាវីការពារក្ដី។

សេចក្ដីសន្និដ្ឋានបញ្ចប់សវនាការជាលាយលក្ខណ៍អក្សរនេះមានចំនួនតិចជាង១៦០ទំព័រ។ កំណត់សម្គាល់ចុងទំព័រមួយពាន់ និងប្រភពច្បាប់យោងពីររយដែលយើងបាន សង្ឃឹមថានឹងជួយដល់លោកលោកស្រីចៅក្រមកាន់តែច្បាស់លាស់ជាក់ស្ដែងក្នុងការកំណត់សាលក្រមកាត់ទោសរបស់លោក លោក

ស្រីចៅក្រម។

[០៩:២១:២១]

អាស្រ័យហេតុនេះសេចក្តីសន្និដ្ឋានរបស់យើងថ្ងៃនេះ គួរតែត្រូវបានមើលឃើញថា ជាសេចក្តីសន្និដ្ឋានបន្ថែមបង្គ្រប់ទៅលើសេចក្តីសន្និដ្ឋានដែលបានដាក់រួចហើយ។ តាមរយៈការបញ្ជាក់ឡើងវិញពីបញ្ហានានា តាមមធ្យោបាយដែលយើងសង្ឃឹមថា នឹងជួយផ្តល់ការយល់ដឹងបន្ថែមអំពីគោលជំហររបស់យើងខ្ញុំនៅក្នុងករណីនេះ។

ពេលវេលានឹងមិនអនុញ្ញាតឲ្យយើងខ្ញុំអាចដកស្រង់គ្រប់ទំព័រនៃឯកសារដែលយើងបានគាំទ្រចំពោះសេចក្តីសន្និដ្ឋានរបស់យើងនាថ្ងៃនេះទេ ប៉ុន្តែលោក លោកស្រីចៅក្រម អាចស្វែងរកសេចក្តីយោងទាំងអស់នោះនៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។ ហេតុដូចនេះសេចក្តីសន្និដ្ឋានបិទសវនាការនេះ គឺគ្រាន់តែជាសេចក្តីសង្ខេបយ៉ាងខ្លីនៃសាច់រឿងទាំងឡាយរបស់ជនរងគ្រោះ និងសាក្សីដែលលោក លោកស្រីចៅក្រមបានស្តាប់រួច ឮរួចហើយ នឹងដែលមាននៅក្នុងឯកសារនានាដែលលោក លោកស្រីបានអានរួចហើយដែរ។

ជាអកុសល ចំពោះមេធាវីការពារក្តី ក្រៅអំពីការដាក់សារណាដ៏ខ្លីដែលមានតែចំនួនដប់ប្រាំមួយទំព័រ ដោយលើកឡើងអំពីអង្គហេតុខ្លះៗ គេមិនបានចាប់យកកាលានុវត្តភាព នេះដើម្បីផ្តល់ជាមុននូវមូលដ្ឋានគ្រឹះនៃភស្តុតាង អំពីការសុំបន្ធូរបន្ថយទោសរបស់ខ្លួនឡើយ។

ហេតុដូច្នេះ ការនេះបានត្រឹមតែអនុញ្ញាតឲ្យយើងខ្ញុំនិងដើមបណ្តឹងរដ្ឋប្បវេណី ឆ្លើយតបដោយផ្ទាល់ទៅនឹងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ពួកគេប៉ុណ្ណោះនៅក្នុងសេចក្តីបដិសេធរបស់យើង។ ការធ្វើដូច្នេះ គឺដោយសារយើងបានព្យាយាមដើម្បីលើកឡើងចំពោះបញ្ហានានាដែលបាន យើងជឿថាមេធាវីការពារក្តីអាចនឹងលើកជាមុន។

សវនាការជំនុំជម្រះក្នុងករណីព្រហ្មទណ្ឌដូចសវនាការមួយនេះ ដែលកំណត់វិសាលភាពត្រឹមតែទីតាំងនៃបទឧក្រិដ្ឋតែមួយ និងមនុស្សតែម្នាក់ និងមិនផ្តល់ជូននូវចម្លើយទាំងអស់សម្រាប់អ្វីៗគ្រប់បែបយ៉ាងដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យបានទេ។ ប៉ុន្តែ យើងសង្ឃឹមថា សវនាការនេះ នឹងបង្ហាញឲ្យឃើញថាយុត្តិធម៌ និងគណនេយ្យភាព គឺជាការឆ្លើយតបដ៏មានសារសំខាន់បំផុតសម្រាប់ឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងនេះ។

អំពីយុត្តាធិការ ឥឡូវនេះសូមក្រឡេកមើលភស្តុតាងនានា អំពីការបង្កើតមូលដ្ឋានយុត្តាធិការនៃ

អង្គជំនុំជម្រះនេះ សម្រាប់វិនិច្ឆ័យទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ យុត្តាធិការរបស់លោក លោកស្រីទៅលើជនជាប់ចោទរូបនេះ ការចេញពីច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ច្បាប់នេះផ្តល់អំណាចឲ្យលោក លោកស្រីធ្វើការវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មជាក់លាក់ដែលបានប្រព្រឹត្តនៅក្នុងកំឡុងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ឧក្រិដ្ឋកម្មទាំងនេះរួមមានទាំងការរំលោភច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ។

[០៩:២៤:៥៤]

រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលមានសមាសភាពតាមការស្មានសៃសភាតំណាងប្រជាជនតាមការបោះឆ្នោតតាមបែបប្រជាធិបតេយ្យនោះ គ្រាន់តែជាការបោកបញ្ឆោតតែប៉ុណ្ណោះ អំណាចពិតប្រាកដស្ថិតនៅក្នុងដៃរបស់បក្សកុម្មុយនិស្តកម្ពុជាដែលហៅថា ប.ក.ក ឬជួនកាលគ្រាន់តែហៅយ៉ាងសាមញ្ញថាបក្ស។ នៅក្នុងបក្សអង្គការដ៏មានអំណាចបំផុត គឺគណៈកម្មាធិការអចិន្ត្រៃយ៍ដែលជាអ្នកកំណត់អំពីគោលនយោបាយនៃរបបនេះ។

ទោះជាយ៉ាងនេះក្តី ប្រជាជនត្រូវបានគេលើកទឹកចិត្តឲ្យប្រើពាក្យថា“អង្គការ” កាលណានិយាយសំដៅទៅដល់កម្លាំងណែនាំរបស់ប្រទេស ជាពាក្យអនាមិក មិនបាច់ច្រឡំជាមួយដែលរួមទាំងចំណែកដែលបរិយាកាសជារួមនៃការរក្សារការសម្ងាត់អវត្តមាននៃគណនេយ្យភាព និងកង្វះខាតនៃលទ្ធិប្រជាធិបតេយ្យពិតប្រាកដ។ មិនមានការណែនាំជាក់លាក់ អ.វ.ត.ក តាមរយៈច្បាប់ជាធរមាន ថាតើនរណាអាចត្រូវបានពិចារណាជាមេដឹកនាំជាន់ខ្ពស់? អាស្រ័យហេតុនេះអង្គជំនុំជម្រះត្រូវបានអនុញ្ញាតឲ្យពិនិត្យទៅលើករណីយុត្តិសាស្ត្រអន្តរជាតិនៅតុលាការអតីតយូហ្គោស្លាវី មានទស្សនទានដែលស្រដៀងគ្នានៃពាក្យថា មេដឹកនាំខ្ពស់បំផុតដែលត្រូវបានសង្ស័យថាជាជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតត្រូវបានកំណត់និយមន័យដោយតុលាការនេះ ថាជាការតម្រូវឲ្យមានការពិនិត្យទៅលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ និងកម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ។

នៅពេលធ្វើការវិភាគអំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ តុលាការ *អាយស៊ីធីវ៉ាយ* បានគូសបញ្ជាក់អំពីកត្តាមួយចំនួនមានដូចជា វិសាលភាពពេលវេលា វិសាលភាពភូមិសាស្ត្រ ចំនួនជនរងគ្រោះដែលរងការប៉ះពាល់ ចំនួនឧប្បត្តិហេតុដាច់ដោយឡែកៗ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងលក្ខណៈនៃអំពើព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តឡើង។

[០៩:២៦:៥៧]

សម្រាប់ការវិភាគអំពីកម្រិតនៃការទទួលខុសត្រូវ តុលាការបានពិចារណាថា មេដឹកនាំជាន់ខ្ពស់ មិនកំហិតត្រឹមតែមេដឹកនាំនៃគោលនយោបាយទេ។ ផ្ទុយទៅវិញ តុលាការត្រូវពិនិត្យទៅលើកត្តាមួយចំនួនដូចជា និច្ចកាលនៃមុខនាទី វិសាលភាពពេលវេលា ចំនួននៃអ្នកនៅក្រោមបង្គាប់ ឋានន្តរសក្តិរបស់ជនជាប់ចោទ នៅក្នុងក្នុងរចនាសម្ព័ន្ធឋានានុក្រម និងតួនាទីព្រហ្មទណ្ឌជាក់ស្តែងរបស់ជនជាប់ចោទ។

សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ជនជាប់ចោទស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ថាជាជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត។ ចំពោះបទឧក្រិដ្ឋដែលបានការគិតគូអំពីសិទ្ធិអំណាចតាមឋានានុក្រមដ៏មានប្រសិទ្ធភាព និងជាផ្លូវការរបស់ រួមទាំងការចូលរួមជាបុគ្គលរបស់គាត់ផង។ ក្នុងនាមជាអនុលេខា និងបន្ទាប់មកជាលេខាមន្ទីរស-២១ ដែលបានគ្រប់គ្រងដោយផ្ទាល់ពីគណៈកម្មាធិការកណ្តាល។

សហព្រះរាជអាជ្ញា សូមអញ្ជើញអង្គជំនុំជម្រះអនុវត្តតាមគោលការណ៍ណែនាំដូចមាននៅក្នុងតុលាការយូហ្គោស្លាវី និងសូមឲ្យកំណត់ថា អ.វ.ត.ក មានយុត្តាធិការទៅលើបុគ្គលជនជាប់ចោទរូបនេះទាំងពីរ ទាំងជាមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត។

ជនជាប់ចោទ គឺជាប្រធានមន្ទីរស-២១ ជាមន្ទីរសន្តិសុខដ៏សំខាន់បំផុតនៅក្នុងកម្ពុជាប្រជាធិប-តេយ្យ នៅក្រោមសិទ្ធិអំណាចរបស់គាត់ បុគ្គលិកមន្ទីរស-២១ បានធ្វើទារុណកម្មជាប្រព័ន្ធទៅលើអ្នកទោសដើម្បីទាញយកចម្លើយសារភាព និងបានសម្លាប់ពួកគេចោល ក្រោយពេលចម្លើយសារភាពរបស់ពួកគេត្រូវបានបញ្ចប់។

ការចូលរួមរបស់គាត់ក្នុងបទឧក្រិដ្ឋនានានៅមន្ទីរស-២១ គឺមានលក្ខណៈទូលំទូលាយចាប់ពីការបង្កើត និងការបង្កើតគោលនយោបាយរបស់គុក រហូតដល់ការមើលខុសត្រូវ និងការចូលរួមក្នុងការសម្លាប់។ ទាក់ទិននឹងការទទួលខុសត្រូវរបស់គាត់ គាត់គឺជាលេខាអចិន្ត្រៃយ៍នៃស-២១ស្ទើរតែពេញមួយអាណត្តិក្នុងរយៈពេលបីឆ្នាំ គាត់បានធ្វើអន្តរសកម្មប្រចាំថ្ងៃជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់បានជ្រើសរើសមនុស្សរាប់ពាន់ ឲ្យចូលរួមបម្រើការងារជាអ្នកក្រោមបង្គាប់របស់គាត់ ហើយគាត់គឺជាអ្នកដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅមន្ទីរស-២១ ទៅតាមកម្រិតជាច្រើនខុសៗគ្នា។

ទាក់ទិននឹងភាពធ្ងន់ធ្ងរ ឧក្រិដ្ឋកម្មនៅមន្ទីរស-២១ មានបទឧក្រិដ្ឋខ្លះ គឺមានលក្ខណៈធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃយុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិ គឺថាការធ្វើទារុណកម្មជាប្រព័ន្ធ ការរំលោភសិទ្ធិ

ដ៏ធំធេង និងការសម្លាប់ដែលមានរយៈពេលជាងបីឆ្នាំ ដែលបានប្រព្រឹត្តទៅលើអ្នកទោសជាងមួយម៉ឺនពីរពាន់នាក់។

ទោះបីជាមេធាវីការពារក្ដីមិនបានស្វែងរក ដើម្បីតវ៉ាទៅនឹងសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលថា ជនជាប់ចោទត្រូវបានគេពិចារណាថា ស្ថិតនៅក្នុងប្រភេទនៃជនដែលទទួលខុសត្រូវខ្ពស់បំផុតក៏ដោយ ពួកគេបានឲ្យដឹងថា ជនជាប់ចោទត្រូវបានគេមួលបង្កាច់យ៉ាងអយុត្តិធម៌។ ពួកគេឲ្យដឹងថា មានប្រធានមន្ទីរសន្តិសុខ ឬក៏ប្រធានគុកជាច្រើននាក់ផ្សេងទៀតនៅទូទាំងប្រទេសដែលមានចំនួនជនរងគ្រោះច្រើនជាងនេះទៅទៀត ត្រូវបានគេសម្លាប់ដែលជាអ្នកអាច និងគួរនាំមករកយុត្តិធម៌។

សហព្រះរាជអាជ្ញាសូមទទូចដល់អង្គជំនុំជម្រះឲ្យបដិសេធចោលការអះអាងដែលថា ជនជាប់ចោទគឺជាជនដែលគេមួលបង្កាច់។ សូមកុំមានការភាន់ច្រឡំ មន្ទីរស-២១ គឺជាមន្ទីរសន្តិសុខកំពូលបំផុតនៃបណ្ដាញមន្ទីរសន្តិសុខនទូទាំងប្រទេសដែលបានប្រតិបត្តិការធ្វើជាគុកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ មន្ទីរស-២១ គឺជាគុកប្លែកយ៉ាងពិសេសខុសពីគេក្នុងចំណោមគុកទាំងអស់ និងដូចដែលយើងត្រូវលើកយកពិភាក្សាគ្នា គឺជាជនជាប់ចោទរូបនេះ មានសិទ្ធិ និងសម្ព័ន្ធភាពប្លែងយ៉ាងពិសេសខុសពីគេ ទៅនឹងមេដឹកនាំជាន់ខ្ពស់នៃរបបនេះ។

ភាពខុសគ្នាប្លែកពីគ្នាដ៏ពិសេសនៃមន្ទីរស-២១ ក៏ដោយសារតែមន្ទីរសន្តិសុខនេះទទួលអ្នកទោសពីគ្រប់ទិសទីនៅទូទាំងប្រទេសពីគ្រប់ក្រសួងនីមួយៗ គ្រប់អង្គភាពយោធានីមួយៗ និងពីគ្រប់អង្គភាពរដ្ឋបាលខេត្តនីមួយៗ។ មន្ទីរស-២១ ក៏មានភាពប្លែកខុសយ៉ាងពិសេសខុសពីគេផងដែរ ដោយសារជនរងគ្រោះ ត្រូវបានរាប់បញ្ចូលទាំងកម្មាភិបាលដែលមានឋានន្តរសក្តិខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា និងសូម្បីតែសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ក៏មាន។ ភាពប្លែកយ៉ាងពិសេសខុសគេនេះ ដោយជនជាប់ចោទធ្លាប់បានសារភាពរួចហើយថា មន្ទីរស-២១ បានឃុំខ្លួន បានធ្វើទារុណកម្ម និងបានសម្លាប់ប្រធានផ្នែកបោសសម្អាតនៃមន្ទីរសន្តិសុខ និងគុកផ្សេងមកពីកន្លែងផ្សេងៗគ្នានៅទូទាំងប្រទេស។

ប៉ុន្តែប្រហែលដោយសារឯកសារដែលជាចម្លើយសារភាពរបស់អ្នកទោសរាប់ម៉ឺនទំព័រ ដែលត្រូវបានធ្វើឡើងតាមរយៈការធ្វើទារុណកម្ម តាមសិទ្ធិអំណាចរបស់ជនជាប់ចោទរូបនេះ ដែលបង្ហាញអំពីសារសំខាន់ និងតម្លៃពិតប្រាកដរបស់មន្ទីរស-២១ ចំពោះរបបនេះ។

[០៩:៣២:៥៦]

ជនជាប់ចោទបានបញ្ជូនចម្លើយសារភាពពីមន្ទីរស-២១ ទៅមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្ត

កម្ពុជា តាមរយៈការវិភាគរបស់គាត់ទៅលើចម្លើយសារភាពទាំងនេះ គាត់ជាឧបករណ៍មួយជួយសម្រួលក្នុងការផ្តល់យោបល់ថា តើនរណាដែលត្រូវចាប់ខ្លួន។

សហព្រះរាជអាជ្ញាដឹងថា មានបណ្ណសារនៃចម្លើយសារភាពពីគុកណាផ្សេងអាចមាន អាចប្រៀបបានឡើយ។ វាមិនទំនងទាល់តែសោះដែលថា មានគុកណាមួយផ្សេង ឬប្រធានគុកណាមួយផ្សេងមានឥទ្ធិពលដូចគ្នាទៅលើយុទ្ធនាការរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងការកម្ទេចជនដែលគេសន្មតថាជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ដូច្នេះជាការត្រឹមត្រូវដែលជនជាប់ចោទរូបនេះ នៅចំពោះមុខអង្គជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩។

**អំពីបទឧក្រិដ្ឋ**

ឥឡូវ សូមក្រឡេកមើលទៅលើបទឧក្រិដ្ឋ ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះវិញម្តង និងភ័ស្តុតាងដែលគាំទ្រហួសពីវិមតិសង្ស័យចំពោះបទឧក្រិដ្ឋទាំងនោះ។ មុននឹងចូលទៅដល់ចំណុចនេះ ខ្ញុំសូមលើកអំពីបញ្ហានៃអង្គហេតុដែលបានព្រមព្រៀងគ្នារួចហើយនៅក្នុងករណីនេះ។

ពីដំបូងនៃសវនាការសហព្រះរាជអាជ្ញាបានអានបញ្ជីអង្គហេតុដែលបានឯកភាព ឬដែលមិនមានការតវ៉ាពីជនជាប់ចោទ។ អង្គហេតុដែលបានឯកភាពគ្នាទាំងនេះ ពិតជាជំនួសដល់អង្គជំនុំជម្រះនៅក្នុងការកំណត់សម្រេចថា តើបញ្ហាណាខ្លះមិនទាន់បានដោះស្រាយ? ប៉ុន្តែវាមិនបានដកហូតនូវកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ជាក់ភ័ស្តុតាងហួសពីវិមតិសង្ស័យពីករណីនេះប្រឆាំងនឹងជនជាប់ចោទនោះទេ។

អ្វីដែលគួរឱ្យកត់សម្គាល់ នៅពេលករណីនេះមានការរីកចម្រើនទៅមុខ ជនជាប់ចោទបានសារភាពកាន់តែច្រើនឡើង អំពីអង្គហេតុនានាដែលបង្ហាញនូវចំពោះមុខគាត់ ប៉ុន្តែវាក៏មានភាពមិនស៊ីសង្វាក់គ្នា និងចន្លោះប្រហោងមួយចំនួននៅក្នុងសេចក្តីសារភាពរបស់គាត់។ អាស្រ័យហេតុនេះ យើងខ្ញុំសូមស្នើដល់អង្គជំនុំជម្រះពិនិត្យទៅលើភ័ស្តុតាងនៅពេលធ្វើការពិចារណាពីសាលក្រមរបស់ខ្លួន ដោយមិនគ្រាន់តែយោងទៅលើអង្គហេតុដែលបានឯកភាពគ្នានោះទេ។ ជាការសំខាន់សមល្មម ដែលគេត្រូវកត់សម្គាល់ចំពោះជនជាប់ចោទដែលមិនព្រមឯកភាពនៅក្នុងករណីនេះ។ គាត់មិនបានឯកភាព គាត់បានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះដោយចេតនាទេ ប៉ុន្តែបានធ្វើតាមបញ្ជានិងការបង្ខិតបង្ខំរបស់ថ្នាក់លើ ដែលបង្ខំឱ្យគាត់ប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ ដូច្នេះ ទោះបីជាគាត់បានសារភាព អំពីអង្គហេតុជាច្រើននៅ

ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទិន្ននឹងសកម្មភាពឧក្រិដ្ឋនៅមន្ទីរស-២១ របស់គាត់ក៏ដោយ ក៏គាត់បានសារភាពតិចតួចប៉ុណ្ណោះអំពីចេតនាឧក្រិដ្ឋរបស់គាត់។ និយាយដោយខ្លី គាត់បានអះអាងថា ទោះបីជាគាត់ជាអ្នកអនុម័តបទបញ្ជាឧក្រិដ្ឋនេះក្តី ក៏គាត់បានធ្វើដូច្នេះដោយសារមានការគំរាមកំហែងសម្លាប់ជីវិតគាត់ពីថ្នាក់លើរបស់គាត់តែប៉ុណ្ណោះ។

ដូចលោកប្រធាន លោក លោកស្រីចៅក្រមជ្រាបស្រាប់ហើយថា បំណងឧក្រិដ្ឋគឺជាចំណុចសំខាន់សម្រាប់ធ្វើការ កំណត់សម្រេចអំពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋណាមួយ ដូចគ្នានឹងអំពើឧក្រិដ្ឋដែរ។ នៅក្នុងករណីនេះ អំពើខកខានមិនមានការព្រមព្រៀងរវាងគាត់ចំពោះបំណងឧក្រិដ្ឋពេញលេញ ផ្អែកទៅលើភ័ស្តុតាងដាក់កំហិតចំពោះអនុភាពនៃការព្រមព្រៀងរបស់គាត់ចំពោះអង្គហេតុនានា។

ហេតុដូច្នេះ សូមចងចាំថា កង្វះខាតដ៏សំខាន់នៃការព្រមព្រៀងរបស់គាត់លើអំពើព្រហ្មទណ្ឌរបស់គាត់ចាប់ពីការស៊ើបសួររហូតដល់ពេលសវនាការ យើងខ្ញុំសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងគួរតែធ្វើការពិនិត្យទៅលើភ័ស្តុតាងទាំងមូលនៅពេលពិចារណាអំពីសាលក្រមរបស់ខ្លួន ដោយមិនគ្រាន់តែយោងលើអង្គហេតុដែលបានព្រមព្រៀងគ្នាប៉ុណ្ណោះទេ។

ដូចជនជាប់ចោទបានទទួលយកហើយថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមានរចនាសម្ព័ន្ធច្បាប់ត្រឹមត្រូវ មិនមានប្រព័ន្ធយុត្តិធម៌ត្រឹមត្រូវទេ មិនមានតុលាការ មិនមានកងកម្លាំងនគរបាល និងក៏មិនមានច្បាប់បោះពុម្ពផ្សាយ ដែលប្រជាជនកម្ពុជាអាចយកធ្វើជាគោលការណ៍ណែនាំទេ។

ផ្ទុយមកវិញ មន្ទីរសន្តិសុខនានាត្រូវបានបង្កើតឡើងនូវទូទាំងប្រទេស ដែលនៅក្នុងមន្ទីរសន្តិសុខទាំងនេះ កប្បកុម្មុយនីស្តកម្ពុជាបានឃុំឃាំង និងសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ចោលជនណាដែលគេបានភ្ជាប់ទៅនឹងអតីតសាធារណរដ្ឋខ្មែរ ឬជនណាដែលគេសង្ស័យពីបទល្មើសប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យថ្មី។

គ្រប់ពេលទាំងអសើមិនមានការការពារផ្លូវច្បាប់ សិទ្ធិទទួលបានការជំនុំជម្រះក្តី ឬតំណាងដោយត្រឹមត្រូវយុត្តិធម៌ឡើយសម្រាប់ជនដែលត្រូវគេចាប់ខ្លួនទាំងនោះ។ ជនជាប់បាននិយាយនៅក្នុងពេលសវនាការ វាជាការត្រឹមត្រូវជាង បើសិនគេពិពណ៌នាអំពីមន្ទីរសន្តិសុខទាំងអស់ថា ជាបន្ទប់ស្លាប់ ជាជាងថាជា “គុក” ដោយសារ គេគ្មានក្តីសង្ឃឹមថា នឹងមានការដោះលែងទេ។

[០៩:៣៨:៥២]

ហេតុអ្វីបានជាមនុស្សត្រូវបានគេប្រព្រឹត្តមកលើយ៉ាងសាហាវឃោរឃៅដូច្នេះ? ហេតុអ្វីបានជា

មនុស្សយ៉ាងច្រើនត្រូវបានគេសម្លាប់? ភ័ស្តុតាងបានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការធ្វើទុក្ខបុកម្នេញខាងនយោបាយក្នុងលើវិសាលភាពថ្នាក់ជាតិ។ ការសម្លាប់ត្រូវបានជំរុញដោយគោលនយោបាយបក្ស និងរើសអើង ដើម្បីកម្ទេចខ្មាំងទាំងអស់នៃរបបនេះ។ ជានិយមសំដៅទៅលើបុគ្គលណាដែលត្រូវបានគេគិតថាវិវត្តន៍តាមឆ្នាំដែលកន្លងផុតទៅ។ នៅដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យជនរងគ្រោះនៃគោនយោបាយ គឺជាមន្ត្រីយោធារបស់អតីតរបស់របបសាធារណរដ្ឋខ្មែរ។ ដល់ឆ្នាំ១៩៧៦ ប្រព័ន្ធកម្មសិទ្ធដីធ្លី និងទ្រព្យសម្បត្តិឯកជនទាំងអស់ត្រូវបានបំបាត់ចោល ទីក្រុងនានាត្រូវបានជម្លៀសដោយបង្ខំ ហើយប្រជាជនកម្ពុជាទាំងមូលត្រូវបានបណ្តេញឲ្យទៅរស់នៅធ្វើការតាមសហករណ៍ ឬការដ្ឋានផ្សេងៗ។ ប្រជាជនដែលពីមុនដែលធ្លាប់ជាកសិករ ងាយនឹងត្រូវចាប់ខ្លួនដោយសារតែមាននិន្នាការទន់ទៅរកពួកមូលធន ពួកសក្តិភូមិ និងពួកផ្សេងទៀត ដែលគេហៅថា ពួកជិះជាន់គេ ហើយជាចុងក្រោយបក្សកុម្មុយនីស្តកម្ពុជាបានចាប់ផ្តើមចំណុចដៅរបស់ខ្លួនៅលើក្រុមមនុស្សរបស់ខ្លួនឯង ដូចដែលចំនួនមនុស្សយ៉ាងច្រើនត្រូវបានបោសសម្អាតពីក្នុងចំណោមមនុស្សដែលមានឋានន្តរសក្តិក្នុងជួរបដិវត្តន៍។

ឯកសារដែលមានការដកស្រង់តយ៉ាងច្រើនចុះក្នុងខែមីនា ឆ្នាំ១៩៧៦ ចេញពីគណៈកម្មាធិការកណ្តាលនៃបក្សកុម្មុយនីស្តកម្ពុជា បើតាមឯកសារនេះ បានកំណត់សិទ្ធិអំណាចក្នុងការកម្ទេចខ្មាំងទាំងខាងក្នុងនៅក្រៅជួរ។ ចាប់តាំងពីពេលនោះមក ជនរងគ្រោះភាគច្រើនបំផុត គឺជាអ្នកដែលត្រូវគេបោសសម្អាតនៅក្នុងផ្ទៃបក្ស នៅក្នុងជួរកងទ័ព។ ចាប់តាំងពីថ្ងៃដំបូងនៃរបបនេះ ប្រទេសកម្ពុជានិងប្រជាជនវៀតណាមត្រូវបាន គេដាក់ចំណុចដៅយ៉ាងពិសេស ជាសត្រូវស្លាប់របស់កម្ពុជាប្រជាធិបតេយ្យ។

នៅក្នុងប្រទេសកម្ពុជា បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការបោសសម្អាតប្រឆាំងនឹងអាណិកជនវៀតណាមទាំងអស់ ឬជនណាដែលគេសង្ស័យថា កំពុងតែស្វែងរកការអាណិតអាសូរពីវៀតណាម។ នៅតាមបណ្តោយព្រំដែនគោក និងព្រំដែនទឹករបស់ខ្លួន កម្លាំងកម្ពុជាប្រជាធិបតេយ្យ បានធ្វើការលុកលុយ ប្រដាប់អាវុធម្តងហើយ ម្តងទៀតនៅក្នុងទឹកដីវៀតណាម ចាប់តាំងពីខ្លួនដណ្តើមបានអំណាចភ្លាមនៅក្នុងខែមេសា ឆ្នាំ១៩៧៥។

[០៩:៤១:៤៥]

ពីដំបូង វាជាសង្គ្រាមលាក់កំបាំងមួយ ហើយបក្សកុម្មុយនីស្តកម្ពុជាបានប្រកាសជាចំហអំពីអរិភាពនៅចុងឆ្នាំ១៩៧៧ ប៉ុន្តែដល់ពេលដំណាក់កាលនោះ ទាហាននិងជនស៊ីវិលវៀតណាមជាច្រើននាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលជាស្រេចនៅមន្ទីរស-២១។ បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការ

បោសសម្អាតដោយគ្មានមេត្តាប្រឆាំងនឹងកម្មាភិបាលខ្លួនឯងផ្ទាល់ ជាមេដឹកនាំជាន់ខ្ពស់ដែលគេសង្ស័យថា "ក្បត់"។

មន្ទីរស-២១ បានអនុវត្ត និងជួយសម្រួលដោយផ្ទាល់ទៅលើការបោសសម្អាតនេះ ដោយទទួលយកអ្នកទោសយ៉ាងច្រើនមកពីតំបន់ ក្រសួង និងអង្គភាពយោធានានា ដែលជាចំណុចដៅនៅទូទាំងសម័យកាលទាំងមូលក្នុងពេលដែលគុកទាំងនោះនៅប្រតិបត្តិការ។ ពីភូមិភាគពាយ័ព្យយ៉ាងហោចណាស់មានមនុស្ស មួយម៉ឺនពីរពាន់ដប់មួយនាក់ ត្រូវបានចាប់បញ្ជូនទៅមន្ទីរស-២១។ យ៉ាងហោចណាស់មនុស្ស មួយម៉ឺនមួយពាន់ហុកសិបប្រាំនាក់ ត្រូវបានចាប់ខ្លួនពីភូមិភាគបូព៌ា និងបញ្ជូនទៅមន្ទីរស-២១។

នៅពេលដែលគេដាក់ចំណុច ទៅលើក្រសួង អ្នកទោសជាងបួនពាន់នាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនទៅមន្ទីរស-២១ ទាំងក្រសួងថ្នាក់មជ្ឈិមរបស់កម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្នុង និងជុំវិញភ្នំពេញ និងក្រសួងអមភូមិភាគនានា។

មន្ទីរស-២១គឺជាឧបករណ៍មួយជួយសម្រួលដល់ការបោសសម្អាតនៅក្នុងជួរកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យទាំងមូល រួមទាំងនៅអគ្គសេនាធិការយោធានៅថ្នាក់មជ្ឈិម ថ្នាក់វរសេនាធំ និងកងពលធំតាមភូមិភាគ និងកងឈ្លប។ បុគ្គលយោធារបស់កម្ពុជាប្រជាធិបតេយ្យជាច្រើនពាន់នាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅមន្ទីរស-២១ ចាប់តាំងពីដើមដំបូងក្នុងឆ្នាំ១៩៧៦មក។ ការបោសសម្អាតនេះបានត្រួសត្រាយផ្លូវជាតួយ៉ាងសម្រាប់ការបោសសម្អាតបន្តទៀតទៅលើកម្មាភិបាលស៊ីវិល។

ជនជាប់ចោទបានឯកភាពទៅលើសេចក្តីលម្អិតដ៏សំខាន់អំពីការបង្កើតទីតាំង រូបសណ្ឋាន និងប្រតិបត្តិការរបស់មន្ទីរស-២១។ គាត់ទទួលយកដោយបានបញ្ជាក់ថា មន្ទីរស-២១ ត្រូវបានបង្កើតឡើងក្នុងកិច្ចប្រជុំមួយដែលមានការកោះធ្វើឡើងដោយនាយអគ្គសេនាធិការយោធា សុន សេន នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ និងបានក្លាយទៅជាមន្ទីរដែលមានប្រតិបត្តិការពេញលេញចាប់ពីខែតុលា ឆ្នាំនោះមក។ គាត់ឯកភាពថា អគារមន្ទីរស-២១ ត្រូវបានផ្លាស់ទៅកាន់ទីតាំងមួយចំនួននៅក្នុងពេល៨ខែដំបូងនៃប្រតិបត្តិការរបស់ខ្លួន។ ដែលនៅចុងក្រោយត្រូវបានបោះទីតាំងនៅបរិវេណនៃវិទ្យាល័យពញាយ៉ាតនៅភ្នំពេញ។ មានទីតាំងស្ថិតនៅចន្លោះផ្លូវលេខ១១៣ ១៣១ ១២០ និងផ្លូវ៣៥០។

[០៩:៤៥:00]

គម្រោងប្លង់ និងរូបសណ្ឋានបន្ទប់ឃុំឃាំង បន្ទប់សួរចម្លើយ និងអគាររដ្ឋបាលមិនត្រូវបានតវ៉ាពីមេធាវីការពារក្តីទេ។ ហើយមុខងារជាចម្បងរបស់អង្គភាពនៃបុគ្គលិកនីមួយៗ ដែលបម្រើការងារនៅ

ទីនោះ ក៏គ្មានការតវ៉ាដែរ។ ដូចយើងបានឃើញរួចមកហើយ បរិវេណកណ្តាលនៃសាលានេះ និងអគារសំខាន់ៗទាំងប្រាំដែលស្ថិតនៅក្នុងសាលានេះគឺជាបេះដូងនេះប្រតិបត្តិការណ៍របស់មន្ទីរស-២១។

នៅពេលណាមួយក៏ដោយអ្នកទោសប្រមាណមួយពាន់ប្រាំរយនាក់ ត្រូវបានគេឃុំខ្លួនក្នុងផ្នែកនៃអគារសម្រាប់ឃុំឃាំង។ បរិវេណកណ្តាលត្រូវបានហ៊ុមព័ទ្ធដោយរបងស័ង្កសីខ្ពស់ ដោយមានបន្លាលួសព័ទ្ធជុំវិញពីលើឆ្មាំយាមកាមប្រដាប់ដោយអាវុធជាច្រើនជាន់ បានល្បាតទាំងខាងក្នុងនិងខាងក្រៅ។

ទីតាំង មន្ទីរស-២១ ដែលស្ថិតនៅជុំវិញក្បែរបរិវេណកណ្តាល រួមមានមន្ទីរសួរចម្លើយសម្រាប់អ្នកទោសទូទៅ និងអ្នកទោសពិសេស ឬអ្នកមានឋានន្តរសក្តិខ្ពស់។ មជ្ឈមណ្ឌលពេទ្យ ជាទីកន្លែងអ្នកទោសដែលត្រូវគេនាំយកទៅបូមឈាមដោយបង្ខំ និងភ័ស្តុតាងសម្រាប់ផ្គត់ផ្គង់ផ្នែកពេទ្យ និងសម្ភារៈផ្គត់ផ្គង់ដទៃទៀត។ សង្កាត់សម្រាប់បុគ្គលិកមន្ទីរស-២១ រស់នៅ បន្ទប់សម្រាប់បុគ្គលិករៀនសូត្រផ្នែកនយោបាយ និងបន្ទប់សម្រាប់គាំទ្រផ្នែកបោះពុម្ពផ្សាយ បរិវេណខាងក្រៅជុំវិញ ផាលសិប្បករ រណបទាំងនេះក៏ត្រូវបានរក្សាទុកផងដែរ។

មន្ទីរស-២១ គឺជាមណ្ឌលធ្វើទារុណកម្មនិងសម្លាប់ជាប្រព័ន្ធ។ មន្ទីរនេះមានប្រសិទ្ធភាពយ៉ាងខ្លាំងវិន័យគឺតឹងរ៉ឹង ការសម្ងាត់ត្រូវបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន បុគ្គលិកត្រូវបានរៀបចំតាមខ្សែយោធាអង្គភាពនានាបំពេញមុខនាទីដាច់ដោយឡែកៗពីគ្នា ហើយអ្នកទោសទាំងអស់ត្រូវបានឃាមកាមយ៉ាងជិតដល់ ដោយប្រកាន់យកនូវលក្ខខណ្ឌយ៉ាងដូច្នេះ ដើម្បីបំផ្លាញចោលនូវសេចក្តីថ្លៃថ្នូរ និងគំនិតក្នុងការតដៃ។ ដោយសារតែមន្ទីរស-២១ មិនមែនកើតឡើងសាមញ្ញត្រឹមតែឃុំខ្លួនអ្នកទោស នៅពេលណាសម្លាប់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីបានចម្លើយសារភាពជាលាយលក្ខណ៍អក្សរពីពួកគេផងដែរ។ អង្គភាពបុគ្គលិកធំជាងគេទាំងពីរ គឺផ្នែកការពារ និងផ្នែកសួរចម្លើយ។ ផ្នែកការពារមានការទទួលខុសត្រូវលើមុខនាទីទាំងអស់ ទាក់ទិននឹងការដឹកជញ្ជូន ការឃាមកាម និងការសម្លាប់អ្នកទោស។ ផ្នែកសួរចម្លើយត្រូវបានចែកចេញជាផ្នែក ដែលត្រូវសួរអ្នកទោសសំខាន់ៗ និងសួរអ្នកទោសធម្មតា។

ដូចអង្គជំនុំជម្រះបានស្តាប់រួចមកហើយ នៅមានការបែងចែកបន្តទៀតនៅក្នុងក្រុមទាំងនោះដូចជាក្រុមធ្វើទារុណកម្មដែរ ហៅថាក្រុមក្តៅ ក្រុមមិនធ្វើទារុណកម្ម ហៅថាក្រុមត្រជាក់ និងក្រុមប្រើបច្ចេកទេសដែលគេស្គាល់ថា ក្រុមអង្កៀម ដែលជាក្រុមធ្វើទារុណកម្មរបៀបផ្សេងមួយទៀត និងជាក្រុមសួរសំណួរសាចុះសាឡើង ដើម្បីបំបែកឆន្ទៈរបស់អ្នកទោសណា ដែលមិនងាយឆ្លើយសារភាព។

[០៩:៤៨:១៦]

អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់អតីតសមាជិកបុគ្គលិកនៃមន្ទីរស-២១រួចមកហើយ ពួកគេភាគច្រើនបំផុត មានប្រវត្តិជាកសិករធម្មតា ដោយពុំមានការអប់រំជាផ្លូវការទេ។ មានខ្លះក្មេងមែនទែនជាកត្តាងាយស្រួលដល់អ្នកបដិវត្តន៍ជើងចាស់ ក្នុងការបញ្ចូលមនោគមវិជ្ជាទៅលើពួកគេ។ ភាគច្រើននៃអតីតសមាជិកបុគ្គលិកទាំងនោះ មិនមានទឹកចិត្តមុតស្រួចក្នុងការនិយាយអំពីការងារដែលពួកគេបានធ្វើនៅមន្ទីរស-២១ទេ។ មិនមានអ្វីដែលគួរមន្ទិលសង្ស័យទេថា ពួកគេមានការពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មនានា នៅមន្ទីរស-២១ ជាឧក្រិដ្ឋកម្មដែលជួនកាលមិនអាចញ៉ាំងឲ្យគេសារភាពបាន។ នេះប្រហែលជាដោយសារគេខ្លាចថា ពួកគេនឹងទទួលការចោទប្រកាន់ ខ្លាចចាប់ខ្លួន និងខ្លាចគេនាំខ្លួនមកវិនិច្ឆ័យទោស ប៉ុន្តែសមាជិកបុគ្គលិក ដែលជាអ្នកនៅក្រោមបង្គាប់គេទាំងអស់នេះ មិនមែនជាអ្នកដែលមានឥទ្ធិពល ឬអំណាចទេ ពួកគេមិនមែនជាអ្នកបង្កើត ឬអភិវឌ្ឍគោលនយោបាយនានាស្តីពីការតាមរក និងកម្ទេចខ្មាំងទេ។ ប្រហែលមានការលើកឡើងចំពោះអតីតអ្នកសួរចម្លើយឈ្មោះ ម៉ម ណៃ ដែលជាអ្នកទទួលបានការអប់រំខ្ពស់ និងជាអ្នកនៅតែជាជនកុម្មុយនីស្ត ដែលមិនទាន់បានកសាងខ្លួននៅឡើយ រហូតមកដល់បច្ចុប្បន្ននេះ។ សមាជិកទាំងនេះ មានការយល់ដឹងតិចតួចអំពីទស្សនវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា និងគ្មានជំនឿរឹងមាំងក្នុងមនោគមវិជ្ជានោះទេ។

សមាជិកបុគ្គលិកធម្មតារបស់មន្ទីរស-២១ គឺជាឧបករណ៍ដែលខ្លួនបានប្រើប្រាស់ដោយកម្មាភិបាលជាន់ខ្ពស់ និងអ្នកដែលបានកែទម្រង់ និងបោកបញ្ឆោតដោយជនជាប់ចោទ និងគណៈកម្មាធិការមន្ទីរស-២១។ នៅគ្រប់ថ្នាក់ និងគ្រប់ឱកាសទាំងអស់គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាលើការកម្ទេចខ្មាំង ត្រូវបានពង្រឹងអនុវត្តជាបន្តបន្ទាប់។ បុគ្គលិកមន្ទីរស-២១ បានចូលរួមប្រជុំ និងចូលរួមវគ្គអប់រំនយោបាយយ៉ាងខ្ជាប់ខ្ជួន។ ពួកគេតម្រូវឲ្យអានទស្សនាវដ្តីទង់បក្សបដិវត្តន៍ និងយុវជន យុវនារីបដិវត្តន៍ វិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យបានផ្សាយជាទៀងទាត់តាមឧបករណ៍បំពងសំឡេងនៅក្នុងគុក។ បុគ្គលិកត្រូវបានគេធ្វើឲ្យជ្រួតជ្រាបទាំងស្រុងពីវប្បធម៌បដិវត្តន៍តាមភាសាដែលគេតម្រូវឲ្យប្រើប្រាស់ និងតាមរយៈការប្រកាន់ខ្ជាប់ខ្ជួន ដែលគេមិនអាចសួរណែនាំនូវមាគ៌ានយោបាយ ដែលគេនោះ ជាការទាមទារចំពោះពួកគេ។

[០៩:៥១:០៧]

មានការលើកឡើងថាកម្រិតនៃអរិយធម៌នៅក្នុងសង្គមមួយអាចត្រូវបានធ្វើការវិនិច្ឆ័យ ដោយការឲ្យចូលនៅក្នុងគុករបស់ខ្លួន។ មិនមានការតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវិនិច្ឆ័យលើសីលធម៌

របស់សង្គមទាំងនោះទេ ប៉ុន្តែគ្រាន់តែឲ្យកំណត់អំពីការទទួលខុសត្រូវរបស់បុគ្គលណាម្នាក់ចំពោះឧក្រិដ្ឋកម្មជាក់លាក់ទាំងឡាយ ដែលបានកើតឡើងនៅមន្ទីរស-២១តែប៉ុណ្ណោះ ហើយវិធីដ៏ច្បាស់លាស់ជាងគេបំផុតនោះ គឺប្រហែលជាការបង្ហាញឲ្យឃើញអំពីឧក្រិដ្ឋកម្មទាំងនេះ គឺការស្រាវជ្រាវជាថ្មីឡើងវិញរកមើលស្លាកស្នាមដាននៃការធ្វើដំណើរដ៏ប្រកបដោយភាពគួរឲ្យរន្ធត់ ព្រឺរន្ធត់របស់ពួកអ្នកទោស ចាប់តាំងពីពេលត្រូវបានចាប់ខ្លួន រហូតដល់ពេលត្រូវគេសម្លាប់។

មន្ទីរស-២១ ត្រូវបានគេស្គាល់ថា ជាកន្លែងមួយដែលមិនអាចរត់គេចចេញពីទីនោះមកវិញបានទេ គឺដោយសំណាងទាំងស្រុងហើយដែលអង្គជំនុំជម្រះនេះបានបើកធ្វើសវនាការស្តាប់ដោយផ្ទាល់នូវភ័ស្តុតាងដែលផ្តល់ដោយមនុស្សបីនាក់ ដែលធ្លាប់បានជាប់ជាអ្នកទោសនៅទីនោះ។ ដោយសារតែទេពកោសល្យរបស់ពួកគេទាំងនោះ ជាជាងគំនូរ និងជាងចម្លាក់ ទើបបានរួចជីវិត ពួកគេឲ្យរួចផុតពីការយកទៅសម្លាប់ចោលភ្លាមៗ បន្ទាប់ពីពួកគេទៅដល់មន្ទីរស-២១ ក្នុងនាមជាអ្នកទោស។

ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យនៅដើមខែមករា ឆ្នាំ១៩៧៩ និងភាពវឹកវរច្របូកច្របល់ដែលកើតឡើង បានបន្តពីនោះបានផ្តល់ភ័ព្វសំណាងដល់ពួកគាត់រត់គេចខ្លួន បើពុំនោះទេ ពួកគេមុខជាត្រូវគេផ្តន្ទាទោសប្រហារជីវិតជាក់ជាពុំខានឡើយ។ ពួកអ្នកទោសភាគច្រើនណាស់ប្រហែលត្រូវបានគេចាប់ខ្លួនដោយមិនបានការប្រមានឲ្យដឹងជាមុនមកពីតាមអង្គភាពស៊ីវិល ឬយោធានានា។ ពួកគេត្រូវអាចត្រូវបានគេសង្ស័យ និងជឿថាត្រូវបានគេយកចេញឲ្យទៅកាន់កន្លែងផ្សេងទៀត ដើម្បីយកទៅធ្វើការអប់រំកែប្រែ ធ្វើការសាកពិសោធខាងវិទ្យាសាស្ត្រ ឬដើម្បីឲ្យទៅបំពេញភារកិច្ចឲ្យអង្គការនៅការដ្ឋានផ្សេងទៀត។ ពួកគេប្រហែលជាត្រូវគេចាប់ខ្លួនភ្លាមៗដោយលួចលាក់មិនឲ្យដឹង ហើយជាញឹកញយតែងតែធ្វើឡើងក្នុងពេលយប់។

អតីតអ្នកទោសនិងជាអ្នកដែលរស់រានមានជីវិតនៅមន្ទីរស-២១ ឈ្មោះ វ៉ាន់ ណាត បានរៀបរាប់អំពីថា តើគាត់ត្រូវគេបញ្ជូនទៅថ្នាក់ស្រុក និងទៅថ្នាក់មន្ទីរសន្តិសុខភូមិភាគ ហើយត្រូវគេធ្វើទារុណកម្ម សួរចម្លើយបែបដូចម្តេចខ្លះ? គាត់បានរៀបរាប់អំពីការធ្វើដំណើរដ៏ប្រកបដោយព្រឺរន្ធត់តាមរថយន្តកាមីញ៉ុង នៅពេលយប់ទៅកាន់មន្ទីរស-២១ ដោយត្រូវគេដាក់ខ្នោះជើង រួមជាមួយនឹងអ្នកទោសម្ភៃទៅសាមសិបនាក់ផ្សេងទៀត។ រូបគាត់និងអ្នកទោសផ្សេងៗទៀតត្រូវបានគេនាំមុខឲ្យដើរចូលទៅក្នុងពន្ធនាគារ ដោយទាក់ជើងរកកលចង់ដួល ដោយមានចងមុខនិងមានខ្សែព្យួរចងរុំនៅត្រង់ក ដែលត្រូវបានឆ្មាំគុកនិយាយឡកឡឺយ និងសើចចំអកដាក់។

នៅពេលឆ្លងកាត់តាមខ្លោងទ្វារធំ អ្នកទោសភាគច្រើនត្រូវបានគេឱ្យតម្រៀបចូលនៅទីធ្លាកណ្ដាលនៃអគារ "គ"។ បុគ្គលិកនៃអង្គភាពខាងឯកសារ បានធ្វើការកត់ត្រាប្រវត្តិសង្ខេបរបស់អ្នកទោសម្នាក់ៗ បន្ទាប់មកពួកគេត្រូវបានគេថតរូប រូបថតសខ្មៅ ដែលផ្តិតរួចសម្រាប់រាប់ពាន់សន្លឹកបាននៅសល់នៅឡើយក្នុងពេលដ៏យូរអង្វែង បន្ទាប់ពីម្ចាស់របស់រូបថតទាំងនេះត្រូវបានគេសម្លាប់បាត់ទៅហើយ រូបភាពទាំងនេះ ស្ថិតនៅជាការចងចាំដ៏ខ្លាំងក្លាមួយ អំពីភាពភ័យខ្លាច ការឡប់ស្មារតី កំហឹង និងការតូចចិត្ត ដែលអ្នកទោសត្រូវតែមានអារម្មណ៍បែបនេះក្នុងពេលដែលពួកគេបានមកដល់មន្ទីរស-២១។

អ្នកទោសទាំងអស់ត្រូវបានគេថតរូប និងរៀបចំចំណាត់ថ្នាក់ បន្ទាប់មកទៀតអមដំណើរទៅកាន់កន្លែងឃុំឃាំងនានា ដោយផ្អែកលើមូលដ្ឋាននៃការសន្មតិអំពីសារសំខាន់ និងការយល់ឃើញអំពីភាពដែលអាចធ្វើឱ្យមានគ្រោះថ្នាក់។ អ្នកទោសភាគច្រើនបំផុត ត្រូវបានគេឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងរួមនានា មានអ្នកទោសចំនួនរាប់សិបត្រូវបានគេដាក់ច្រវាក់ជាប់ជាមួយគ្នា។ អតីតឆ្មាំគុកឈ្មោះ ឈុន ផល បានរៀបរាប់អំពីស្ថានភាពដែលធ្វើឱ្យភ័យតក់ស្លុត ដែលមានអ្នកទោសជាច្រើនត្រូវបានឃុំខ្លួននៅក្នុងនោះ ដោយជាប់ខ្នោះជើងតម្រៀបគ្នាជាជួរយ៉ាងវែង ដែលគ្មានអ្វីស្លៀកពាក់ទេ គឺមានតែខោអាវហែករយ៉ៃតែប៉ុណ្ណោះ។ គេឱ្យហូបបបររាវប៉ុន្មានស្លាបព្រា ហើយងូតទឹកសម្អាតខ្លួនដោយសារការបាញ់ទុយោទឹកពីចម្ងាយ ស្រោចទឹកទៅលើកន្លែងដែលពួកគេដេក។

[០៩:៥៦:៣២]

វ៉ាន់ ណាត បានរៀបរាប់អំពីថា តើគាត់បានបាត់បង់សេចក្តីថ្លៃថ្នូរបែបដូចម្តេចខ្លះក្នុងស្ថានភាពបែបនេះ? តាមពាក្យរបស់គាត់និយាយថា ពួកអ្នកទោសត្រូវបានគេប្រព្រឹត្តចំពោះខ្លួនដូចជាសត្វធាតុច្រើនជាងជាមនុស្ស។ គេមិនអនុញ្ញាតឱ្យអ្នកទោសធ្វើចលនាងើបអង្គុយ ឬនិយាយគ្នាឡើយ គ្មានការសម្អាត ឬអនាម័យត្រឹមត្រូវទេ។ ហើយគេតម្រូវឱ្យអ្នកទោសបន្ទោបង់នៅក្នុងកែសដែក ដែលគេហុចបន្តគ្នាចុះឡើងនៅក្នុងបន្ទប់។ ជំងឺនិងដំកាត់ផ្សេងៗ គឺបានកើតឡើងពាសពេញ។ អ្នកទោសមួយចំនួនបានស្លាប់នៅកន្លែងដែលពួកគេដេក ក៏ប៉ុន្តែសាកសពនៅជាប់ខ្នោះនៅឡើយ ដែលជាប់គ្នាជាមួយអ្នកទោសដទៃទៀតសម្រាប់មួយរយៈពេលជាបន្តទៅទៀត។ ពួកអ្នកទោសត្រូវបានកាត់បន្ថយឱ្យនៅក្នុងស្ថានភាពមួយ គួរឱ្យអាណិតអាសូរណាស់ មានភាពស្គមស្គាំងឃើញតែស្បែកដណ្តប់ឆ្អឹង ព្រមទាំងអត់អាហារពួកគេបានខំប្រឹងព្យាយាមបរិភោគសត្វល្អិតៗ ដែលធ្លាក់មកលើអំពូលភ្លើង ដើម្បីចម្អែតនូវការស្រេកឃ្លាន ទោះបីជាដឹងថា បើសិនជាត្រូវគេឃើញនោះ ខ្លួនមុខជានឹងត្រូវគេដាក់ទណ្ឌកម្មយ៉ាង

ធ្ងន់ធ្ងរជាពុំខានក៏ដោយ។ ពួកគេបានបាត់បង់អស់នូវចេតនាដែលចង់រស់នៅតទៅទៀត។ មានអ្នកទោសមួយចំនួនបានព្យាយាមធ្វើអត្តឃាត ទោះបីជានៅក្នុងបន្ទប់ឃុំឃាំងទាំងនោះ មានលក្ខខណ្ឌយ៉ាងតឹងរ៉ឹង និងមានឆ្មាំគុកយាមកាមយ៉ាងច្រើន ដែលមិនងាយមានឱកាសអាចធ្វើបែបនេះក៏ដោយ។ អ្នកទោសភាគច្រើនត្រូវបានគេសួរចម្លើយ ពួកគេត្រូវគេយកចេញពីបន្ទប់ឃុំឃាំងទៅ និងបណ្ដើរដោយឆ្មាំគុកដែលប្រដាប់ដោយអាវុធទៅកាន់បន្ទប់សួរចម្លើយសម្រាប់ម្នាក់ៗ ដែលនៅទីនោះពួកគេត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគំរាមកំហែង ការសម្លុតបំភ័យ អំពើហិង្សា និងការធ្វើទារុណកម្មជាច្រើនប្រភេទផ្សេងៗគ្នា។

អតីតអ្នកទោស និងដែលនៅរស់រានមានជីវិតឈ្មោះ ជុំ ម៉ី បានទទួលរងនូវការប្រព្រឹត្តកម្មដ៏សែនអាក្រក់អាក្រីមកលើរូបគាត់ ការជួបប្រទេសនូវបទពិសោធន៍របស់គាត់ បានធ្វើឲ្យគាត់បាក់ស្បាតយ៉ាងខ្លាំង។ អង្គជំនុំជម្រះសាលាដំបូងជាអ្នកបានធ្វើសាក្សីលើគេដំបូងបង្អស់អំពីថា តើសូម្បីតែបានកន្លងផុតទៅអស់ជាងសាមសិបឆ្នាំហើយក្ដី ក៏មកទាល់សព្វថ្ងៃនេះ គាត់នៅតែមានការជឿចាប់នៅក្នុងចិត្តក្នុងការរាយរ៉ាប់ឡើងវិញអំពីអ្វីដែលបានកើតឡើង។ គាត់បានរៀបរាប់អំពីថា តើគេយកគាត់ចេញពីបន្ទប់ឃុំឃាំងរបស់គាត់ ចងមុខគាត់ និងបញ្ជាឲ្យគាត់អង្គុយនៅក្នុងបន្ទប់មួយដែលមានឈាមខ្ទាតប្រឡាក់ពាសពេញដែលនៅស្រស់ៗនេះតាមរបៀបដូចម្ដេចខ្លះ? គាត់ត្រូវបានគេសួរចម្លើយអំពីការចូលរួមរបស់គាត់ក្នុងគម្រោងផែនការក្បត់របស់ពួក សេ.អ៊ី.អា និង កា.ហ្សេ.បេ។ នៅពេលដែលគាត់បាននិយាយប្រាប់ទៅពួកអ្នកសួរចម្លើយថា គាត់មិនបានដឹងអំពីរឿងនោះទេនោះ គាត់ត្រូវបានគេវាយដំយ៉ាងសាហាវ ការធ្វើទារុណកម្មបានបន្តជាច្រើនថ្ងៃ និងច្រើនសប្ដាហ៍មកទៀត ហើយវិធីសាស្ត្រនៃការធ្វើទារុណកម្ម កាន់តែសាហាវឡើងៗ។ គាត់ត្រូវបានគេដាក់ឲ្យឆក់ខ្សែភ្លើង ហើយត្រូវគេដកក្រចកមេជើងរបស់គាត់។ ជាយថាហេតុ ដោយមានស្នាមបែក និងវង្វេងស្មារតីផងនោះ គាត់បានឆ្លើយសារភាពខុសពីការពិតដោយអារម្មណ៍រវើរវាយថា បានចូលរួមក្នុងគម្រោងផែនការក្បត់ ដែលក្នុងនោះរួមទាំងអ្នកដែលគាត់ធ្លាប់ស្គាល់ផង ដើម្បីគ្រាន់តែចង់ឲ្យអ្នកដែលវាយដំធ្វើទារុណកម្មគាត់ ឈប់វាយតែប៉ុណ្ណោះ។

ប៊ូ ម៉េង ជាជនរងគ្រោះដែលរស់នៅរស់រានមានជីវិតទីបី ដែលត្រូវបានធ្វើសវនាការស្ដាប់រួចហើយ ដោយអង្គជំនុំជម្រះសាលាដំបូងបានរៀបរាប់អំពី គាត់ត្រូវបានគេនាំយកទៅកាន់បន្ទប់មួយ និងត្រូវបានគេអញ្ជើញឲ្យធ្វើការជ្រើសរើស តើគួរឲ្យពួកអ្នកសួរចម្លើយប្រើប្រាស់ឧបករណ៍ណាមួយដើម្បីវាយរូបគាត់។ គាត់ត្រូវបានវាយនឹងដំបង និងវាត់នឹងខ្សែតីរហូតដល់បែកឈាមពេញពេលកំពុងត្រូវគេ

ជំរុញឲ្យឆ្លើយសារភាពថា “បានចូលរួមក្នុងគម្រោងផែនការក្បត់ជាមួយសេ.អ៊ី.អា និង កា.ហ្សេ.បេ”។ គាត់ត្រូវបានបុគ្គលិកមន្ទីរស-២១ ចំអកឡកឡឺយ វាយដំ ធ្វើទារុណកម្ម និងបំបាកមុខ។ មានមួយពេលនោះ គាត់ចោទជនជាប់ចោទបានបង្ខំឲ្យគាត់វាយគ្នាជាមួយនឹងជនជាប់ឃុំម្នាក់ទៀត ដែលហាក់ដូចជាការគិតឃើញតែពីផ្លូវអាក្រក់ដែលសម្រាប់តែកំសាន្តសប្បាយរបស់ខ្លួនតែប៉ុណ្ណោះ។

សម្រែកថ្ងូររបស់អ្នកទោសបានលាន់ឮរំពង ត្រឡប់មកវិញនូវជុំវិញបរិវេណនៃមន្ទីរស-២១។ ពួកគេបានវិលត្រឡប់មកកាន់មន្ទប់ឃុំឃាំងរបស់ខ្លួនវិញ ដោយមានស្នាមដាច់របួស និងគ្របដណ្តប់ទៅដោយឈាម និងមានស្នាមជាំ ដោយសារការធ្វើទារុណកម្ម។ ប៉ុន្តែ តាមឯកសារនានាដែលនៅសល់ពីមន្ទីរស-២១ និងបានបុគ្គលិកពន្ធនាគារដែលបានផ្តល់សក្ខីកម្ម ឬចម្លើយនៅចំពោះមុខអង្គជំនុំជម្រះយើងនេះ បានឲ្យដឹងថា មានការវាយដំធ្វើទារុណកម្មអាក្រក់ជាងនេះទៅទៀត។ ជាពិសេស ការអនុវត្ត ភាពស្អប់ខ្ពើមនៅមន្ទីរស-២១ រួមមានការបូមឈាមដោយបង្ខំ និងការអនុវត្តការវះកាត់ដើម្បីធ្វើកាយវិភាគលើមនុស្សនៅរស់។

អតីតអ្នកសួរចម្លើយម្នាក់ ប្រាក់ ខន បានរៀបរាប់អំពីថា តើការបូមឈាមពីអ្នកទោសដែលនៅរស់រហូតដល់អ្នកទោសដេកស្តូក ត្រដរខ្យល់ ហើយស្លាប់ បានធ្វើឡើងតាមបែបដូចម្តេចខ្លះ? ការអនុវត្តបែបនេះត្រូវបានបញ្ជាក់អះអាងការពិតដោយគ្រូពេទ្យ ម៉ក់ ស៊ីធីម និង សេក ដន។ ប្រធានផ្នែកឯកសារឈ្មោះ សួស ធី បានបញ្ជាក់ថា បញ្ជីឈ្មោះអ្នកទោស ត្រូវបានគេគូសឆូតចោលដែលសំគាល់ថា ត្រូវបានសម្លាប់រួចហើយ។ ដោយការបូមឈាមពីពួកគេអស់ហើយ។

[១០:០៣:០០]

ចំពោះជនជាប់ចោទខ្លួនគេផ្ទាល់ថា ការអនុវត្តបែបនេះជាក់ស្តែងគឺគ្មានន័យអ្វីទេ។ អង្គជំនុំជម្រះសាលាដំបូងបានឃើញអក្សរសរសេរដោយដៃ ដោយទឹកប៊ិចពណ៌ក្រហមក្បែរជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនទៀត ជាប្រយោគដ៏សាមញ្ញដែលដាក់ថា កម្ទេចស្មើនឹងឈាម។ ស្រដៀងគ្នានេះដែរ ជនជាប់ចោទបានទទួលសារភាពដោយសោះកក្រោះថា មានអ្នកទោសពីរបីនាក់ត្រូវបានគេយកទៅធ្វើការពិសោធន៍ស្រាវជ្រាវខាងវិជ្ជសាស្ត្រដើម្បីគោលបំណងធ្វើកាយវិភាគ។

ភាពសាហាវឃោឃៅព្រៃផ្សៃចំពោះអ្នកទោស គឺគេមិនដឹងថាតើមានព្រំដែនត្រឹមកម្រិតណាទេ ស្ថានភាពដ៏ស្មោកគ្រោក ដូចជាសត្វធាតុដែលពួកអ្នកទោសត្រូវឃុំឃាំងនៅទីនោះ និងការណែនាំផ្សេងៗដែលជនជាប់ចោទបានផ្តល់ឲ្យ ដើម្បីធានាកុំឲ្យចម្លើយសារភាពត្រូវដាច់នៅមុនពេលសួរចម្លើយ

ឲ្យបានចប់សព្វគ្រប់។ ដោយសារអ្នកទោសត្រូវស្លាប់នៅក្នុងពេលធ្វើទារុណកម្ម ដែលជាក់ស្តែងគឺបានបើកឲ្យពួកអ្នកសួរចម្លើយទាំងឡាយនូវសេរីភាពដូចសេះដាច់បង្ហៀរក្នុងការប្រើប្រាស់នូវអារម្មណ៍ស្រមើលស្រមៃរបស់ខ្លួន។ មានអ្នកទោសមួយចំនួនត្រូវគេបង្ខំឲ្យស៊ីអាចម៍។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់ត្រូវបានគេបង្ហាញឲ្យឃើញនូវឯកសារអំពីការភាពឃោឃៅទុរយស ដែលក្នុងនោះសង្ខេបសេចក្តីអំពីតើវិធីសាស្ត្រនេះត្រូវបានគេអនុវត្តបែបដូចម្តេចខ្លះទៅលើឈ្មោះ កែ គឹមហួត អតីតគ្រូរបស់ជនជាប់ចោទ។ ស្ទើរតែមិនអាចយល់បានអំពីថាជនជាប់ចោទ និងបុគ្គលិករបស់ខ្លួន ដែលទាំងអស់គ្នាសុទ្ធតែបាត់បង់អស់ លែងមានអារម្មណ៍រំភើបចំពោះការឈឺចាប់ខ្លោចផ្សារបស់មនុស្សដូចគ្នា ដែលធ្វើឲ្យពួកគេអាចប្រព្រឹត្តនូវអំពើឃោឃៅព្រៃផ្សៃបែបនេះទៅរួច។ ទាំងនេះគឺមិនបាច់ឆ្ងល់ទេ សុទ្ធតែជាលទ្ធផលដែលគេចាប់បានគឺភាពស្មោះភក្តីចំពោះបក្ស។

ការធ្វើទារុណកម្មខាងផ្លូវចិត្តក៏ដូចជាខាងផ្លូវកាយ ត្រូវបានគេប្រើប្រាស់ជាប្រចាំដើម្បីស្រង់យកចម្លើយសារភាពឲ្យបានពេញលេញ និងមានប្រយោជន៍ជាទីបំផុតចំពោះអ្នកទោស។ សូម្បីតែអ្នកទោសជាមន្ត្រីជាន់ខ្ពស់ក៏ដោយ ដែលទោះបីជាសត្រូវជាត្រូវជាប់ឃុំឃាំងនៅក្នុងបន្ទប់ឃុំឃាំងដាច់ដោយឡែកមិនដាក់នៅក្នុងបន្ទប់ឃុំឃាំងរួមក៏ដោយ ក៏ត្រូវគេវាយធ្វើបាបឲ្យឈឺចាប់យ៉ាងខ្លាំងនិងសម្លុតបំភ័យដែរ។

[១០:០៥:៤៥]

ជនជាប់ឃុំដែលមានឋានន្តរសក្តិខ្ពស់ដូចជា ណៃ សារ៉ាន ហៅ យ៉ា ត្រូវបានគេគំរាមកំហែងយ៉ាងសាហាវព្រៃផ្សៃប្រសិនបើពួកគេមិនឆ្លើយសារភាពទេនោះ អង្គការបានដឹងអស់ហើយ តើគ្រួសាររបស់ពួកគេរស់នៅទីណានោះ មានចំណុចខ្សោយណាមួយគឺត្រូវពួកអ្នកសួរចម្លើយចាប់យក។ សៀត ឆែ ហៅ ទុំ ដែលខ្លួនឯងផ្ទាល់គឺជាកម្មាភិបាលយោធាជាន់ខ្ពស់ដ៏សំខាន់ម្នាក់ ដែលបានតវ៉ាអំពីភាពស្លូតត្រង់របស់ខ្លួន បានប្រកាស់អំពីភក្តីភាពរបស់ខ្លួនចំពោះបក្ស ទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់គាត់ជាមួយនឹងគ្រួសារគាត់ ត្រូវបានគេយល់ឃើញថា ខាងផ្លូវអាក្រក់មួលបង្កាច់ប្រឆាំងនឹងរូបគាត់ ហើយរូបគាត់ត្រូវបានគេធ្វើទារុណកម្មឲ្យឆ្លើយសារភាពខុសពីការពិតថា គាត់បានប្រព្រឹត្តអំពើសហាយស្មន់ជាមួយនឹងកូនស្រីរបស់ខ្លួនឯង។ ការបញ្ជាក់បន្ថែមទៀតត្រូវតែធ្វើឡើងចំពោះការសួរចម្លើយ និងការប្រើប្រាស់ការសួរចម្លើយនេះ ដែលនៅក្នុងនោះមានចុះអំពីចម្លើយសារភាពទាំងឡាយដែលជាលទ្ធផលរបស់វា។ នៅក្នុងនយោបាយសង្គមរបស់កម្ពុជាប្រជាធិបតេយ្យ ដែលនាំទៅរកផ្លូវអាក្រក់នៅពេលដែលជនណាម្នាក់ត្រូវគេចាប់ខ្លួន គឺពួកគេត្រូវបានផ្តន្ទាទោសជាស្រេចរួចទៅហើយ។ អង្គការមិនដែលចាប់មនុស្សខុស

នោះទេ គឺជាទ្រឹស្តីជាសាកល។ គោលបំណងនៃការធ្វើទារុណកម្មលើពួកអ្នកទោសរហូតទាល់តែឆ្លើយសារភាព គឺមិនមែនគ្រាន់តែស្រង់យកចម្លើយតាមការស្មានរបស់ខ្លួនអំពីការចូលរួមនៅក្នុងផែនការក្បត់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងដើម្បីបញ្ចេញឲ្យដឹងអំពីការជនក្បត់ដទៃទៀត ដែលគេជឿថា បានរួមគ្នាក្បត់ប្រឆាំងនឹងរបបនេះផងដែរ។ ចម្លើយសារភាពដែលសរសេរដោយដៃ និងវាយអង្គុលីលេខចំនួនរាប់សែនទំព័រ ដែលជាលទ្ធផលបានមកពីការសួរចម្លើយអ្នកទោសនៃមន្ទីរស-២១។

អង្គជំនុំជម្រះសាលាដំបូងទើបតែបានឃើញចម្លើយសារភាពទាំងនេះតែមួយភាគតូចប៉ុណ្ណោះ។ សារសំខាន់នៃសេចក្តីចម្លើយសារភាពនានាចំពោះករណីរឿងដែលប្រឆាំងនឹងជនជាប់ចោទរូបនេះ គឺមិនមានខ្លឹមសារអ្វីច្រើនពេកដូចដែលពួកគេបញ្ជូនទៅឲ្យមេដឹកនាំជាន់ខ្ពស់នានានោះទេ។ ដូចដែលយើងនឹងត្រូវពិភាក្សាគ្នា ជនជាប់ចោទគឺជាមនុស្សតែម្នាក់គត់ដែលមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីរាយការណ៍ទៅឲ្យមេដឹកនាំជាន់ខ្ពស់នានា។ គាត់ជាអ្នកទទួលខុសត្រូវស្ទើរតែផ្តាច់មុខក្នុងការធ្វើចំណារទៅលើចម្លើយសារភាពនានា។ នៅក្នុងការធ្វើសេចក្តីសង្ខេបខ្លឹមសារនៃចម្លើយសារភាពទាំងនោះ ដើម្បីឲ្យមេដឹកនាំជាន់ខ្ពស់ទាំងនោះអាចក្តាប់បានអំពីផែនការក្បត់របស់ខ្មាំងដែលមានច្រើនជាអនេកប្បការ ដែលត្រូវបានគេស្មានថា បានលេចឡើងព្រោងព្រាតនៅទូទាំងប្រទេស។ គឺការវិភាគដូចនេះហើយដែលគេជះឥទ្ធិពលទៅលើការណែនាំឲ្យធ្វើការបោសសម្អាតនាពេលអនាគត។ ហើយគឺដោយសារតែការវិភាគនេះហើយដែលធ្វើឲ្យមានការចាប់ខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម និងការប្រហារជីវិតមួយលើកមួយលើកទៀតសាចុះសាឡើងវិលវល់។ ភាពអមនុស្សធម៌ត្រូវបានគេយកមកអនុវត្តក្នុងទ្រង់ទ្រាយដ៏ធំមួយនៅមន្ទីរស-២១។ អ្នកទោសភាគច្រើនដែលលាយចម្រុះគ្នាគឺជាប្រជាជនកម្ពុជា។ ពួកគេបានត្រូវជាប់ឃុំឃាំងនៅកន្លែងណាមួយនៅក្នុងមន្ទីរស-២១ ចាប់ពីពីរទៅបីថ្ងៃរហូតដល់ជាងមួយឆ្នាំ។ ទោះបីជាមធ្យមគឺមានពីច្រើនសប្តាហ៍រហូតដល់ពីរទៅបីខែក៏ដោយ។ ទារកត្រូវបានគេយកចេញពីឪពុកម្តាយ ហើយសម្លាប់ចោលដោយគ្មានញញើតដៃ។ ស្ត្រី និងកូនក្មេង គេមិនទុកជីវិតឲ្យនៅទេ។

[១០:០៩:៥៦]

ពួកអ្នកទោសវៀតណាមទាំងទាហាន ទាំងស៊ីវិល ត្រូវគេបង្ខំឲ្យឆ្លើយសារភាព ហើយចម្លើយរបស់ពួកគេត្រូវបានថតជាខ្សែភាពយន្ត ឬផ្សាយតាមវិទ្យុ ឬធ្វើជាផ្នែកនៃការឃោសនារបស់កម្ពុជាប្រជាធិបតេយ្យមុនពេលត្រូវគេសម្លាប់។

អ្នកទោសពីបស្ចិមប្រទេសក៏ត្រូវបានគេបង្ខំឲ្យឆ្លើយសារភាពដែលត្រូវបានគេសន្មតថាជាសកម្ម-

ភាពខ្លាំងក្នុងលក្ខខណ្ឌដូចគ្នាបេះបិទនឹងអ្នកទោសកម្ពុជាដែរ នៅមុនពេលត្រូវពិឃាដ ហើយសាកសពរបស់ពួកគេត្រូវគេដុតឲ្យទៅជាផេះ។

ជនជាប់ចោទបានព្រមទទួលថា គាត់គឺជាអ្នកដែលមានសិទ្ធិអំណាចយ៉ាងពេញលេញទាំងស្រុងទៅលើការរដ្ឋានព្រៃស ដែលជាបណ្តាញតភ្ជាប់ដែលត្រូវបានគេស្គាល់ផងដែរ ជាមន្ទីរស-២៤ ក្នុងស្រុកដង្កោ ខាងត្បូងទីក្រុងភ្នំពេញ។

ព្រៃសគឺជាកន្លែងដែលពួកគេចាប់ពីក្នុងជួរបក្សយកទៅ ជាពិសេសខាងយោធា ត្រូវគេឃុំខ្លួនទៅកាន់ទីនោះនៅមុនពេលដែលសេចក្តីសម្រេចជាស្ថាពរមួយស្តីពីការធ្វើទារុណកម្ម ឬប្រហារជីវិតពួកគេត្រូវបានធ្វើឡើង។ ដូចដែលជនជាប់ចោទបានទទួលសារភាពរួចហើយ ជនជាប់ឃុំនៅព្រៃស ដែលត្រូវបានគេស្គាល់ថាជាពួកសមាសភាពផ្សេងៗ ត្រូវបានគេបង្ខំឲ្យធ្វើការច្រើនម៉ោងជាងគេជាទីបំផុត ទៅតាមវាលស្រែ ដោយមានការតាមដានត្រួតមើលយ៉ាងតឹងរ៉ឹងជិតដល់បំផុត។ ទោះបីជាឃើញអ្នកទោសនៅទីនោះមិនមានជាប់ខ្នោះជើងរហូតដូចជាអ្នកទោសនៅមន្ទីរស-២១ក៏ដោយក្តី ក៏ពួកសមាសភាពផ្សេងៗនៅព្រៃស ត្រូវបានគេយាមកាមជាប្រចាំដែរ។ នៅក្នុងដំណាក់កាលណាក៏ដោយពួកអ្នកទោសទាំងនោះក៏អាចត្រូវគេបញ្ជូនទៅកាន់ជើងឯកដោយត្រង់តែម្តង ដើម្បីសម្លាប់ ឬដោយឆ្លងតាមមន្ទីរស-២១ ដើម្បីយកទៅធ្វើទារុណកម្មនិងសួរចម្លើយ។

មិនដែលមានអ្នកទោសណាម្នាក់ត្រូវបានដោះលែងពីព្រៃសទាល់តែសោះ តាមសម្តីរបស់ជនជាប់ចោទផ្ទាល់ថា ជនជាប់ឃុំបានបាត់បង់សិទ្ធិរបស់ខ្លួនទៅហើយ សេចក្តីសម្រេចមួយដើម្បីកម្ទេចពួកគេ។ ធ្វើបានពាក់កណ្តាលផ្លូវហើយ នៅពេលដែលពួកគេបានមកដល់ព្រៃសនេះ។ តាមពិត ហេតុផលពិតប្រាកដតែមួយគត់ប៉ុណ្ណោះ ដែលត្រូវទុកពួកគេ គឺដើម្បីឲ្យពួកគេធ្វើពលកម្មដោយបង្ខំសម្រាប់ផ្គត់ផ្គង់ស្រូវ និងដំណាំផ្សេងទៀតដល់មជ្ឈិមបក្ស។ ដោយសារតែរបបអាហារមានការខ្វះខាត គ្មានការផ្គត់ផ្គង់នូវគ្រឿងបរិក្ខាពេទ្យ ហើយស្ថានភាពធ្វើការងារមានសភាពក្តៅគគុកនោះ ភាគច្រើនត្រូវបានគេឲ្យធ្វើការរហូតខ្សោះអស់កម្លាំងពីខ្លួននៅមុនពេលដែលពួកគេត្រូវបញ្ជូនឲ្យទៅស្លាប់ដូច្នោះ ហើយត្រូវបានដាក់ជំនួសដោយអ្នកផ្សេងទៀត។ ដូចដែលជនជាប់ចោទទទួលស្គាល់ព្រមជាមួយគ្នានេះហើយដែលថាពីដំបូងពួកអ្នកទោសត្រូវបានគេសម្លាប់ និងត្រូវបានគេកប់នៅក្នុងជុំវិញបរិវេណមន្ទីរស-២១។

សំឡេងស្រែករបស់ជនរងគ្រោះ និងក្លិនស្អុយអសោចនៃគំរង់ជះក្លិនចេញពីសាកសពរលួយដែលគេកប់តាមរណ្តៅរាក់ៗ គឺប្រាកដជាបានកើតឡើងជាពុំខានពីពេលដំបូងៗនោះ។ ក៏ប៉ុន្តែមិនយូរប៉ុន្មាន

បន្ទាប់ គាត់បានក្លាយទៅជាលេខាក្នុងឆ្នាំ១៩៧៦។ ជនជាប់ចោទបានប្តូរកន្លែងប្រហារជីវិត និងកន្លែងកប់ខ្មោច ដែលសំខាន់យកទៅដាក់នៅកន្លែងថ្មីនៅឯជើងឯកវិញ។ ដែលមានចម្ងាយប្រហែល១៥គីឡូម៉ែត្រពីមន្ទីរស-២១ មួយផ្នែកគឺដើម្បីជៀសវាងការប្រថុយនឹងគ្រោះថ្នាក់នឹងជំងឺឆ្លង ប៉ុន្តែមិនបាច់ឆ្ងល់ទេ គឺដោយសារតែពីមូលហេតុមកពីពួកអ្នកជីករណ្តៅជុំវិញមន្ទីរស-២១ នោះអស់ទីកន្លែងសម្រាប់កប់ខ្មោចទៀតផង។

អ្នកទោសភាគច្រើនដែលនៅជុំវិញពីបទពិសោធន៍ឆ្លងកាត់ហេតុការណ៍ដ៏អាក្រក់ដែលគួរឲ្យព្រឺខ្លាចនៅមន្ទីរស-២១ ប៉ុន្តែនេះគឺគ្រាន់តែជាការពន្យារពេលជាបណ្តោះអាសន្នមួយរយៈសិនតែប៉ុណ្ណោះ។ ការសម្លាប់គឺភាពពិតប្រាកដមួយសម្រាប់ពួកគេគ្រប់ៗគ្នា ក៏ប៉ុន្តែយើងគ្រាន់តែអាចនឹងស្រមៃនៅក្នុងអារម្មណ៍ប៉ុណ្ណោះឃើញមើលថា ក្នុងអំឡុងពេលដែលពួកគេដែលជាប់នៅក្នុងការឃុំឃាំងដ៏សែនរងទុក្ខវេទនានិង ការធ្វើទារុណកម្មដ៏សែនសាហាវយង់ឃ្នងនោះ តើការនឹកគិតស្រមៃនៅក្នុងអារម្មណ៍របស់ពួកគេពីសេចក្តីស្លាប់ដែលលើសពីមួយពាន់ដងទៅទៀត វាបែបណាទៅ?

[១០:១៤:៥០]

គ្មានអ្នកទោសណាម្នាក់ដែលត្រូវបានគេដឹកតាមរថយន្តកាមីញ៉ុង យកចេញទៅកាន់វាលពិឃាដជើងឯកនៅពេលយប់បានរួចជីវិតដើម្បីនិយាយអំពីណាក់កាលចុងក្រោយនោះនោះទេ។ គឺមានតែឆ្មាំយាមគុក និងជនជាប់ចោទខ្លួនឯងផ្ទាល់តែប៉ុណ្ណោះ ដែលអាចមានលទ្ធភាពរៀបចំអំពីភ័ព្វវាសនាដែលជនរងគ្រោះទាំងឡាយបានទទ្ទឹងរង់ចាំ។ មកដល់ពេលនេះជាការគួរឲ្យអៀនខ្មាស់ណាស់ ដែលការរៀបរាប់របស់ពួកគេអាចនាំមកជូននូវការពិត អំពីកម្រិតនៃភាពភ័យខ្លាច និងការឈឺចុកចាប់ខាងផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកទោស គឺមិនទាន់ធ្វើបានល្អគ្រប់គ្រាន់នៅឡើយ។ តើមកដល់ចំណុចណាទើបជនរងគ្រោះទាំងនោះបានដឹង ពួកគេជិតត្រូវគេប្រហារជីវិតហើយនោះ? នៅពេលដែលពួកគេកំពុងតែអង្គុយនៅលើឡានតាមផ្លូវទៅកាន់វាលពិឃាដឬ? តើនៅពេលដែលពួកគេកំពុងត្រូវគេដាក់ឲ្យចុះពីលើរថយន្តហើយនាំចូលទៅកាន់ទីងងឹតឬ? ឬមួយនៅពេលដែលពួកគេកំពុងត្រូវបានគេទៅឲ្យរង់ចាំនៅក្នុងខ្ទមមួយ ដែលគេប្រើសំឡេងម៉ាស៊ីន ដើម្បីបង្ខំកាត់បន្ថយកុំឲ្យឮសំឡេងស្រែកថ្ងូររបស់អ្នកទោស ដែលគេនាំយកទៅមុនគេ។

ប្រាកដណាស់ ពួកគេត្រូវតែបានដឹង ព្រោះពួកគេត្រូវបាននាំយកទៅម្តងមួយៗ ហើយបង្ខំឲ្យលត់ជង្គង់នៅក្បែររណ្តៅប្រហារជីវិត ដែលជីវិតរបស់ពួកគេត្រូវឈានដល់ទីបញ្ចប់។ គ្មានអ្នកណាម្នាក់

អាចរត់ចេញពីជើងឯករួចបានទេ។ រាល់សាកសពនីមួយៗត្រូវបានគេត្រួតពិនិត្យមើលក្រែងមានសញ្ញាថា មិនទាន់ស្លាប់នៅឡើយ។ អ្នកទោសទាំងឡាយណាដែលមិនទាន់ស្លាប់ភ្លាមៗដោយសារវាយទៅលើកញ្ចឹងកត្រូវបានគេកាត់បំពង់ក និងវះពោះបើកចំហដោយកាំបិតត្នោត។ ម្យ៉ាងទៀត នៅជើងឯកជាទីតាំងមួយដែលស្ថិតនៅឯទីជនបទដ៏ស្ងប់ស្ងាត់ បានក្លាយទៅជាវាលពិឃាដ ដែលធ្វើជានិមិត្តរូបតំណាងឲ្យអំពើដ៏សាហាវយង់ឃ្នង អមនុស្សធម៌ ដែលបានសម្លាប់ប្រជាជនឯងអស់ដ៏ច្រើនសន្ធឹកសន្ធាប់។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់គោលបំណងនៃសវនាការអង្គជំនុំជម្រះក្តីនេះ ទីតាំងតែមួយកន្លែងនេះគឺមិនមែនគ្រាន់តែជានិមិត្តរូបប៉ុណ្ណោះទេ នៅក្រោមសិទ្ធិអំណាចរបស់ជនជាប់ចោទ ជើងឯកគឺជាទីដៅចុងក្រោយបង្អស់របស់អ្នកទោសមន្ទីរស-២១ ភាគច្រើនបំផុត។ មានអ្នកទោសប្រភេទខ្លះ តួយ៉ាងដូចជាមន្ត្រីរាជការជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា អ្នកទោសវៀតណាម និងអ្នកទោសខាងបស្ចិមប្រទេសនៅតែត្រូវបានយកទៅសម្លាប់ក្នុងបរិវេណនិងនៅជុំវិញទីស្នាក់ការធំនៃមន្ទីរស-២១ដដែល។ គ្រោងឆ្អឹងរបស់អ្នកទោសទាំងឡាយ ដែលគេបានសម្លាប់ជាយូរមកហើយ ឯកសណ្ឋានយោធាចាស់ៗ និងខ្នោះជើងត្រូវបានគេរកឃើញនៅតំបន់ដែលនៅជុំវិញមន្ទីរស-២១។ មេផ្ទះ ឬចុងភៅជាច្រើនដែលមកពីសង្កាត់ទួលស្លែងបានផ្តល់ចម្លើយដែលរៀបរាប់អំពីការរកឃើញរបស់ពួកគេ ដែលសភាពគួរឲ្យព្រឺខ្លាចនៅពេលដែលវិលត្រលប់មកកាន់គេហដ្ឋានរបស់ខ្លួនវិញបន្ទាប់ពីខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាច។

[១០:១៨:២៨]

ភ័ស្តុតាងដែលអង្គជំនុំជម្រះបានលើក បើកសវនាការបានស្តាប់ បានបង្ហាញភ័ស្តុតាងណាមួយថាអង្គហេតុដែលយើងទើបនឹងបានរៀបរាប់នោះ វាហួសពីវិមតិសង្ស័យ។ ឥឡូវនេះ យើងងាកមើលទៅដល់នីតិសម្បទាខាងផ្លូវច្បាប់នៃអង្គជំនុំជម្រះវិញ។ និយាយម្យ៉ាងទៀតថា តើអង្គជំនុំជម្រះនេះបញ្ជាក់ទៅលើបទឧក្រិដ្ឋអ្វីខ្លះ? សហព្រះរាជអាជ្ញាបានដាក់ជូនរួចហើយ នូវសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរមួយយ៉ាងល្អិតល្អន់រួចហើយ ដែលពិភាក្សាយ៉ាងលម្អិតអំពីរឿងនេះ។ ដូច្នេះ ធ្វើការបង្ហាញជូនដោយផ្ទាល់មាត់របស់យើងនាថ្ងៃនេះ និងធ្វើដោយសង្ខេបនូវអំណះអំណាងទាំងនេះជាជាងនិយាយសាជាថ្មីឡើងវិញទាំងស្រុង។

រាល់អង្គហេតុទាំងអស់ដែលបានរៀបរាប់មកទល់ពេលនេះ អាចនឹងត្រូវបានកំណត់នីតិសម្បទាថាជាបទព្រហ្មទណ្ឌនៅក្រោមច្បាប់ អ.វ.ត.ក។ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានកែ

ប្រែដោយសាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ បានរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិការធ្វើទារុណកម្ម និងអំពើមនុស្សឃាតដែលល្មើសនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានប្រព្រឹត្ត។

សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការបញ្ជាក់អះអាងអំពីឧក្រិដ្ឋកម្មទាំងនេះនៅក្នុងសាលដីការបស់ខ្លួន។ ឥឡូវនេះ សូមត្រឡប់ទៅមើលចំណាត់ថ្នាក់បទឧក្រិដ្ឋនីមួយៗវិញម្តង។

អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើការពិភាក្សាអំពីឋានុក្រមនៃឧក្រិដ្ឋកម្មអន្តរជាតិ គេមិនអាចបដិសេធបានឡើយថា បទឧក្រិដ្ឋជាក់លាក់មួយចំនួនធ្វើឲ្យមានស្លាកស្នាមទុរយសទាក់ទងនឹងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង។ ឧក្រិដ្ឋកម្មទាំងនេះមានលក្ខណៈធ្ងន់ធ្ងរជាខ្លាំង ដែលផលប៉ះបាល់មិនគ្រាន់តែត្រូវបានទទួលរងដោយជនរងគ្រោះជាបុគ្គលនិងក្រុមគ្រួសារ និងមិត្តភក្តិរបស់គេផ្ទាល់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែដោយមនុស្សជាតិទាំងមូលទៀតផង។ ឧក្រិដ្ឋកម្មតាំងឡាយបែបនេះ ដែលនៅក្នុងនោះរួមមានការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិទាំងមូល និងទៅលើទស្សនៈយល់ឃើញរបស់សហគមន៍នៃមនុស្សជាតិផ្ទាល់តែម្តងត្រូវបានគេស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អំពើដ៏ព្រៃផ្សៃដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ បានធ្លាក់ចូលដោយត្រង់ទៅក្នុងឧក្រិដ្ឋកម្មប្រភេទនេះ មាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់សិទ្ធិអំណាចឲ្យអង្គជំនុំជម្រះនេះ ដើម្បីជំនុំជម្រះជនសង្ស័យនានាចំពោះការប្រព្រឹត្តិនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាក់លាក់ចំនួនប្រាំបួនដាច់ៗដោយឡែកៗពីគ្នា។

[១០:២១:៤០]

ភ័ស្តុតាងបង្ហាញឲ្យឃើញហួសពីវិមតិសង្ស័យថា ឧក្រិដ្ឋកម្មចំនួនប្រាំពីរ ក្នុងចំណោមឧក្រិដ្ឋកម្មទាំងប្រាំបួននេះត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើអមនុស្សធម៌ផ្សេងៗទៀត ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម អំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ។ ដើម្បីឲ្យបទល្មើសទាំងប្រាំពីរ ដូចបានរៀបរាប់ខាងលើនេះ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គេត្រូវតែបង្ហាញឲ្យឃើញពីធាតុផ្សំខាងយុត្តាធិការបន្ថែមមួយចំនួនផងដែរ។ បទល្មើសដូចបានរៀបរាប់ខាងលើនេះត្រូវតែបានប្រព្រឹត្តជាផ្នែកមួយក្នុងការវាយប្រហារ ជាលក្ខណៈទូលំទូលាយឬជាប្រព័ន្ធដែលសំដៅប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយ ដោយសារមូលហេតុខាងជាតិសាសន៍នយោ

បាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា។ យើងនឹងពិភាក្សាអំពីបញ្ហានេះម្តងមួយៗ។

ឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរស-២១ផ្ទាល់ គ្មានអ្វីគួរឲ្យសង្ស័យទេថា ជាផ្នែកនៃឈុតនៃឧក្រិដ្ឋកម្មមួយ ដែលធំជាងនេះយ៉ាងសម្បើមដែលត្រូវបានប្រព្រឹត្តនៅក្នុងទូទាំងប្រទេស និងនៅក្នុងទូទាំងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល។ អ្វីដែលគេថា មាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានពង្រឹងការអនុវត្តនៅទូទាំងប្រទេសកម្ពុជាទាំងមូល ដែលក្នុងនោះមិនគ្រាន់តែមានការកម្ទេចខ្មាំង ដោយប្រើកងកម្លាំងសន្តិសុខនិងកម្លាំង និងបណ្តាញនៃមណ្ឌលសន្តិសុខតែប៉ុណ្ណោះទេ ក៏ប៉ុន្តែក្នុងចំណោមវិធីសាស្ត្រផ្សេងៗទៀតជាច្រើនរួមបញ្ចូលទាំងការជម្លៀសដោយបង្ខំ ការបង្ខាំងប្រជាជនតាមសហករណ៍ជនបទ និងការដ្ឋាននានាដោយខុសច្បាប់ ការធ្វើទៅជាទាសករ និងការបង្អត់អាហារ។ ទំហំភូមិសាស្ត្រនៃឧក្រិដ្ឋកម្មទាំងនេះគឺទូលំទូលាយណាស់ ដែលមិនអាចប្រកែកបានទេ។ ចំនួនជនរងគ្រោះសរុបក៏មានចំនួនធំសម្បើមស្រដៀងគ្នាដែរ តាមកម្រិតដែលឧក្រិដ្ឋកម្មនានានៅមន្ទីរស-២១ ត្រូវតែបានចាត់ទុកថា ជាផ្នែកនៅក្នុងឧក្រិដ្ឋកម្មទូទាំងប្រទេសទាំងមូលដែលមានទំហំធំជាងនោះត្រូវ តែបានចាត់ទុកថាឧក្រិដ្ឋកម្មទាំងនេះមានលក្ខណៈទូលំទូលាយ។ ទោះបីជាប្រសិនបើឧក្រិដ្ឋកម្មទាំងឡាយនៅមន្ទីរស-២១ ត្រូវបានគេយល់ឃើញថាដាច់ដោយឡែកពីគ្នានោះក្តី គេអាចត្រូវបានរៀបរាប់ដោយត្រឹមត្រូវបានថា មានលក្ខណៈទូលំទូលាយដែរ។ ជនរងគ្រោះនៅមន្ទីរស-២១ គ្រប់តំបន់ភូមិសាស្ត្រទាំងអស់នៃកម្ពុជាប្រជាធិបតេយ្យ ហើយជាក់ស្តែងគឺមកពីគ្រប់បណ្តាអង្គភាពរដ្ឋបាលយោធា និងស៊ីវិលទាំងអស់។

[១០:២៤:៣៤]

តាមឯកសារដែលមាននៅសល់ចំនួនស្លាប់ គឺមានយ៉ាងតិច១២.២៧៣នាក់ ដោយយកចិត្តដាក់ពិចារណាទៅលើអង្គហេតុទាំងនេះ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១ ទោះបីជាគេយល់ឃើញថាគឺជាអំពើអមនុស្សធម៌ផ្សេងៗ ដែលបន្ថែមទៀត ឬមួយក៏ជាអំពើអមនុស្សធម៌តែមួយគត់ដែលមានទំហំមិនធម្មតាមួយក្តី ក៏ឧក្រិដ្ឋកម្មទាំងនោះមានលក្ខណៈទូលំទូលាយដែរ។ បទល្មើសដូចបានរៀបរាប់ខាងលើនេះតម្រូវឲ្យចាត់ទុកផ្សេងពីនេះថា មានលក្ខណៈជាប្រព័ន្ធទៅវិញ ដើម្បីកំណត់នីតិសម្បទាថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើទោះបីជាត្រូវបានគេយល់ឃើញថា ជាផ្នែកនៃការពង្រឹងការអនុវត្តមាគ៌ានយោបាយ ដែលធំទូលំទូលាយជាងនៅក្នុងទូទាំងប្រទេសទាំងមូល ឬមួយក៏គ្រាន់តែមើលឃើញថាជាអំពើហិង្សា និងការធ្វើបាបរបស់មន្ទីរសន្តិសុខតែមួយគត់ក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងឡាយនៅមន្ទីរ

ស-២១ គ្មានអ្វីគួរឲ្យសង្ស័យទេ ត្រូវតែរៀបរាប់ថា មានលក្ខណៈជាប្រព័ន្ធ។

អំពើហិង្សា ការធ្វើបាប ការជម្លៀសចេញដោយបង្ខំ ការធ្វើឲ្យទៅជាទាសករ និងអំពើផ្សេងទៀត ត្រូវបានគេរៀបចំឡើង និងបង្កលក្ខណៈឲ្យអនុវត្តទៅតាមការសម្រេចដល់មជ្ឈិមបក្ស នៅក្នុងរង្វង់នៃមន្ទីរស-២១ដែលជាមន្ទីរសន្តិសុខមួយដាច់ដោយឡែកតែឯង ជនជាប់ចោទក្នុងនាមជាលេខា និងកម្មាភិបាលជាន់ខ្ពស់នានាជាកូនចៅរបស់គាត់បានធ្វើឲ្យប្រាកដថា សេចក្ដីណែនាំទាំងឡាយរបស់បក្ស ត្រូវតែបានអនុវត្តដោយមានវិធីសាស្ត្រ និងដោយភាពស្មោះត្រង់។

អំពើហិង្សានិងការធ្វើបាបទាំងពីរនេះ ត្រូវតែបានរៀបចំដោយប្រុងប្រយ័ត្ន ហើយត្រូវតែធ្វើជាដដែលៗ។ ជនជាប់ចោទបានបញ្ជាក់ថា គាត់បានដឹងគ្រប់មន្ទីរសន្តិសុខទាំងអស់ គឺបានដំណើរការតាមរបៀបដូចគ្នាតែមួយ ដោយសារតែមន្ទីរសន្តិសុខទាំងនោះ គេតម្រូវឲ្យអនុវត្តទៅតាមមាគ៌ារបស់បក្ស។ ដំណើរការក្នុងការចាប់ខ្លួន ឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្ម ចម្លើយសារភាព និងការប្រហារជីវិត មិនអាចធ្វើការកំណត់ចរិតលក្ខណៈរបស់វាតាមភាពសមហេតុសមផលថា ធ្វើឡើងដោយស្មានៗ ឬដោយចៃដន្យបានឡើយ ជាពិសេសនៅក្នុងរង្វង់មន្ទីរស-២១ ការរៀបចំទុកដាក់ ការរៀបចំចងក្រងឯកសារយ៉ាងហ្មត់ចត់ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីលក្ខណៈជាប្រព័ន្ធនៃឧក្រិដ្ឋកម្មទាំងនេះ។ បទល្មើសនានាដែលបានរៀបរាប់មកនេះ ក៏ត្រូវតែបានប្រព្រឹត្តជាផ្នែកមួយក្នុងការវាយប្រហារមួយដែលត្រូវតែចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។ តាមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ការវាយប្រហារមួយត្រូវបានកំណត់និយមន័យថា ដំណើរការនៃការប្រព្រឹត្តិមួយដែលនៅក្នុងនោះរួមមានអំពើហិង្សានៅក្នុងនោះផង។

[១០:២៧:៤៤]

ការវាយប្រហារ គឺមិនកម្រិតតែការប្រើប្រាស់នូវកម្លាំងប្រដាប់តែប៉ុណ្ណោះទេ ហើយក៏មិនតម្រូវថាត្រូវតែជាការវាយប្រហារដោយយោធាណាមួយនោះដែរ ឬក៏មិនកម្រិតថាជាផ្នែកមួយនៅក្នុងជម្លោះប្រដាប់អាវុធណាមួយនោះ។ ផ្ទុយទៅវិញ គឺវាគ្របដណ្ដប់ទៅលើការធ្វើបាបបែបណាមួយក៏ដោយទៅលើប្រជាជនស៊ីវិល។ ភ័ស្តុតាងដែលមិនអាចជជែកតវ៉ាបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញសក្ខីកម្មយ៉ាងច្បាស់ថា គឺមានការវាយប្រហារបែបដូចនេះមែន នៅក្នុងទូទាំងកម្ពុជាប្រជាធិបតេយ្យទាំងមូល ការធ្វើពលកម្មដោយបង្ខំ ការជម្លៀសដោយបង្ខំ អំពើហិង្សា និងការធ្វើបាបជនស៊ីវិល គឺជានិយាមសម្រាប់ការអនុវត្តជាក់ស្តែងរបស់បក្សកុម្មុយនីស្តកម្ពុជា។ ជាងនេះទៅទៀត ការបង្កើតការ

គ្រប់គ្រង និងកិច្ចប្រតិបត្តិការនៃមន្ទីរសន្តិសុខនានានៅក្នុងទូទាំងប្រទេស បាននាំមកដល់ការបង្កលក្ខណៈដើម្បីធ្វើឱ្យបានសម្រេចនូវការកៀបសង្កត់ក្នុងទ្រង់ទ្រាយធំមួយ។ នៅក្នុងរង្វង់នៃមន្ទីរស-២១ ខ្លួនឯងផ្ទាល់តែម្តងការវាយប្រហារ គឺត្រូវបានកំណត់ចរិតលក្ខណៈថា ត្រូវមានអំពើហិង្សាជាបុគ្គលចំនួនប្រហែលរាប់ម៉ឺន ឬរាប់សែន ដែលក្នុងនោះរួមមានការវាយដំ ការធ្វើទារុណកម្ម ការសម្លាប់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ដោយបានអនុវត្តជាលក្ខណៈប្រព័ន្ធ និងការកៀបសង្កត់បែបនេះផ្ទាល់តែម្តង ដែលបង្កើតបានជាការវាយប្រហារតាមគោលបំណង ដែលមានចែងនៅក្នុងមាត្រា៥ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិណាមួយ ក៏ត្រូវតែប្រឆាំងនឹងប្រជាជនស៊ីវិលណាមួយផងដែរ ក្នុងនោះគឺតម្រូវឱ្យប្រជាជនស៊ីវិលធ្វើជាគោលដៅ ជាសារវន្តនៃការវាយប្រហារ។

អង្គហេតុទាំងឡាយដែលត្រូវបានទទួលយល់ព្រម រួមជាមួយនឹងភ័ស្តុតាងរបស់លោក ក្រេក អេតឆេសាន់ គឺបានបង្ហាញភ័ស្តុតាងឱ្យឃើញយ៉ាងច្បាស់ថា ការវាយប្រហាររបស់បក្សកុម្មុយនីស្តកម្ពុជា នៅតាមបណ្តាសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខនានា និងនៅក្នុងមន្ទីរស-២១ផ្ទាល់គឺសុទ្ធតែសំដៅទៅលើប្រជាជនទាំងមូលរបស់ប្រទេសកម្ពុជា ដែលក្នុងនោះចំនួនច្រើនលើសលប់គឺជាជនស៊ីវិល។ ការវាយប្រហារនេះ បានចាប់ផ្តើមឡើងដោយការជម្លៀសចេញដោយបង្ខំឱ្យប្រជាជនស៊ីវិលទាំងអស់ឱ្យចេញពីទីក្រុងភ្នំពេញនិងពីទីក្រុងដទៃទៀត។ ការធ្វើឱ្យប្រជាជនរបស់ប្រទេសទាំងអស់ក្លាយជាទាសករនៅក្នុងសហករណ៍ និងការដ្ឋាននានា ការលុបបំបាត់ចោលទាំងអស់នូវបញ្ញវន្តមូលធន និងមនុស្សដែលធ្លាប់ជាប់ពាក់ព័ន្ធជាមួយនឹងរដ្ឋាភិបាលចាស់។

បន្ទាប់ពីការវាយប្រហារបែបនេះធ្វើឱ្យបានសម្រេចហើយនោះ ហើយដូចដែលយើងបានលើកមកពិភាក្សាគ្នារួចហើយ ការវាយប្រហារទាំងនោះ គឺបានសំដៅទៅលើបុគ្គលទាំងឡាយដែលនៅក្នុងរង្វង់សហករណ៍ ការដ្ឋាននានា និងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាខ្លួនឯង អ្នកដែលត្រូវបានគេយល់ឃើញថា ជាខ្មាំងរបស់រដ្ឋដ៏មានសក្តានុពល។

[១០:៣១:០៨]

សញ្ញាណអំពីប្រជាជនស៊ីវិល តាមគោលបំណងនៃធាតុផ្សំខាងយុត្តាធិការ នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចង់សំដៅទៅលើរាល់មនុស្សគ្រប់រូបទាំងអស់ ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ប្រជាជនដែលស្ថិតនៅក្រោមការវាយប្រហារ អាចរួមបញ្ចូលផងដែរនូវជនទាំងឡាយ

ណាដែលមិនមែនជាជនស៊ីវិល ដែលពួកមិនមានការបាត់បង់ចរិតលក្ខណៈជាជនស៊ីវិលទេ ដរាបណានៅក្នុងចំណោមប្រជាជននោះមានជនស៊ីវិលភាគច្រើនលើសលប់។

ក្នុងបញ្ជីឈ្មោះអ្នកទោសស-២១ជាច្រើនបង្ហាញថា ក្រុមជនជាប់ឃុំឃាំងដែលធំជាងគេបង្អស់តែមួយគត់នោះ គឺក្រុមរបស់កម្មាភិបាលដែលមកពីរដ្ឋការស៊ីវិលរបស់កម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីនេះសូម្បីតែនៅក្នុងរង្វង់មន្ទីរស-២១ក៏ដោយ ក៏គោលដៅនៃការវាយប្រហារភាគច្រើនលើសលប់ គឺជាជនស៊ីវិលដែរ។

លក្ខខណ្ឌតម្រូវមួយចំនួនខាងយុត្តាធិការអំពីទីតិសម្បទា និងការវាយប្រហារត្រូវតែបានប្រព្រឹត្តដោយផ្អែកលើមូលដ្ឋាននៃការរើសអើងណាមួយ។ ការរើសអើងនោះតែងតែផ្អែកលើមូលដ្ឋានខាងជាតិសាសន៍នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា។

លោកប្រធានតើត្រូវសម្រាកបន្តិចដែរអត់ទេលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បើអ៊ីចឹង សម្រាកបន្តិចទៅណា៎។ ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះសាលាដំបូងប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃនាទីសូមអញ្ជើញចូលវិញ--ខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៣៣នាទី ដល់ម៉ោង ១១:០០នាទី]*

[១១:០២:០០]

**ប្រធានអង្គជំនុំ៖**

សូមបិទវាំងននសិនទៅ ហើយផ្ដាច់ប្រព័ន្ធសំឡេងកុំឲ្យផ្សាយចេញទៅខាងក្រៅ។

*(គ្មានសំឡេង)*

[១១:០៦:៤៦]

**ប្រធានអង្គជំនុំ៖**

...បាទសឹមយើងចាប់ផ្ដើមបន្តនូវដំណើរការសវនាការតទៅទៀត ហើយជាបន្តនេះសូមអញ្ជើញ

សហព្រះរាជអាជ្ញាជាតិដើម្បីបន្តធ្វើសេចក្តីថ្លែងការណ៍នូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមអរគុណនិងសូមអនុញ្ញាតបន្តទៀត។

ភ័ស្តុតាងដែលនៅចំពោះមុខអង្គជំនុំជម្រះបង្ហាញឲ្យឃើញថា បក្សកុម្មុយនីស្តកម្ពុជាបានធ្វើការវាយប្រហារលើប្រជាជនស៊ីវិលដោយសារមូលហេតុខាងនយោបាយ សាសនា និងខាងជាតិពន្ធទៅតាមបណ្តាសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខនានានៅក្នុងទូទាំងប្រទេសកម្ពុជា ដែលរួមទាំងមន្ទីរស-២១ និងព្រៃសផង។ ការវាយប្រហារនេះ គឺត្រូវបានជំរុញទឹកចិត្តដោយសហគមន៍ខាងនយោបាយបក្សកុម្មុយនីស្តកម្ពុជាបានចូលរួមនៅក្នុងការធ្វើទុក្ខបុកម្នេញជាប្រព័ន្ធ ដោយការធ្វើទុក្ខបុកម្នេញខាងនយោបាយ ដោយស្វែងរកយ៉ាងណា យ៉ាងសកម្ម ដោយការដាក់ក្នុងមន្ទីរឃុំឃាំង និងប្រហារជីវិតមនុស្សទាំងអស់ដែលត្រូវបានគេចាត់ទុកថាជាខ្មាំង ឬម្យ៉ាងទៀតថា ជាសមាសភាពដែលគេមិនចង់បាន។ នេះគឺរាប់បញ្ចូលនូវអតីតទាហាន និងមន្ត្រីនៃសាធារណរដ្ឋខ្មែរ ក៏ដូចជាកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា យុទ្ធជន និងកម្មករដែលត្រូវបានគេបោសសម្អាត ដោយសារគេសន្និដ្ឋានថា មាននិន្នាការក្បត់។

បក្សកុម្មុយនីស្តកម្ពុជាក៏បានអនុវត្តនូវគោលនយោបាយរើសអើងខាងជាតិពន្ធប្រឆាំងនឹងជនជាតិវៀតណាមដើម្បីធ្វើការបោសសម្អាតទូទាំងប្រទេសឲ្យអស់ អ្នកដែលគេជឿថាគាំទ្រវៀតណាម។

អាចទាញជាសេចក្តីសន្និដ្ឋានថា បក្សកុម្មុយនីស្តកម្ពុជាក៏បានចូលរួមផងដែរនៅក្នុងការធ្វើទុក្ខបុក ម្នេញខាងសាសនា។ រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ បានហាមឃាត់រាល់សាសនាប្រតិកិរិយាទាំងអស់ ដែលជនជាប់ចោទបានថ្លែងថា ត្រូវតែមានន័យ ហើយរួមបញ្ចូលទាំងអ៊ីស្លាម និងគ្រិស្តសាសនិកផងដែរ។ ក៏ប៉ុន្តែ តាមជាក់ស្តែងគឺមិនមានការអនុគ្រោះដល់សាសនាណាមួយឡើយដែលរួមទាំងពុទ្ធសាសនិកផង។ ជនជាប់ចោទ បានថ្លែងនៅក្នុងពេលដែលកំពុងដំណើរការសវនាការចំពោះមុខសហចៅក្រមស៊ើបអង្កេតថា គ្មាននរណាម្នាក់ប៉ានអនុវត្តការប្រតិបត្តិសាសនាដោយចំហនោះទេ នៅក្នុងអំឡុងពេលនៃរបបនេះ ហើយថា ប៉ុល ពត បានលុបបំបាត់ចោលនូវសាសនាផ្សេងៗ ព្រមទាំងមានផែនការនឹងបំផ្លាញចេតីយនៅលើកំពូលវត្តភ្នំផ្សេងទៀតផង ដើម្បីយករូបសំណាកកុម្មុយនីស្តណាមួយមកដាក់ជំនួសវិញ។

ដើម្បីឲ្យបទល្មើសនានាដែលបានរៀបរាប់មកនេះត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

ជាតិក្រោមច្បាប់អន្តរជាតិ គឺថាវីត្រូវតែបានដឹងពីអត្ថិភាពនៃការវាយប្រហារទៅលើប្រជាជនស៊ីវិលជាមួយថ្នាក់លើនានារបស់ខ្លួននៅក្នុងឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានចូលរួមក្នុងអង្គប្រជុំផ្សេងៗជាមួយបណ្តាអង្គភាពនានារបស់រដ្ឋាភិបាល និងយោធានៃកម្ពុជាប្រជាធិបតេយ្យ។ ការប្រជុំ និងការប្រើប្រាស់ការទាក់ទងទាំងនេះ បានផ្តល់ព័ត៌មានដល់គាត់អំពីស្ថានភាពនៅផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា។

ជាងនេះទៅទៀត ជនជាប់ចោទ គឺជាអ្នកដែលបានដឹងដោយលម្អិតដែលមិនធ្លាប់បានដឹងពីមុនមក និងតែម្នាក់គត់អំពីសភាពការណ៍នៅក្នុងទូទាំងប្រទេសកម្ពុជាទាំងមូល តាមរយៈការអានយ៉ាងល្អិតល្អន់នូវចម្លើយសារភាពរបស់អ្នកទោសនានា។

[១១:១១:២៦]

សក្ខីកម្មទាំងស្រុងរបស់គាត់បានបញ្ជាក់អះអាងថា គាត់បានដឹងយ៉ាងពេញលេញអំពីបរិបទនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល។ ជនជាប់ចោទក៏បានដឹងផងថា អំពើទាំងឡាយរបស់ខ្លួន គឺជាផ្នែកនៅក្នុងការវាយប្រហារនោះដែរ។ គាត់បានដឹង ហើយបានទទួលដែរផ្តល់ជាភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថានៅមន្ទីរស-២១ បានជួយ និងបង្កលក្ខណៈងាយស្រួលដល់ការបោសសម្អាត ដោយសារការកំណត់អត្តសញ្ញាណពួកអ្នកដែលគេចោទថាជាខ្មាំង។ ដោយផ្អែកទៅលើមូលដ្ឋាននៃចម្លើយសារភាពដែលស្រង់សម្រាប់គោលបំណងដ៏ជាក់លាក់នៅមន្ទីរស-២១។

ឥឡូវនេះ ចូរយើងងាកមកមើលបទល្មើសនានាដែលបានរៀបរាប់មកនេះ ដោយដាច់ឡែកពីគ្នានោះ ដែលនៅក្នុងវង្វង់ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់តាមរយៈករណីរឿងនេះ។ ការដាក់នៅក្នុងមន្ទីរឃុំឃាំង កំណត់ហេតុទាំងឡាយរបស់អ្នកទោសដែលនៅរស់មិនមានលក្ខណៈពេញលេញទេ។ ហើយយើងដឹងថាឈ្មោះរបស់ជនជាប់ឃុំខ្លះ មិនដែលត្រូវគេកត់ចូលនោះឡើយ។ តួរលេខមានជនជាប់ឃុំ១២.២៧៣នាក់ ត្រូវបានប្រមូលចងក្រងពីឯកសារនានា ដែលទំនងជាដាក់តាមតួរលេខប៉ាន់ប្រមាណដែលទាបជាងជាក់ស្តែង រាប់ការដកហូតនូវសេរីភាពនៅមន្ទីរស-២១ គឺត្រូវបានធ្វើឡើងតាមទំនើងចិត្ត អ្នកទោសទាំងឡាយត្រូវ បានគេចាប់ខ្លួន ព្រោះតែពួកគេត្រូវបានគេចាត់ទុកថាជាខ្មាំង។ បទល្មើសដែលត្រូវបានគេសន្មតជាទូទៅ បែបនេះ គឺមិនដែលមានរៀបរាប់នៅក្នុងច្បាប់ ឬក្នុងលក្ខន្តិកៈណាមួយនោះទាល់តែសោះ។ ពួកអ្នកទោសនៅមន្ទីរស-២១ មិនដែលបានតវ៉ាទៅនឹងការដាក់ពួកគេនៅក្នុងមន្ទីរឃុំឃាំងទេ ពីព្រោះមិនដែលមានប្រព័ន្ធច្បាប់ណាមួយ

ដែលបានដំណើរការទាល់តែសោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ក្នុងនាមជាមេបញ្ជាការនៃមន្ទីរស-២១ ជនជាប់ចោទបានធ្វើការដកហូតសេរីភាពរបស់អ្នកទោសតាមតែទំនើងចិត្ត ជនជាប់ចោទបានទទួលយល់ព្រមហើយថា ក្នុងការឃុំខ្លួនពួកគេនោះ គឺគ្មានមូលដ្ឋានខាងផ្លូវច្បាប់ទេ ហើយក៏មិនមានមធ្យោបាយណាមួយដែលអាចឲ្យអ្នកទោសនៅស-២១ ធ្វើ ការតវ៉ាទៅនឹងការដាក់ពួកគេក្នុងមន្ទីរឃុំឃាំងនោះដែរ។

[១១:១៤:១៩]

**អំពើអមនុស្សធម៌ផ្សេងៗទៀត**

មុននឹងយើងងាកទៅរកបទឧក្រិដ្ឋហិង្សានានាដែលត្រូវបានទទួល ស្គាល់នៅមន្ទីរស-២១ ប្រភេទអំពើអមនុស្សធម៌ផ្សេងៗទៀត គឺជាប្រភេទដែលនៅសេសសល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងភាពធ្ងន់ធ្ងរនៃអំពើនានាដែលបានរៀបរាប់មកយ៉ាងជាក់លាក់នេះ។ បទឧក្រិដ្ឋប្រភេទនេះឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ ជាក់លាក់នូវអំពើព្រៃ ផ្សៃដ៏ច្រើនហួសហេតុដែលត្រូវបានអនុវត្តនៅមន្ទីរស-២១។ នៅក្រោមអំណាចរបស់ជនជាប់ចោទ ការឈឺចាប់តាមផ្លូវកាយ និងផ្លូវចិត្តដ៏ធ្ងន់ធ្ងរតាមគ្រប់រូបភាព ត្រូវបានគេធ្វើទៅលើ ព្រមទាំងការបង្កើតឡើងនូវលក្ខខណ្ឌនៃការឃុំខ្លួនដ៏សែនទារុណនានាផងដែរ។ ដែលជាក់ស្តែងលក្ខខណ្ឌទាំងនោះមានលក្ខណៈអមនុស្សធម៌ជាទីបំផុត។ ការឈឺចាប់នេះមិនមែនជាចៃដន្យនោះទេ វាជាការគិតគូជាមុន ហើយតាមអង្គហេតុពិតបានបណ្តាលឲ្យមានការឈឺចាប់ និងទុក្ខព្រួយអតិបរមា។

អំពើអមនុស្សធម៌នានាដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ គឺធ្វើឲ្យគ្រប់គ្នាមានការរន្ធត់ ក៏ប៉ុន្តែបើប្រមូលគ្នាទៅ អំពើអមនុស្សធម៌ទាំងនោះបានបន្សល់ទុកឲ្យពួកយើងនូវភាពគ្មានគុណធម៌ និងភាពសាហាវឃោរឃៅដែលគួរឲ្យមានការងឿងឆ្ងល់ដែលស៊ីជម្រៅពិតប្រាកដ។ វាជាការងឿងឆ្ងល់ដ៏តិចតួចតែប៉ុណ្ណោះ ដែលមានអ្នកទោសខ្លះបានប៉ុនប៉ងធ្វើអត្តឃាដជាជាងបន្តទទួលរងនូវការឈឺចាប់ដ៏ខ្លាំងក្លាថែមទៀត។ ត្រួតគ្នាដោយគ្មានឈប់ឈរបែបដូច្នេះ។

[១១:១៦:៥៩]

ដោយមានភស្តុតាងគាំទ្រ យើងនឹងធ្វើការសង្ខេបនូវតួយ៉ាងបែបមួយចំនួន។ ការបង្កើតឡើងនូវលក្ខខណ្ឌនៃការឃុំខ្លួនដែលមានលក្ខណៈអមនុស្សធម៌ ជាក់ស្តែងដោយការដាក់យ៉ាងណែនចង្អៀត និងការខ្វះខាតអាហារ អនាម័យ និងការព្យាបាលផ្នែកសុខភាព។ ការហាមឃាត់ដោយបង្ខំ ដោយល្អានពាន

និងដោយសម្ងហាភាពនៅក្នុងអំឡុងពេលនៃការឃុំខ្លួន។ អំពើហិង្សាលើរាងកាយមិនចាំបាច់ បណ្តោយស្រេចតែចិត្តនៅក្នុងអំឡុងពេល និងក្រោយពេលសួរចម្លើយ។

ការបួមឈាមដោយបង្ខំ និងការធ្វើពិសោធន៍កាយវិភាគលើមនុស្សរស់ ការបង្កើតនូវបរិយាកាសភ័យខ្លាចមួយនៅមន្ទីរស-២១ តាមរយៈការដាក់ឱ្យការអនុវត្តនូវប្រព័ន្ធវិន័យមួយដ៏តឹងរ៉ឹង និងតាមរយៈការបំភិតបំភ័យ និងការគំរាមកំហែងដល់ពួកអ្នកទោស។ ការរំលោភទៅលើផ្លូវចិត្ត តាមរយៈការឃុំឃាំងពួកអ្នកទោសនៅក្នុងបន្ទប់ឃុំឃាំងតែមួយ ឬក្នុងបន្ទប់ឃុំឃាំងដែលជាប់គ្នា ជាមួយនិងអ្នកដែលកំពុងត្រូវបានធ្វើទារុណកម្ម អ្នកដែលធ្លាប់ត្រូវបានធ្វើទារុណកម្ម ឬជាអ្នកដែលបានស្លាប់ដោយសារការធ្វើទារុណកម្ម ដោយជំងឺ ឬដោយកង្វះម្ហូបអាហារ។

អំពើអមនុស្សធម៌បែបទាំងនេះ ទោះបីជាត្រូវបានមើលជាលក្ខណៈដាច់ដោយឡែកៗក្តី ជារួមក្តីគឺពិតជាមានលក្ខណៈធ្ងន់ធ្ងរទាំងអស់។ អំពើទាំងនោះត្រូវបានប្រព្រឹត្តឡើងដោយជនជាប់ចោទក្នុងឋានៈជាប្រធានមន្ទីរស-២១ និងដោយពួកថ្នាក់ក្រោមរបស់គាត់ទៅតាមសិទ្ធិអំណាចផ្ទាល់របស់គាត់។ គាត់បានចេញបញ្ជាផ្ទាល់ទៅកាន់ថ្នាក់ក្រោមរបស់គាត់ឱ្យធ្វើការបំភិតបំភ័យ គំរាមកំហែង និងប្រើអំពើហិង្សា។ គាត់បានដឹងទាំងស្រុងនូវលក្ខខណ្ឌទាំងឡាយដែលពួកអ្នកទោសត្រូវបានជាប់ឃុំឃាំង និងត្រូវបានសួរចម្លើយ។ ក្នុងឋានៈជាប្រធានមន្ទីរស-២១ គាត់មានចេតនាក្នុងការបង្កើត និងគ្រប់គ្រងលើប្រព័ន្ធមួយដែលមានការប្រព្រឹត្តិមិនល្អ ភ័ស្តុតាងបានបង្ហាញថា ទោះជាត្រូវបានផ្តល់នូវសិទ្ធិអំណាចយ៉ាងជាក់លាក់ក្តី គឺត្រូវបានបណ្តោយ ឬត្រូវបានអត់ឱនឱ្យមិនបានច្បាស់លាស់ក្តី។ អំពើអមនុស្សធម៌ដ៏ជាក់លាក់ទាំងនេះ គឺពិតជាផ្នែកមួយនៃសេចក្តីវន្ទត់ តក់ស្លុតនៃមន្ទីរស-២១។

[១១:១៩:៤៣]

**អំពីការធ្វើឱ្យទៅជាទាសករ**

ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើឱ្យទៅជាទាសករត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១។ ការធ្វើឱ្យទៅជាទាសករត្រូវបានឱ្យនិយមន័យថាជាការប្រើប្រាស់ដោយចេតនានូវអំណាចដែលជាម្ចាស់ទៅលើបុគ្គលណាមួយ និងរៀបរាប់បានយ៉ាងល្អបំផុត អំពីលក្ខខណ្ឌនានាដែលពួកអ្នកទោសនៅមន្ទីរស-២១ បានរស់នៅប៉ុណ្ណោះ។ ទិដ្ឋភាពនៃការរស់នៅរបស់ពួកអ្នកទោសនៅមន្ទីរស-២១ត្រូវបានគេត្រួតពិនិត្យ ពួកអ្នកទោសត្រូវបានគេដាក់នៅក្នុងបន្ទប់ឃុំឃាំង ហើយត្រូវបានយាមកាមជាប់ជានិច្ច។ ពួកគេត្រូវបានបង្ខាំងដោយប្រើខ្នោះដៃ និងខ្នោះជើង

បទវិន័យតឹងរ៉ឹងជាទីបំផុត ពួកអ្នកទោសមិនត្រូវបានគេអនុញ្ញាតឲ្យនិយាយ ឬធ្វើឲ្យឮសំឡេងខ្លាំង ឬដើរហើរដោយគ្មានការអនុញ្ញាតនោះទេ។

ពួកអ្នកទោសរស់នៅក្នុងស្ថានភាពមួយដ៏ស្មោកគ្រោកពុំមានអនាម័យ ការងូតទឹកគឺមានអ្នកយាមគុកបាញ់ទឹកតាមទុយោទៅលើពួកជាប់ឃុំនៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ នៅពេលដែលពួកគេកំពុងចាប់ខ្នោះជើងនៅឡើយ។ ពួកអ្នកទោសត្រូវតែសុំការអនុញ្ញាត ដើម្បីធ្វើការបន្ទោបង់ ទោះបីបន្ទោបង់តូច ឬធំ ទាំងជាប់ច្រវាក់នៅក្នុងបន្ទប់ឃុំឃាំងរបស់ពួកគេ។ ការផឹកទឹក បានផ្តល់ទៅតាមការសម្រេចរបស់អ្នកយាម អាហារមិនគ្រប់គ្រាន់តាមការស្រេកឃ្លានទេ។ លក្ខខណ្ឌនៃការឃុំខ្លួនបែបដូច្នេះ គឺវាជ្រុលហួសពីអ្វីដែលមន្ទីរឃុំឃាំងមួយត្រូវមានការតាមស្រមស្រប ឬតាមការចាំបាច់។ ការត្រួតត្រាក្នុងកម្រិតនេះទៅលើពួកអ្នកទោស គឺបានដកហូតចេញទាំងស្រុងនូវឆន្ទៈរបស់ពួកគេ។

ស្រដៀងគ្នានេះដែរ នៅព្រៃស ពួកអ្នកទោសត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងលក្ខខណ្ឌមួយដែលហត់នឿយយ៉ាងខ្លះ ដែលស្ថិតនៅក្រោមការគំរាមកំហែង សម្លាប់ជាប់ជាប្រចាំ។ ពួកអ្នកទោសធ្វើស្រែ និងចម្ការដើម្បីបំពេញទៅតាមកូដតាផលិតផលរបស់មន្ទីរស-២១ ទោះបីជាពួកគេមិនដែលបានទទួលផលប្រយោជន៍អ្វីពីពលកម្មពួកគេក៏ដោយ។ ការធ្វើមិនបានសម្រេចទៅតាមកូដតាការងារ ដោយអ្នកទោសណាម្នាក់ នោះនឹងនាំឲ្យមានការដាក់ទណ្ឌកម្មលើរាងកាយយ៉ាងធ្ងន់ធ្ងរ សូម្បីតែពួកស្ត្រី និងពួកកុមារក៏ដោយ។ ពួកអ្នកទោសត្រូវស្ថិតនៅក្រោមការធ្វើបាបដោយអមនុស្សធម៌ និងការខ្វះខាតអាហារ និងការសម្រាក។ ស្ថានភាពរបស់ពួកគេពិតជាអាចត្រូវបានពិពណ៌នាថា ដូចជាស្ថានភាពនៃទាសករដូច្នេះដែរ។ ជនត្រូវចោទខ្លួនឯង និងតាមរយៈថ្នាក់ក្រោមរបស់ខ្លួន មានចេតនាអនុវត្តនូវភាពជាម្ចាស់បែបនេះ និងត្រួតត្រាទាំងស្រុងទៅលើពួកអ្នកទោស។ គាត់បានដាក់វិធាននានាឲ្យអនុវត្ត ដែលបានដកហូតសេរីភាពពីការគ្រប់គ្រងលើជីវិតផ្ទាល់ខ្លួននៃពួកអ្នកទោសនៅមន្ទីរស-២១។ គាត់បានដឹងទាំងស្រុងថា ពួកអ្នកជាប់ឃុំឃាំងត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងគុក ជាពិសេសនៅព្រៃស គឺធ្វើការគ្រាន់តែដើម្បីបំពេញតាមកូដតាផលិតផលប៉ុណ្ណោះ។

[១១:២៣:១៩]

**អំពីការរំលោភខាងផ្លូវភេទ**

ដូចដែលបានពិភាក្សាដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរកាលពីម្សិលមិញនូវបទឧក្រិដ្ឋរំលោភខាងផ្លូវភេទ ដែលបានកើតឡើងផងដែរនៅមន្ទីរស-២១។ ផ្ទុយទៅវិញ សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សា

ដេញដោលរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ យើងបានពិភាក្សាភ័ស្តុតាងនៃការរំលោភខាងផ្លូវភេទនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ពិភាក្សាដេញដោលរបស់ការិយាល័យសហព្រះរាជអាជ្ញា ហើយយើងសន្និដ្ឋានថា ការរំលោភខាងផ្លូវភេទពិតជាបានកើតឡើងប្រាកដមែន ដែលភ័ស្តុតាងនេះពិតជាមាន ហើយជឿជាក់បានដែលបានរកឃើញនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត។ នៅក្នុងអំឡុងពេលជំនុំជម្រះករណីរំលោភខាងផ្លូវភេទ បានកើតឡើងនៅមន្ទីរស-២១ ដោយមិនមានការដាក់ទោសពីជនជាប់ចោទចំពោះអ្នកប្រព្រឹត្ត។

ដោយយោងទៅតាមអង្គហេតុខាងលើនេះ គឺវាហួសពីវិមតិសង្ស័យហើយ ដែលបទឧក្រិដ្ឋនេះវាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះ ក្នុងនាមជាមេកើយ ឬជាអ្នកបញ្ជា។

**អំពីការធ្វើទារុណកម្ម**

សូមពិនិត្យទៅលើឧក្រិដ្ឋកម្មមួយ ក្នុងចំណោមបទឧក្រិដ្ឋធំៗជាក់ស្តែងចំនួនពីរ ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ គឺការធ្វើទារុណកម្ម ជាបទឧក្រិដ្ឋមួយប្រឆាំងនឹងមនុស្សជាតិ ដែលតម្រូវឲ្យមានសក្ខីកម្មតែធាតុផ្សំចំនួនបីគឺ៖

ទីមួយ អំពើ ឬការខកខាន ត្រូវតែបង្កឲ្យមានរបួស ឬការឈឺចាប់យ៉ាងធ្ងន់ធ្ងរខាងផ្លូវកាយ ឬមួយខាងផ្លូវចិត្ត។ ទីពីរ អំពើ ឬការខកខាននោះ ត្រូវតែធ្វើឡើងដោយចេតនា។ និងទីបី អំពើ ឬការខកខាននោះ ត្រូវតែបានអនុវត្តដោយមានគោលបំណងយ៉ាងជាក់លាក់ ដូចជា ដើម្បីឲ្យបានព័ត៌មាន ឬចម្លើយសារភាព ដើម្បីដាក់ទណ្ឌកម្ម ដើម្បីបំភិតបំភ័យ ឬបង្ខិតបង្ខំជនរងគ្រោះ ឬជនទីបី ឬដើម្បីធ្វើការរើសអើង ដោយឈរលើមូលដ្ឋានណាមួយក៏ដោយ ទៅលើជនរងគ្រោះ ឬជនទីបី។

[១១:២៥:៣២]

វាមិនមានអ្វីដែលត្រូវជជែកទៀតទេ ដែលថាអំពើទារុណកម្ម ដែលមាននិយមន័យយ៉ាងល្អិតល្អន់ត្រូវបានគេយកទៅអនុវត្តនៅមន្ទីស-២១ ដោយឈរលើមូលដ្ឋានមួយដែលប្រកបដោយចេតនា និងដែលមានលក្ខណៈជាប្រព័ន្ធ ការធ្វើទារុណកម្ម និងមានលក្ខណៈជាប្រចាំ និងជាផ្នែកមួយនៃវប្បធម៌របស់មន្ទីរស-២១។ វាគឺជាឧបករណ៍ដ៏សំខាន់មួយក្នុងការបង្ខំឲ្យពួកអ្នកទោសឆ្លើយសារភាព។ ដូចដែលយើងនឹងបង្ហាញនៅពេលធ្វើការពិភាក្សាអំពីការទទួលខុសត្រូវរបស់គាត់ ជាបុគ្គលលើផ្នែកព្រហ្មទណ្ឌជនជាប់រូបនេះ គឺជាមជ្ឈដ្ឋានសំខាន់ចំពោះគ្រប់អំពើទារុណកម្មទាំងអស់ ដែលត្រូវអនុវត្តនៅមន្ទីរស-២១។ គាត់

បានបង្រៀនអំពីវិធីសាស្ត្រធ្វើទារុណកម្មដល់ពួកបុគ្គលិករបស់គាត់ និងអំពីរបៀបប្រើប្រាស់នូវបច្ចេកទេសធ្វើទារុណកម្មយ៉ាងណា ដើម្បីឲ្យបានចម្លើយសារភាពនានាដែលគួរឲ្យទុកចិត្តបាន។ សូម្បីតែខ្លួនគាត់ផ្ទាល់ ក៏គាត់បានធ្វើបាបទៅលើពួកអ្នកទោសផងដែរ។ តាមរយៈនេះបណ្តាលឲ្យកើតមានជាបរិយាកាសនៃនិទ្ទណ្ឌភាព។ ពេញមួយដំណើរការនៃនីតិវិធី ជនជាប់ចោទរូបនេះកាន់តែបង្កើនឡើងជាប់ជានិច្ចនូវការទទួលស្គាល់ ជាក់ស្តែងគ្រប់ទម្រង់ទាំងអស់នៃការធ្វើទារុណកម្ម ដែលសាក្សីនានាបានរៀបរាប់ គឺសុទ្ធតែត្រូវបានអនុវត្តនៅក្រោមសិទ្ធិអំណាចរបស់គាត់នៅមន្ទីរស-២១។ នៅតាមច្បាប់អន្តរជាតិមេគុកមានការទទួលខុសត្រូវមួយ ដើម្បីការពារពួកអ្នកទោសឲ្យរួចផុតពីការរំលោភដោយខុសច្បាប់ និងធានាថាលក្ខខណ្ឌនានានៃការរស់នៅត្រូវតែប្រកបដោយមនុស្សធម៌។ វាជាការច្បាស់ណាស់ដែលថា មិនដែលមានចេតនាណាមួយដែលចង់ឲ្យមានការគ្រប់គ្រងពួកអ្នកទោសស-២១ តាមបែបមនុស្សធម៌ទាល់តែសោះនោះឡើយ។ ផ្ទុយទៅវិញ អ្វីៗទាំងអស់ត្រូវបានគិតគូរសំដៅបាន ចូលរួមចំណែកនៅក្នុងការរំលោភបំពានដែលមានលក្ខណៈជាប្រព័ន្ធរបស់ពួកខ្លួនតែប៉ុណ្ណោះ។

[១១:២៧:៤៧]

**អំពីការធ្វើមនុស្សឃាត**

ឧក្រិដ្ឋកម្មចម្បង នៅមន្ទីរស-២១ គឺការធ្វើមនុស្សឃាតក្នុងកម្រិតមួយយ៉ាងទូលំទូលាយ ដែលជាក់ស្តែងទៅលើគ្រប់គ្នាទាំងអស់ ដែលត្រូវបានជាប់ឃុំឃាំងនៅទីនោះជាចុងក្រោយ ជាបុរស ជាស្ត្រី និងជាកុមារ។ យើងមិនដែលបានដឹងដោយបានពិតប្រាកដថា មានជីវិតមនុស្សចំនួនប៉ុន្មាននាក់ត្រូវបានកម្ទេចចោលទេ។ យ៉ាងតិចណាស់ក៏មានចំនួនមនុស្ស១២.២៧៣នាក់ដែរ ដែលត្រូវបានកត់ត្រាទុកក្នុងបញ្ជីឈ្មោះអ្នកទោស។ ការស្លាប់របស់ពួកគេ គឺជាសតិមួយដែលគ្មានន័យសម្រាប់ជនជាប់ចោទរូបនេះ និងពួកមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យទេ។ ការព្រួយបារម្ភរបស់ពួកគេ គឺការធានាយ៉ាងណាធ្វើឲ្យបានចម្លើយសារភាពនានា ឲ្យបានគ្រប់គ្រាន់ពីអ្នកទោសទាំងនោះ។ នៅពេលដែលការណ៍នេះបានសម្រេចហើយ ការបន្តទៀតគឺត្រូវការសម្លាប់ចោលជាប្រព័ន្ធ ដោយមានចេតនា ដោយមានបំណងគិតទុកជាមុន និងដោយគ្មានមេត្តាធម៌។

ភ័ស្តុតាងបានបង្ហាញថា ជនជាប់ចោទរូបនេះ គឺពួកថ្នាក់ក្រោមរបស់គាត់មានចេតនាយ៉ាងច្បាស់លាស់ ដើម្បីសម្លាប់ពួកជនរងគ្រោះនៅមន្ទីរស-២១ ដោយបានដឹងថា វាជាបញ្ហាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលថាពួកអ្នកជាប់ឃុំឃាំងទាំងអស់ត្រូវតែសម្លាប់ចោល។ វាគឺជាការងារ

របស់ជនជាប់រូបនេះ ដើម្បីធានាថា គោលនយោបាយនេះត្រូវតែយកទៅប្រតិបត្តិតាម ហើយគាត់បានអនុវត្តនូវកិច្ចការរបស់គាត់យ៉ាងតឹងតែង ជាប់រហូតជានិច្ចនិងដោយមានការប្ដេជ្ញាចិត្តផង។

ភាគច្រើននៃការស្លាប់ គឺបណ្ដាលមកពីអំពីហិង្សា ដែលបុគ្គលិកមន្ទីរស-២១ បានធ្វើឡើងទៅតាមបញ្ជារបស់ជនជាប់រូបនេះឲ្យមានចេតនាជាក់លាក់ ដើម្បីសម្លាប់ចោល។ភាគច្រើននៃអ្នកទោសត្រូវបានប្រហារជីវិត ដោយការវាយដុំនឹងដំបង ឬដោយការសម្លាប់ដោយកាំបិតនៅជើងឯង។ ពួកអ្នកទោសថ្នាក់ខ្ពស់ត្រូវបានសម្លាប់ចោលនៅក្នុង ឬនៅក្បែរមន្ទីរស-២១ ហើយជាទូទៅ ក៏ត្រូវបានវាយសម្លាប់ចោលនឹងដំបងផងដែរ។ ទោះបីជាពីដំបូង វានៅមិនទាន់ច្បាស់លាស់ទាំងស្រុងនៅឡើយ ថាតើអ្នកទោសបស្ចិមប្រទេសត្រូវបានគេសម្លាប់ ឬយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានស្ដាប់នូវភ័ស្ដុតាងអំពីរបៀបដែលពួកគាត់ត្រូវបានគេដុតនឹងកង់ឡានរួចហើយដែរ។

ការបូមឈាមដោយបង្ខំ ការវះកាត់លើពួកអ្នកទោសនៅរស់ និងការពិសោធធ្វើដូចជាផ្នែកវេជ្ជសាស្ត្រដទៃទៀត ដែលនាំឲ្យមានការស្លាប់ ត្រូវបានគេគិតទុកជាមុន និងដោយមានចេតនា។

[១១:៣០:៤៩]

ជាញឹកញាប់ការធ្វើឲ្យមានអំពើទារុណកម្ម បានបណ្ដាលឲ្យមានអ្នកទោសស្លាប់ ជាពិសេសក្នុងពេលដាក់ឲ្យឆក់ខ្សែភ្លើងពេលធ្វើការសួរចម្លើយ។ ការណ៍នេះ បានបំពេញនូវនិយមន័យនៃការធ្វើមនុស្សឃាត ដោយវាជាអំពើមួយដែលបានគិតទុកជាមុន ដោយមានចេតនា និងធ្វើឲ្យមានការឈឺចាប់សោកសៅដល់រាងកាយ ឬក៏ធ្វើឲ្យរបួសដ៏ធ្ងន់ធ្ងរ។ ស្រដៀងគ្នានេះដែរ លក្ខខណ្ឌអមនុស្សធម៌នានា ដូចជាកង្វះខាតនៅអាហារ អនាម័យ ការថែទាំផ្នែកវេជ្ជសាស្ត្រឲ្យបានត្រឹមត្រូវបណ្ដាលឲ្យមានការស្លាប់អ្នកទោសចំនួនដ៏ច្រើន ដែលត្រូវតែបានមើលឃើញផងដែរថា ជាអំពើ ឬការខកខានមិនបានធ្វើដោយចេតនា បានគិតទុកជាមុន ដើម្បីធ្វើឲ្យមានការឈឺចាប់ ឬរបួសរហូតដល់កម្រិតបែបដូច្នេះ។

[១១:៣១:៤៧]

ឧក្រិដ្ឋកម្មបន្ទាប់ចុងក្រោយដែលប្រឆាំងនឹងមនុស្សជាតិត្រូវបានបង្ហាញដោយភ័ស្ដុតាងនោះ គឺឧក្រិដ្ឋកម្មការសម្លាប់រង្គាល។ ឧក្រិដ្ឋកម្មនេះតម្រូវឲ្យមានសក្ខីកម្មនៃអំពើមួយ ឬក៏ការខកខាន មិនបានធ្វើអំពើនោះ ដែលបណ្ដាលឲ្យមានការស្លាប់មនុស្សក្នុងកម្រិតដ៏ច្រើនក្រាស់ក្រែល ហើយដែលមានចេតនាមួយខាងផ្នែកជនជាប់ចោទដើម្បីសម្លាប់មនុស្សក្នុងកម្រិតដ៏ច្រើនក្រាស់ក្រែលនោះ ឬដើម្បីបង្កើតឡើងនូវលក្ខខណ្ឌនៃការរស់នៅនានា ដែលនាំឲ្យមានការស្លាប់មនុស្សក្នុងចំនួនដ៏ច្រើន។ ជនជាប់ចោទ

រូបនេះធ្លាប់បានទទួលស្គាល់ថា ការស្លាប់ទាំងនោះ គឺបណ្ដាលមកពីគោលនយោបាយមួយបានគិតទុកជាមុន ដើម្បីសម្លាប់គ្រប់អ្នកទោសទាំងអស់ ដែលគាត់និងថ្នាក់ក្រោមរបស់គាត់ត្រូវអនុវត្ត។

ដោយពិចារណាទៅលើចំនួនសរុបដែលត្រូវបានសម្លាប់ ការបំផ្លាញជីវិតមនុស្សដោយមានការគិតគូរទុកជាមុនបែបដូច្នេះ ត្រូវបានពិព៌ណនាថា ការសម្លាប់រង្គាលយ៉ាងពិតប្រាកដ។

**អំពីការធ្វើទុក្ខបុកម្នេញ**

ឧក្រិដ្ឋកម្មដែលប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបង្ហាញដោយភស្តុតាងនោះ គឺឧក្រិដ្ឋកម្មអំពើការធ្វើទុក្ខបុកម្នេញដែលជាបទល្មើសមួយនៅក្នុងសិទ្ធិផ្ទាល់របស់វាដែលត្រូវបានផ្ដល់និយមន័យ ដោយការរើសអើងដ៏ជាក់លាក់ទៅលើមូលហេតុខាងនយោបាយ ពូជសាសន៍ និងខាងសាសនា។ ការធ្វើទុក្ខបុកម្នេញជាលក្ខណៈសំខាន់ណាស់នៃមន្ទីរស-២១។ ការរើសអើងប្រឆាំងនឹងពួកអ្នកទោស បានបញ្ជាក់ដោយភស្តុតាងជាក់ស្ដែង ត្រូវគ្រប់អំពើហិង្សានីមួយៗ ឬក៏ការខកខានដោយគ្មានមេត្តា មិនបានធ្វើនូវអំពើនោះប្រឆាំងនឹងពួកគេ ក្នុងអំឡុងពេលនៃការឃុំឃាំង។

គ្រប់បទល្មើសទាំងអស់ដែលបានរៀបរាប់មកនេះ ដែលយើងបានពិព៌ណនារហូតមកទាល់ពេលនេះ គឺអាចមានលទ្ធភាពក្នុងការពិចារណាថា ជាអំពើនានានៃការធ្វើទុក្ខបុកម្នេញហើយ។ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើរឿងនេះថា យ៉ាងដូច្នេះផងដែរ។ ដូចដែលយើងបានពន្យល់រួចមកហើយ ការកម្ទេចពួកសត្រូវនយោបាយ និងការលុបបំបាត់ចោលពួកវៀតណាម និងឥទ្ធិពលទាំងអស់របស់វៀតណាម គឺជាមាគ៌ានយោបាយដ៏តឹងរ៉ឹងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលជនជាប់ចោទរូបនេះ និងថ្នាក់ក្រោមរបស់គាត់បានអនុវត្តយ៉ាងហ្មត់ចត់នៅមន្ទីរស-២១។ នៅក្នុងកាលៈទេសៈទាំងនេះ វាមិនអាចមានចម្ងល់អ្វីទៀតទេ ដែលថាជនជាប់ចោទនិងថ្នាក់ក្រោមរបស់គាត់បានប្រតិបត្តិនូវអំពើនានានៃការធ្វើទុក្ខបុកម្នេញ ដោយមានចេតនាដើម្បីធ្វើការរើសអើង ដោយមានមូលហេតុនយោបាយ និង/ឬ ខាងពូជសាសន៍។

[១១:៣៤:៤៩]

**អំពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ**

ឥឡូវនេះ ខ្ញុំសូមបន្តទៅនឹងរបៀបដែលអង្គហេតុនេះបានបង្ហាញនូវអំពើរបស់ជនជាប់ចោទនៅមន្ទីរស-២១ ដែលបានបង្កើតថា ឧក្រិដ្ឋកម្មសង្គ្រាមផងដែរ។

សាធារណជនអាចនឹងសួរថា ហេតុអ្វីបានជាចាំបាច់លើឡើងនូវឧក្រិដ្ឋកម្មទាំងនេះ ដែលជា

ទូទៅមានមូលដ្ឋាននៅលើអង្គហេតុដូចៗគ្នា។ តើការកាត់សេចក្ដីតែទៅលើបទឧក្រិដ្ឋអន្តរជាតិតែមួយប្រភេទ ដូចជាឧក្រិដ្ឋកម្មសង្គ្រាមជាដើមនោះ វាមិនគ្រប់គ្រាន់ទេឬយ៉ាងណា? ទាំងនេះគឺសុទ្ធតែជាសំណួរដ៏សមហេតុផលដែលទាមទារឲ្យមានការឆ្លើយតប។

ទីមួយ គឺវិធាននៃច្បាប់តម្រូវឲ្យវា និងអង្គជំនុំជម្រះនេះ និងជាពិសេសការិយាល័យរបស់ពួកយើងខ្ញុំដែលត្រូវបានជាប់កាតព្វកិច្ចត្រូវអនុវត្តច្បាប់។

ទីពីរ គឺជាកិច្ចការសំខាន់មួយ ដែលប្រទេសកម្ពុជា និងសហគមន៍ពិភពលោកមើលឃើញថាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ ត្រូវតែបានដាក់ទណ្ឌកម្មដើម្បីឲ្យនៅមានលទ្ធភាពក្នុងការបន្ត ធ្វើឲ្យមានអនុភាពក្នុងការញញើតមួយទៅអនាគត អំពីជម្លោះប្រដាប់អាវុធនានានៅទូទាំងពិភពលោក។ អនុសញ្ញាទាំងនេះ មិនត្រូវបានមើលឃើញថាគ្រាន់តែជាពាក្យនៅលើក្រដាសប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាសិទ្ធិ និងគោលការណ៍ទាំងឡាយដែលប្រជាជាតិស៊ីវិល ស៊ីវិល័យនានាបានជឿជាក់ និងគាំទ្រដោយមិនគិតពីនយោបាយ ឬភាពងាយស្រួលឡើយ។

ទីបី ឧក្រិដ្ឋកម្មសង្គ្រាមរួមផ្សំជាមួយនឹងបទចោទដទៃទៀត ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវពិរុទ្ធភាពរបស់ជនរងគ្រោះ ហើយអវត្តមាននៃឧក្រិដ្ឋកម្មសង្គ្រាម និងមិនបានប្រាប់ប្រវត្តិមន្ទីរស-២១ទាំងស្រុងទេ ជាពិសេសគឺការស្លាប់របស់ជនស៊ីវិល និងទាហានវៀតណាម ដែលសមនឹងទទួលបានច្រើនជាងអ្វីដែលពួកគេបានទទួលរួមមកហើយនេះ។

តាមសវតានៃឧក្រិដ្ឋកម្មទាំងនេះ នៅក្រោមសង្គ្រាមលើកទីពីរ សហគមន៍អន្តរជាតិបានមកជួបជុំគ្នានៅទីក្រុងហ្សឺណែវ និងបានបង្កើតវិធាននានាមួយចំនួនដោយមានគោលដៅសំខាន់ដើម្បីកាត់បន្ថយឬដកចេញនូវអំពើសាហាវឃោឃៅនៅពេលមានសង្គ្រាមដែលប្រឆាំងនឹងជនស៊ីវិល និងពួកឆ្លើយសឹក។ ការដាក់ឲ្យជាបទល្មើសព្រហ្មទណ្ឌ និងការដាក់ទណ្ឌកម្មទៅលើឧក្រិដ្ឋកម្មសង្គ្រាម ជាពាក្យសម្ដី តាមក្រៀមភាសាដែលប្រើចំពោះការរំលោភដ៏ធ្ងន់ធ្ងរទៅលើវិធាននានាដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌក្នុងអនុសញ្ញានៃទីក្រុងហ្សឺណែវ។ គឺមិនមានអ្វីជាបញ្ហាទៀតឡើយ ដែលវាជាផ្នែកមួយនៃការបង្កើតច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅក្នុងរយៈកាលទាំងស្រុងនៃពាក់កណ្ដាលទីពីរនៃសតវត្សរ៍ទី២០ ប៉ុន្តែក្នុងរយៈកាល៥០ឆ្នាំចាប់ពីអនុសញ្ញានានានៃទីក្រុងហ្សឺណែវត្រូវបានចុះហត្ថលេខារួចមក អនុសញ្ញាទាំងនោះត្រូវបានគេទទួលស្គាល់កាន់តែច្រើនឡើងនៅក្នុងការបង្កាត់ជាជាងក្នុងការសង្កេតរបស់ពួកគេ។

[១១:៣៨:១៩]

ដូច្នេះ វាបានបង្ហាញនៅក្នុងជម្លោះប្រដាប់អាវុធមួយនៃកម្ពុជាប្រជាធិបតេយ្យជាមួយនឹងវៀតណាមនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ពួកឆ្លើយសឹកវៀតណាមដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១ ទាំងទាហាន និងទាំងស៊ីវិល ត្រូវមានទៅតាមផ្លូវច្បាប់ដើម្បីឲ្យគេគ្រប់គ្រងយ៉ាងត្រឹមត្រូវ និងដោយយុត្តិធម៌។

ជនជាប់ចោទនេះ ហើយនិងពួកថ្នាក់ក្រោមដែលបានមានសិទ្ធិ និងអំណាចរបស់គាត់ បានបដិសេធពួកគេ។ ដោយច្រានចោលនូវភាពមនុស្សធម៌ទាំងនោះ ដែលការធ្វើដូច្នេះ គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ ខ ចែងទាំងឡាយ នៃអនុសញ្ញានៃទីក្រុងហ្សឺណែវ។

មាត្រា៦ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់អំណាចឲ្យអង្គជំនុំជម្រះទាំងឡាយធ្វើការសេចក្តីលើជនសង្ស័យនានាដែលបានប្រព្រឹត្ត ឬបានបញ្ជាឲ្យប្រព្រឹត្តនូវអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរចំនួនប្រាំបីផ្សេងៗគ្នា ដែលមានចែងក្នុងអនុសញ្ញានៅទីក្រុងហ្សឺណែវ។ ភ័ស្តុតាងបានបង្ហាញហួសពីវិមតិសង្ស័យថា មានឧក្រិដ្ឋកម្មចំនួនប្រាំក្នុងចំណោមឧក្រិដ្ឋកម្មទាំងប្រាំបី ត្រូវបានប្រព្រឹត្ត ត្រូវបានបញ្ជាដោយប្រព្រឹត្តនៅមន្ទីរស-២១ ជាពិសេសគឺការឃុំជនស៊ីវិលដោយខុសច្បាប់ ការដកហូតសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដោយត្រឹមត្រូវនិងទៀងទាត់។ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ និងការធ្វើមនុស្សឃាតដោយចេតនា។ ដើម្បីឲ្យបទល្មើសនានាដែលបានរៀបរាប់មកផ្សេងៗគ្នាចំនួនប្រាំនេះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ធាតុផ្សំបន្ថែមនៃយុត្តាធិការ ក៏ត្រូវតែបង្ហាញជាសក្ខីកម្មផងដែរ។

[១១:៤០:៣០]

បទល្មើសនានាដែលបានរៀបរាប់មកនេះត្រូវតែបានប្រព្រឹត្តនៅក្នុងបរិបទនៃ-- និងត្រូវតែបានរួមផ្សំដោយជម្លោះប្រដាប់អាវុធអន្តរជាតិផងដែរ។ ចារីត្រូវតែបានដឹង ឬអំពីកាលៈទេសៈនានានៃអង្គហេតុដែលបានបង្ហាញសក្ខីកម្មឲ្យឃើញអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធមួយ។ អំពើទាំងនោះត្រូវតែបានប្រព្រឹត្តប្រឆាំងនឹងជនទាំងឡាយដែលត្រូវបានទទួលនូវការការពារដោយអនុសញ្ញាមួយ ឬច្រើននៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ហើយចារីត្រូវបានដឹងអំពីកាលៈទេសៈនានានៃអង្គហេតុដែលបង្ហាញសក្ខីកម្មឲ្យឃើញអំពីអត្ថិភាពនៃឋានៈដែលត្រូវបានទទួលនូវការការពារនេះ។

[១១:៤១:១៩]

យើងនឹងធ្វើសេចក្តីអត្ថាធិប្បាយសង្ខេបអំពីបញ្ហានេះម្តងមួយៗ។ ជាការឆ្លើយតបទៅនឹងបញ្ហាស្តីពីជម្លោះប្រដាប់អាវុធដែលមេធាវីការពារក្តីបានជំទាស់។ អយ្យការខកខានមិនបានបង្ហាញឱ្យហួសពីវិមតិសង្ស័យថា ជម្លោះប្រដាប់អាវុធមួយមានអត្ថិភាពពេញលេញរយៈកាលនៃទង្វើឧក្រិដ្ឋរបស់ជនជាប់ចោទ ជាពិសេសមេធាវីការពារក្តីជឿជាក់ថា ជម្លោះប្រដាប់អាវុធមួយមិនបានកើតឡើងនោះទេ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។ នៅពេលដែលទំនាក់ទំនងការទូតនានាត្រូវបានកាត់ផ្តាច់រវាងកម្ពុជា និងវៀតណាម។ ទោះជាយ៉ាងនេះក្តី ក៏អង្គហេតុទាំងនេះមិនបានគាំទ្រដល់គោលជំហរនេះឡើយ។

ដូចដែលយើងនឹងពិភាក្សាបន្តទៅទៀតនេះ វាហួសពីវិមតិសង្ស័យទាំងអស់ដែលថាភ័ស្តុតាងបានផ្តល់ជាសក្ខីកម្មលើជម្លោះប្រដាប់អាវុធអន្តរជាតិមួយរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចាប់ផ្តើមនៅក្នុងខែមេសា ១៩៧៥ ហើយបានបន្តទៀតទៅតាមកម្រិតនៃប្រពលភាពផ្សេងៗគ្នារហូតដល់ខែមករា ឆ្នាំ១៩៧៩។ ចំណែកឯមន្ទីរ ស-២១ មិនបានបើកប្រតិបត្តិការ និងចាប់ផ្តើមឧក្រិដ្ឋរបស់ខ្លួនទេ រហូតដល់ក្រោយខែមេសា ឆ្នាំ១៩៧៥ ទើបបានបើកប្រតិបត្តិការ និងចាប់ផ្តើមសកម្មភាពឧក្រិដ្ឋរបស់ខ្លួន ដែលនេះជាការសំខាន់។ អង្គជំនុំជម្រះនេះនឹងរកឃើញថា ជម្លោះប្រដាប់អាវុធនោះបានចាប់ផ្តើមនៅដើមឆ្នាំ១៩៧៥ ដែលជាផ្នែកមួយនៃតួនាទីរបស់ខ្លួននៅក្នុងការកំណត់រកការពិតទៅលើអង្គហេតុនានាដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នេះជាអ្វីដែលការចោទប្រកាន់ត្រូវបានបង្ហាញមានសក្ខីកម្ម ហើយអង្គជំនុំជម្រះត្រូវបានតម្រូវឱ្យរកនូវអង្គហេតុអ្វីដែលបង្ហាញជាសក្ខីកម្ម។

នៅក្នុងការពិនិត្យឡើងវិញនូវអង្គហេតុនានា យើងបានដាក់ជូននូវអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិមួយរវាងកម្ពុជាប្រជាធិបតេយ្យនិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានបង្ហាញជាសក្ខីកម្មហួសពីវិមតិសង្ស័យទាំងអស់។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតដែលបានចែងថា លើកលែងតែនៅក្នុងពេលសម្រាកមួយចំនួនតិចប៉ុណ្ណោះ មានអំពើហិង្សាប្រដាប់អាវុធជាញឹកញាប់ដែលចេះតែកើតខ្លាំងឡើងៗ និងចេះតែរាលដាលចាប់ផ្តើមក្នុងខែមេសា ១៩៧៥។

[១១:៤៥:០១]

ក្នុងអំឡុងពេលសវនាការសាក្សីជំនាញឈ្មោះ ណាយ៉ាន់ ចាន់ដា បានបង្ហាញទស្សនៈមួយថាប្រទេសទាំងពីរនេះមានសង្គ្រាមជាមួយគ្នាចាប់ពីពេលមានអត្ថិភាពនៃកម្ពុជាប្រជាធិបតេយ្យ។

លោកប្រធាននៅតែចងចាំបានអំពើចម្លើយទៅនឹងអំពីចម្លើយទៅនឹងសំណួររបស់មេធាវីការពារ

ក្តីដែលថា ក្នុងឆ្នាំ១៩៧៥ ពុំមានសង្គ្រាមជាមួយវៀតណាមទេ។ ណាយ៉ាន់ ចាន់ដា បានឆ្លើយថា បើសង្គ្រាមអាចកើតឡើងបានដោយពុំចាំបាច់មានការប្រកាសសង្គ្រាមនោះ កម្ពុជានិងវៀតណាម គឺមានសង្គ្រាមនឹងគ្នាចាប់តាំងពីឆ្នាំ១៩៧៥។

ដូចដែលលោកប្រធានបានជ្រាបស្រាប់ហើយថា ទៅតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងទៅតាមទឡ្ហីករណ៍សមស្របនានា ការប្រកាសសង្គ្រាមពុំចាំបាច់តម្រូវឱ្យមានការបង្ហាញសក្ខីកម្មអំពីអស្ថិរភាពនៃជម្លោះប្រដាប់អាវុធទេ។ ទស្សនៈរបស់ ណាយ៉ាន់ ចាន់ដា គឺមានមូលដ្ឋានទៅលើការសង្កេតនានារបស់គាត់អំពីទំហំ និងចារិកលក្ខណៈនៃអរិភាពដែលប្រទេសទាំងសងខាងបានប្រកាន់យក។

យ៉ាងណាក៏ដោយសក្ខីកម្មរបស់ ណាយ៉ាន់ ចាន់ដា គឺជាភ័ស្តុតាងមួយដ៏សំខាន់ដែលលើសពីភ័ស្តុតាងនានាដែលបានហួសពីមតិសង្ស័យនៅពេលសវនាការ ថាជាការភ័ស្តុតាងដែលហួសពីវិមតិសង្ស័យតែមួយដែលបង្ហាញថា មានមានជម្លោះប្រដាប់អាវុធមួយរវាងប្រទេសទាំងពីរ ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

របាយការណ៍បណ្តាយសារព័ត៌មាន កាលពីជំនាន់មួយជាមួយគ្នា និងរបាយការណ៍យោធា និងនយោបាយនៃកម្ពុជាប្រជាធិបតេយ្យក៏ដូចជាអត្ថបទវិភាគរបស់អ្នកជំនាញនានា បានបញ្ជាក់អះអាងទៅលើទស្សនៈរបស់ ណាយ៉ាន់ ចាន់ដា។ អត្ថបទជាក់លាក់នានាត្រូវបានលម្អិតនៅក្នុងសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោលជាលាយលក្ខណ៍អក្សរ នៅក្នុងកាលប្បវត្តិនៃជម្លោះប្រដាប់អាវុធដែលបានដាក់ជូនដោយភ្ជាប់មកជាមួយនឹងរបាយការណ៍ និងអត្ថបទវិភាគចំនួន៤៣០ នៅក្នុងអំឡុងនៃករណីនេះ។

ដូច្នេះភ័ស្តុតាងរបស់អ្នកជំនាញ និងឯកសារជាច្រើនកាលពីជំនាន់ជាមួយគ្នា ដែលបានដាក់បញ្ជានៅពេលសវនាការ បន្សល់ទុកនូវចម្ងល់តែបន្តិចបន្តួចប៉ុណ្ណោះ ទាក់ទងនឹងអស្ថិរភាពនៃជម្លោះប្រដាប់អាវុធចាប់ពីឆ្នាំ១៩៧៥មក បើទោះជានៅក្នុងដំណាក់កាលដំបូងរដ្ឋាភិបាលទាំងពីរចង់រក្សាវាទុកថាជាសង្គ្រាមសង្ងាត់ក៏ដោយចុះ។

បើសង្ខេបខ្លីទូទៅនៃជម្លោះចេះតែកើន ហើយនៅតាមវេលា ហើយការប៉ះទង្គិចគ្នានៅតាមព្រំដែនការប្រយុទ្ធគ្នា ការបោះបោរ និងការចូលលុកលុយទាំងស្រុកបានកើតឡើងរវាងកងកម្លាំងប្រដាប់អាវុធទាំងពីរប្រទេសចាប់ពីខែមេសា ឆ្នាំ១៩៧៥ តរៀងមក។

ការណ៍នេះបានកើនឡើងដល់កំពូល ហើយការចូលលុកលុយពេញទំហឹងក្នុងប្រទេសកម្ពុជាពីសំណាក់កងកម្លាំងវៀតណាម ដែលបានបណ្តាលឲ្យមានការដួលរំលំនៃរដ្ឋាភិបាលកម្ពុជាប្រជាធិប-

តេយ្យកាលពីខែមករា ឆ្នាំ១៩៧៩។

[១១:៤៧:១១]

ដើម្បីបង្ហាញសក្ខីកម្មពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាហ្សឺណែវ គេក៏ត្រូវតែបង្ហាញផងដែរថា ជនជាប់ចោទបានដឹងអំពីជម្លោះនោះ និងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តដោយរួមគ្នា។

នៅក្នុងបរិបទស្ដីពីជម្លោះប្រដាប់អាវុធ នៅត្រង់ចំណុចនេះ ជាការបន្ថែមទៅលើការអះអាងរបស់ពួកខ្លួនក្រុមមេធាវីការពារក្ដីបានលើកសំអាងថាជម្លោះប្រដាប់អាវុធមិនមានអត្ថិភាពទេ។ រហូតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ហើយថាជនជាប់ចោទមិនបានដឹងអំពីជម្លោះប្រដាប់អាវុធនេះទេ រហូតមកដល់ក្រោយកាលបរិច្ឆេទនោះទើបគាត់បានដឹង។

ដូច្នេះហើយ ដោយឈរលើមូលដ្ឋាននេះ ពួកខ្លួនបាននិយាយថាបទល្មើសនានាដែលជាអំពីបំពារបំពានយ៉ាងធ្ងន់ធ្ងរមិនអាចត្រូវបានបង្ហាញសក្ខីកម្មថា បានកើតឡើងនៅមុនកាលបរិច្ឆេទនេះទេ។ ជាពិសេសក្រុមមេធាវីការពារក្ដីបានថ្លែងថា ដោយសារតែភាពសម្ងាត់នៃបក្សកុម្មុយនីស្ដកម្ពុជាស្ដីពីបញ្ហាជម្លោះប្រដាប់អាវុធ ហើយនិងអវត្តមានដែលមិនទៀងទាត់នៃពួកអ្នកទោសវៀតណាមនៅមន្ទីរស-២១ នៅចុងឆ្នាំ១៩៧៧។ ដូច្នេះ គឺពុំមានបទល្មើសនានាដែលជាអំពើបំពារបំពានធ្ងន់ធ្ងរអាចត្រូវបានគេរកឃើញនៅមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។ ទាក់ទិននឹងបញ្ហានេះ សេចក្ដីសំអាងនេះគឺជាលក្ខណៈផ្សេងគ្នាទាំងស្រុងទៅនឹងភ័ស្ដុតាង។ ជនជាប់ចោទបើមិនមែនជាបុគ្គលសំខាន់បំផុតទេ ក៏ជាបុគ្គលដ៏សំខាន់បំផុតម្នាក់នៅក្នុងចំណោមបុគ្គលដ៏សំខាន់បំផុតនៅក្នុងចារកម្មរបស់បក្សកុម្មុយនីស្ដកម្ពុជានៅក្នុងប្រតិបត្តិការផ្នែកសន្តិសុខ ដូចដែលសហការីរបស់ខ្ញុំនឹងធ្វើការពិភាក្សានៅបន្ទាប់ពេលខាងក្រោយនេះ។

វាការច្បាស់ណាស់ដែលថាការសម្ងាត់មិនត្រូវបានរក្សាទុកដោយមិនឲ្យគាត់ដឹងនោះទេ។ ព្រោះជាផ្នែកមួយនៃពួកគេ។ ដោយសារតែចារិកនៃកិច្ចការរបស់គាត់ក្នុងការប្រមូលព័ត៌មានសម្ងាត់ជាលទ្ធ-ផលជនជាប់ចោទ គឺបានស្ថិតនៅក្នុងតំណែងមួយដ៏ល្អបំផុតក្នុងចំណែមតំណែងល្អៗទាំងឡាយក្នុងការបានដឹង ឮ ពីជម្លោះនានា ព្រមទាំងការប្រុងប្រយ័ត្ន និងការព្រួយបារម្ភរបស់បក្សកុម្មុយនីស្ដកម្ពុជាអំពីបញ្ហានេះផងដែរ។ ថាតើកម្ពុជា និងវៀតណាមមានបំណងចង់ពិភាក្សាអំពីជម្លោះប្រដាប់អាវុធនេះជាសាធារណៈ ឬមួយមិនចង់នោះ? ការនេះមិនមានជាប់ជំពាក់អំពីថាតើជនជាប់ចោទ បានដឹងឮ ឬមិនបានដឹងឮ អំពីជម្លោះមួយនោះទេ។

[១១:៤៩:៥៧]

ចំណែកឯអវត្តមានដែលមានទៀងទាត់នៃពួកវៀតណាមនៅមន្ទីរស-២១។ ដូចដែលពួកខ្លួនបានអះអាងហើយ ចាប់ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧ ដែលជាការពិនិត្យមើលត្រួសៗទៅលើភស្តុតាងគឺខកខានមិនបានគាំទ្រគោលជំហរនេះទេ ឲ្យតែជនជាប់ចោទបានដឹងឮថា មានពួកវៀតណាមនៅមន្ទីរស-២១ នោះវាមិនចាំបាច់ថា ចំនួនដែលមិនទៀងទាត់អ្វីណាមួយ ដែលថាការដឹងឮពីចំនួនមួយចំនួនទាំងនោះបានគាំទ្រដល់ការរកឃើញថា ជនជាប់ចោទនោះបានដឹងឮពីជម្លោះប្រដាប់អាវុធ តាមរយៈអង្គហេតុនោះក្នុងចំណោមវិធីសាស្ត្រដទៃទៀតដែលអាចមាន។ ផ្ទុយទៅវិញ ភស្តុតាងបានបង្ហាញថា ជនជាប់ចោទរូបនេះបានដឹងឮទាំងស្រុង អំពីកាលៈទេសៈនានានៃជម្លោះប្រដាប់អាវុធនេះ យ៉ាងហោចណាស់ក៏នៅពេលដែលអ្នកទោសវៀតណាមទីមួយបានមកដល់ ជនជាប់ចោទរូបនេះបានទំនាក់ទំនងការងារដ៏ជិតស្និទ្ធជាមួយនឹង សុន សេន ដែលជានាយអគ្គសេនាធិការយោធានៃកម្ពុជាប្រជាធិបតេយ្យ ហើយគាត់បានចូលរួមនៅក្នុងការប្រជុំផ្សេងៗនៃអង្គភាពយោធា។

សុន្ទរកថានានាដែលធ្វើឡើងដោយពួកមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ទស្សនាវដ្តីរបស់បក្ស និងការឃោសនាដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជាតែងតែយោងជានិច្ចសំដៅទៅរកប្រទេសវៀតណាម និងប្រជាជនវៀតណាមថាជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យ។

ជាផ្នែកមួយនៃអង្គហេតុដែលបានព្រមព្រៀងគ្នា ជនជាប់ចោទរូបនេះបានទទួលស្គាល់ថា គាត់បានដឹងអំពីទីកន្លែងដែលជម្លោះបានចាប់ផ្តើមដំបូង គឺនៅម្តុំជុំវិញកោះត្រល់ នៅក្នុងខែមេសា ខែឧសភា ឆ្នាំ១៩៧៥ នៅភាគខាងត្បូងខេត្តមណ្ឌលគីរី និងនៅតាមបណ្តោយខ្សែបន្ទាត់ប្រេវីយ៉េនៅដើមឆ្នាំ១៩៧៦ ជនជាប់ចោទរូបនេះក៏បានទទួលស្គាល់ផងដែរថា ខ្លួនបានចាត់តាំងអ្នកយាមនៅក្រោមបង្គាប់របស់ខ្លួនម្នាក់គឺឈ្មោះ ម៉ម ណៃ ឲ្យសួរចម្លើយពួកអ្នកទោសវៀតណាម។

ជនជាប់ចោទរូបនេះក៏មិនបានជជែកផងថា អំពីការចាប់ខ្លួនដែលត្រូវបានកត់ត្រាជាដំបូងនៅថ្ងៃទី៧ ខែកុម្ភៈឆ្នាំ១៩៧៦ ទៅលើបុគ្គលម្នាក់ដែលត្រូវបានកំណត់អត្តសញ្ញាណថា ជាជនជាតិវៀតណាមនេះគឺមកពីការឯកសារអំពីការមកដល់នៃពួកវៀតណាមក្នុងដើមឆ្នាំ១៩៧៦។ បែបនេះត្រូវបានកត់ត្រាទុកដោយឯកសារ ដោយអក្សរផ្ទាល់ដៃរបស់ជនជាប់ចោទរូបនេះ ពួកទាហាន និងពួកជនស៊ីវិលវៀតណាម ដែលត្រូវបានសួរចម្លើយនិងសម្លាប់ចោលនៅមន្ទីរស-២១ ត្រូវទទួលរងនៅការការពារដោយបញ្ញត្តិនានានៃអនុសញ្ញាទីក្រុងហ្សឺណែវ។

បញ្ជីអ្នកទោសនានាដែលនៅសល់មានរាយនាមបង្ហាញឈ្មោះសមាជិកយោធាវៀតណាមធម្មតា

រវាង១៥០នាក់ ទៅដល់ច្រើនរយនាក់ ជាអ្នកចាប់ខ្លួននៅក្នុងអំឡុងពេលនៃអរិភាព នៅក្បែរតំបន់ព្រំដែនជាប់ជាមួយនឹងកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដាក់គុកនៅមន្ទីរស-២១។

[១១:៥៣:១៦]

ដោយការធ្លាក់ចូលនៅក្នុងអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ពួកទាហានវៀតណាមទាំងនេះមានសិទ្ធិទទួលបាននូវឋានៈជាឈ្លើយសឹកនៅតាមអនុសញ្ញាទីក្រុងហ្សឺណែវ។ ស្រដៀងគ្នានេះដែរយ៉ាងហោចណាស់មានជនស៊ីវិលវៀតណាមចំនួន១០០នាក់ដែរ ដែលត្រូវបានដាក់ឲ្យឃុំនៅមន្ទីរស-២១កាលដែលពួកខ្លួនត្រូវស្ថិតនៅក្នុងដៃរបស់ភាគីមួយនៃជម្លោះដែលពួកខ្លួនមិនមែនជាជនជាតិរបស់ប្រទេស នោះពួកខ្លួនត្រូវមានសិទ្ធិទទួលបាននូវឋានៈ ដែលត្រូវបានការពារដោយអនុសញ្ញាទីបួន នៃទីក្រុងហ្សឺណែវ។ ជនជាប់ចោទរូបនេះមិនបានជជែកតវ៉ាទេថា យ៉ាងហោចណាស់មានប្រជាជនវៀតណាមចំនួន៤០០នាក់ត្រូវបានដាក់ឃុំនៅមន្ទីរស-២១ និងថាពួកទាំងនោះបានមកដល់ជាចំនួនដ៏ច្រើន នៅពេលដែលជម្លោះជាមួយវៀតណាមចេះតែរីកធំឡើង ហើយថាជាចុងក្រោយបំផុតម្នាក់ៗសុទ្ធតែត្រូវបានសម្លាប់ចោល។ ការដឹងឮពីជម្លោះប្រដាប់អាវុធ គឺជាកម្រិតនៃការដឹងឮតែមួយប៉ុណ្ណោះ ដែលជនជាប់ចោទរូបនេះត្រូវតែមាន និងត្រូវបានបង្ហាញសក្ខីកម្ម។ ជនជាប់ចោទរូបនេះ ក៏ត្រូវតែបានដឹងឮផងដែរអំពីឋានៈរបស់ពួកបុគ្គល បុគ្គលិកយោធា និងជនស៊ីវិលវៀតណាម ដែលត្រូវទទួលបាននូវការការពារដែលបានជាប់ឃុំឃាំងនៅមន្ទីរស-២១។

ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ បញ្ជាក់ថាជនជាប់ចោទរូបនេះបានដឹងឮអំពីឋានៈដែលត្រូវទទួលបាននូវការការពាររបស់ជនស៊ីវិល និងពួកទាហានវៀតណាម។ ជនជាប់ចោទរូបនេះ បានទទួលស្គាល់ថា ខ្លួនបានដឹងថា ពួកដែលត្រូវបានចាប់ខ្លួន គឺជាពួកទាហាននៅក្នុងជួរកងទ័ពវៀតណាម ដែលត្រូវបានចាប់ខ្លួនទៅលើសមរភូមិ ឬជាជនស៊ីវិលវៀតណាម ដែលត្រូវបានចាប់ខ្លួនទៅលើទឹកដីវៀតណាមដោយកងទ័ពបដិវត្តកម្ពុជា។ ភ័ស្តុតាងបង្ហាញថា ជនជាប់ចោទរូបនេះបានទទួលស្គាល់ថា ខ្លួនបានអានបានវិភាគ និងបានធ្វើសង្ខេបពីប្រវត្តិរូប និងសកម្មភាពពីមុនៗរបស់អ្នកទោសវៀតណាមទាំងអស់មួយចំនួនផងដែរ។ ដូច្នេះគាត់បានដឹងឮទាំងស្រុងអំពីគ្រប់កាលៈទេសៈទាំងអស់ ដែលតម្រូវឲ្យគេធ្វើការចោទប្រកាន់អំពីអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។

ជាទីចុងបញ្ចប់ វាជាការមួយដ៏ច្បាស់លាស់ណាស់ដែរថា បទល្មើសនានាដែលបានរៀបរាប់មកនេះត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១នៅក្នុងបរិបទ និងដោយរួមផ្សំជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរ-

ជាតិ ពួកទាហាន និងប្រជាជនស៊ីវិលវៀតណាមត្រូវបានជាប់ឃុំនៅមន្ទីរស-២១ ដោយសារតែជម្លោះនោះភាគច្រើនត្រូវបានចាប់ខ្លួនក្នុងពេលកំពុងប្រយុទ្ធគ្នា ឬនៅពេលកំពុងលុកលុយចូលក្នុងទឹកដីវៀត-ណាមពីសំណាក់កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ។

[១១:៥៦:១៦]

ជនជាប់ចោទរូបនេះបានទទួលស្គាល់ថា ពួកវៀតណាមត្រូវបានសួរចម្លើយដើម្បីឲ្យបានចម្លើយសារភាពនានាក្នុងការបង្ហាញវៀតណាមបានឈ្លានពានកម្ពុជា ក្នុងគោលបំណងដើម្បីយកធ្វើជាឧប-សម្ព័ន្ធ។ គាត់បានទទួលស្គាល់ផងដែរថា ចម្លើយសារភាពនានាត្រូវបានផ្សព្វផ្សាយទៅតាមវិទ្យុ និងត្រូវបានប្រើប្រាស់សម្រាប់គោលដៅឃោសនា ដែលមានការទាក់ទងនឹងជម្លោះនេះ។

ឥឡូវនេះ ខ្ញុំសូមងាកមកពិភាក្សាដាច់ដោយឡែកពីគ្នា អំពីបទល្មើសនានាដែលបានរៀបរាប់មកទាំងប្រាំ ដែលបានបង្ហាញយ៉ាងច្បាស់តាមរយៈភ័ស្តុតាងថា ជាអំពើបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ បញ្ជីអ្នកទោសនានាដែលនៅសល់បានកត់ត្រាថា មានពួកឈ្លើយសឹកវៀតណាមរវាង ១៥០នាក់ ទៅច្រើនរយនាក់ និងយ៉ាងហោចណាស់មានប្រជាជនស៊ីវិលវៀតណាមចំនួន១០០នាក់ ដែលជាជនរងគ្រោះដោយសារបទល្មើសទាំងនោះ។

អំពីការឃុំជនខ្លួនស៊ីវិលដោយខុសច្បាប់។ ធាតុផ្សំតាមផ្លូវច្បាប់ដែលត្រូវបានតម្រូវឲ្យផ្តល់ជាសក្ខីកម្មនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ គឺមានលក្ខណៈដូចគ្នានឹងធាតុផ្សំនៃការដាក់ក្នុងមន្ទីរឃុំឃាំងដែលជាបទឧក្រិដ្ឋមួយប្រឆាំងនឹងមនុស្សជាតិ យ៉ាងហោចណាស់ក៏មានជនស៊ីវិលវៀតណាមចំនួន ១០០នាក់ដែរ ដែលបានត្រូវបានគេឃុំខ្លួននៅមន្ទីរស-២១ ដោយសារតែបញ្ហាសញ្ជាតិរបស់ពួកគេ។ ការឃុំខ្លួននោះគឺបានគិតគូរទុកជាមុន ហើយដែលជាលទ្ធផលចេញពីការបញ្ជានានា ដែលបានចេញពីការអនុវត្តដោយជនជាប់ចោទរូបនេះ និងថ្នាក់ក្រោមរបស់គាត់។

អំពីការដកហូតសិទ្ធិក្នុងការទទួលបាននូវការកាត់ក្តីដោយត្រឹមត្រូវ និងទៀងទាត់។ ពួកគាត់ជាប់ឃុំឃាំងជាជនជាតិវៀតណាមទាំងអស់នៅមន្ទីរស-២១ ទោះជាជនស៊ីវិល ឬយោធាក៏ដោយ ក៏សុទ្ធតែត្រូវទទួលបាននូវការធានាទៅតាមផ្លូវច្បាប់នៃនីតិវិធីត្រឹមត្រូវ និងសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្តីដោយត្រឹមត្រូវនិងទៀងទាត់។ ពួកគេមិនបានទទួលនូវសិទ្ធិបែបទាំងនេះទេ ព្រមទាំងត្រូវបានប្រហារជីវិតទាំងអស់គ្នា ដោយពុំមានការជំនុំជម្រះទៀតផង។ ដូចដែលយើងបានពិភាក្សារួចមកហើយគឺនៅពេលពេញប្រទេស ពាសពេញប្រទេសកម្ពុជាទាំងមូល នៅក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ពុំ

មានអស្ថិរភាពនៃប្រព័ន្ធច្បាប់ណាមួយដែលដំណើរការទេ ប្រព័ន្ធច្បាប់មួយដែលដំណើរការបាននេះក៏មានផងដែរនៅមន្ទីរស-២១។

[១១:៥៨:៥៣]

ដូច្នេះ វាមិនមាននីតិវិធីដ៏មានប្រសិទ្ធភាពណាមួយដែលពួកអ្នកទោសវៀតណាមនៅមន្ទីរស-២១ អាចនឹងធ្វើការតតាំងអំពីការយកពួកគេទៅក្នុងគុក ដាក់ក្នុងមន្ទីរឃុំឃាំង ឬអំពីឋានៈរបស់ពួកគេបាន ដូចដែលពួកគេត្រូវមានសិទ្ធិក្នុងការទទួលបាន តាមអនុសញ្ញានៃទីក្រុងហ្សឺណែវនោះទេ។ ក្នុងឋានៈជាប្រធានគុក ជនជាប់ចោទរូបនេះបានជាប់កាតព្វកិច្ចទៅតាមផ្លូវច្បាប់អន្តរជាតិ ដើម្បីលើកស្ទួយ ខ ចែងទាំងឡាយដែលមាននៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ សម្រាប់ពួកអ្នកទោសនៃប្រទេសដែលជាសត្រូវរបស់ខ្លួន។ យ៉ាងណាក៏ដោយគាត់ធ្លាប់ទទួលស្គាល់ថា គាត់បានដឹងឮនៅពេលនេះថាពុំមានការធានាលើវិស័យយុត្តិធម៌ ឬនីតិវិធីតាមផ្លូវច្បាប់ទេ សម្រាប់អ្នកទោសណាមួយក៏ដោយដែលនៅមន្ទីរស-២១។

សក្ខីកម្មបន្ថែមទៀត អំពីការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្ដីដ៏ត្រឹមត្រូវរបស់ពួកអ្នកទោសវៀតណាម បានលេចចេញមកពីការអនុវត្តដោយសារការថតខ្សែភាពយន្តនិងការផ្សព្វផ្សាយតាមវិទ្យុ ចម្លើយសារភាពរបស់ពួកគេសម្រាប់គោលបំណងនៃការឃោសនា។

មិនមាននៅក្នុងដំណាក់កាលណាមួយដែលពួកគេបានប្រឹងប្រែងរកភាពថ្លៃថ្នូរ និងភាពជាមនុស្សធម៌ដើម្បីការពារនៅឋានៈរបស់ពួកគេដែលត្រូវបានតម្រូវឲ្យធ្វើនោះឡើយ។ អំពីការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព។

លោកប្រធានសូមស្នូបន្តិច តើយើងត្រូវសម្រាក ឬក៏យើងអាចទៅទៀត ព្រោះឥឡូវម៉ោងដប់ពីរ?

**ប្រធានអង្គជំនុំ៖**

នៅវែងទេខាងផ្នែកភាគីជាតិ?

**លោកស្រី ជា លាង៖**

*(មិនឮសំឡេង)*

**ប្រធានអង្គជំនុំ៖**

ឥឡូវយើងដល់ពេលត្រូវសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះដើម្បីពិសាអាហារថ្ងៃត្រង់។ ហើយសវនាការនឹងលើកទៅបន្តនៅរសៀលនេះ ចាប់ពីម៉ោងមួយ

និងសាមសិបនាទី។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:០២នាទី ដល់ម៉ោង ១៣:៣១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាកិច្ចបន្តសូមអញ្ជើញសហព្រះរាជអាជ្ញាបន្តធ្វើសេចក្ដីថ្លែងនូវសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

សូមអញ្ជើញ!

**លោកស្រី ជា លាង៖**

សូមអរគុណ ហើយសូមគោរពអង្គសវនាការទាំងមូលសាជាថ្មី។ ខ្ញុំត្រូវការពេលវេលាប្រហែលជាដប់នាទីទៀត ហើយខ្ញុំនឹងផ្ទេរសេចក្ដីសន្និដ្ឋានរបស់ខ្ញុំទៅខាងសហការីរបស់ខ្ញុំជាបន្តទៀត។

អ្នកទោសវៀតណាមបានទទួលរងនូវការឈឺចាប់មិនតិចជាងជនរងគ្រោះ ដែលជាជនជាតិខ្មែរប៉ុន្មានទេនៅក្នុងមន្ទីរស-២១។ អង្គជំនុំជម្រះនេះធ្លាប់បានស្ដាប់យ៉ាងវែង ពិស្ដាររួចមកហើយអំពីការរងរបួស និងភាពមិនងាយស្រួលតាមផ្លូវកាយ ដែលបណ្ដាលមកពីលក្ខខណ្ឌអមនុស្សធម៌នៃការឃុំឃាំងនៅក្នុងមន្ទីរស-២១។ ការខ្វះខាតអាហារមិនបានគ្រប់គ្រាន់ ការថែទាំផ្នែកវេជ្ជសាស្ត្រ និងអនាម័យព្រមទាំងវិធីសម្លាប់មនុស្សដ៏អមនុស្សធម៌។ ស្រដៀងគ្នានេះដែរ ការឈឺចាប់តាមផ្លូវចិត្ត ដោយរួមទាំងការថប់អារម្មណ៍ ដោយបានពីឃើញរបួសរបស់អ្នកទោសដូចគ្នាដែលកើតឡើង។ ដោយការបំពានលើរូបរាងកាយ និងការធ្វើទារុណកម្ម ដោយមកពីឃើញអ្នកទោសដូចគ្នា ដែលបានស្លាប់ដោយសារស្លាកស្នាមមុខរបួស ជំងឺ ឬកង្វះអាហារ។ ដោយសារបានឮសំឡេងស្រែកខ្លាំងរបស់អ្នកទោសដទៃទៀតដែលកំពុងត្រូវបានគេធ្វើទារុណកម្ម រួចសម្លាប់ចោល និងដោយសារបានរស់នៅក្នុងភាពភ័យខ្លាចជាប់ជានិច្ច ពីការវាយធ្វើបាប ការធ្វើទារុណកម្ម និងការសម្លាប់ចោល។

យើងបានពិភាក្សារួចមកហើយអំពីភស្តុតាងជាច្រើន ស្តីពីចេតនាក្នុងការធ្វើឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ។ ចេតនាឧក្រិដ្ឋបែបនេះមាននៅជាប់នឹងជនជាប់ចោទ និងពួកជនទាំងឡាយដែលនៅក្រោមសិទ្ធិអំណាចរបស់ជនជាប់ចោទរូបនេះ។ គឺមិនមានការខុសប្លែកគ្នាអ្វីពីអ្នកទោសវៀតណាម បើមានអ្វីកើតឡើងបក្សកម្មុយនីស្តកម្ពុជាបានធ្វើការ-- ពីការស្អប់វៀតណាម ដោយអាចជាការលើកទឹកចិត្តដល់អ្នកដទៃទៀត ដែលបានវាយធ្វើបាបពួកអ្នកទោសឱ្យកាន់តែសាហាវឡើង និងយ៉ាងអមនុស្សធម៌កាន់តែខ្លាំងឡើងថែមទៀត ចំពោះអ្នកទោសវៀតណាមដែលជាប់ឃុំឃាំង។

[១៣:៣៤:៣៩]

**ការធ្វើទារុណកម្ម**

ធាតុផ្សំតាមផ្លូវច្បាប់ដែលត្រូវបានតម្រូវឱ្យផ្តល់សក្ខីកម្ម ពីការធ្វើទារុណកម្មថាជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាពីក្រុងហ្សឺណែវ គឺមានលក្ខណៈដូចគ្នានឹងធាតុផ្សំនៃការធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិដូច្នេះដែរ។ វាពុំមានភស្តុតាងជាក់លាក់ណាមួយដែលថាពួកអ្នកទោសវៀតណាមត្រូវបានគេធ្វើទារុណកម្មនោះទេ ប៉ុន្តែវាជាការសមហេតុផល ដោយអាចទាញថា ជាសេចក្តីសន្និដ្ឋានបានថា ពួកគេបានទទួលរងនូវការធ្វើបាបដូចនឹងអ្នកភាគច្រើនដទៃទៀតនៅមន្ទីរស-២១ដែរ។ ជាទូទៅ ការធ្វើទារុណកម្មត្រូវបានពួកអ្នកសួរចម្លើយប្រើប្រាស់ជាពិសេស ដើម្បីឱ្យបាននូវចម្លើយសារភាព។ អ្នកទោសណាដែលរឹងរូស នឹងត្រូវរងទទួលទារុណកម្ម កាន់តែច្រើនជាងអ្នកដែលចង់ឆ្លើយសារភាព។

**អំពីការធ្វើបាបដោយអមនុស្សធម៌**

ភស្តុតាងទាំងអស់អំពីរបៀបដែលមន្ទីរស-២១ ធ្វើប្រតិបត្តិការ។ អំពីលក្ខខណ្ឌនៃការឃុំខ្លួនដែលប្រកបទៅដោយបំណងអាក្រក់ និងអំពីអាកប្បកិរិយារបស់បុគ្គលបង្ហាញថា ពួកអ្នកទោសវៀត-ណាមពុំមែនត្រូវបានធ្វើបាបដោយអមនុស្សធម៌តិចជាងដៃគូដែលជាជនជាតិខ្មែរនោះទេ។

ការធ្វើបាបដោយអមនុស្សធម៌ ដែលជាអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គ្របដណ្តប់មិនត្រឹមតែទៅលើអំពើនានានៃការធ្វើទារុណកម្ម ឬអំពើដែលបង្កឱ្យមានការឈឺចាប់ដោយចេតនាប៉ុណ្ណោះទេ។ ក៏ប៉ុន្តែ ថែមទាំងអំពើដទៃដែលរំលោភទៅលើគោលការណ៍នៃការឃុំគ្រងតាមបែបមនុស្សធម៌ ជាពិសេស គឺការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស។

នៅក្នុងវិសាលភាពនៃអំពើរបស់បុគ្គលដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងអ្នកទោសវៀតណាម

អង្គជំនុំជម្រះសាលាដំបូងអាចនឹងមិនបានពិចារណាថា ជាអំពើនានានៃការធ្វើទារុណកម្ម ឬអំពើដែលបង្កឲ្យមានការឈឺចាប់ដោយចេតនាទេ។ នោះវាពិតជាពុំបានមានភាពរលូនទៅនឹងការគ្រប់គ្រងតាមបែបមនុស្សធម៌ ឬសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ។

ការធ្វើមនុស្សឃាតដោយចេតនា។ អ្នកទោសវៀតណាមទាំងអស់នៅមន្ទីរស-២១ ត្រូវបានសម្លាប់ចោល ស្ថិតក្នុងប្រភេទនៃបទល្មើសនេះហើយ។ សក្ខីកម្មរបស់សាក្សី រូបថត ព័ត៌មាន ដែលបានមកពីមន្ទីរស-២១ ចម្លើយសារភាព និងការផ្សព្វផ្សាយតាមវិទ្យុ ដែលនៅមានជាឯកសារនៅឡើយ គឺទាំងអស់នេះហើយ ដែលបង្ហាញថាមានការប្រហារជីវិត ដោយមិនបានគិតគូរទុកជាមុនទៅលើពួកអ្នកទោសវៀតណាម។ ជនជាប់ចោទរូបនេះបានទទួលស្គាល់ថា ពុំមានជនជាតិវៀតណាមណាម្នាក់ត្រូវបានទុកឲ្យរួចជីវិតទេ។

[១៣:៣៧:៣១]

**បទឧក្រិដ្ឋផ្ទុយនឹងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦**

ឥឡូវនេះ ខ្ញុំសូមចូលទៅដល់ប្រភេទទីបី និងជាប្រភេទចុងក្រោយនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺបទឧក្រិដ្ឋមនុស្សឃាត និងការធ្វើទារុណកម្ម ដែលជាការរំលោភលើច្បាប់ព្រហ្មទណ្ឌជាតិកម្ពុជា គឺច្បាប់ព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

ទោះបីជាច្បាប់ព្រហ្មទណ្ឌអន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ អាចហាមឃាត់នូវទង្វើព្រហ្មទណ្ឌក្នុងកម្រិតនៃភាពធ្ងន់ធ្ងរខុសៗគ្នាក៏ដោយ ក៏ច្បាប់ព្រហ្មទណ្ឌជាតិរបស់យើងមិនមែនអត់តម្លៃក្នុងការប្រតិបត្តិការនោះដែរ។

ដូចដែលតុលាការនេះជាតុលាការសម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាដំបូងបង្អស់ និងសំខាន់បំផុតត្រូវធ្វើឲ្យសាធារណជនមើលឃើញថា ច្បាប់ជាតិត្រូវបានគោរព។ ដោយការចោទប្រកាន់តាមបទល្មើសតាមច្បាប់ជាតិបង្ហាញឲ្យឃើញថា ច្បាប់ជាតិកម្ពុជាអាចការពារពួកគេបានក្នុងនាមសហគមន៍មួយ។ ដោយសារតែតុលាការនេះ គឺជាតុលាការកម្ពុជាអន្តរតួបនីយកម្ម ការចោទប្រកាន់ឧក្រិដ្ឋកម្មជាតិ គឺជាជួយពន្លឿននូវស្មារតីនៃភាពជាម្ចាស់នៃកិច្ចដំណើរការនីតិវិធីតុលាការសម្រាប់ប្រជាជនទាំងមូលផង និងតុលាការកម្ពុជាផង។

យុត្តិសាស្ត្រក្នុងករណីនេះ និងករណីដទៃផ្សេងទៀតស្តីពីច្បាប់ជាតិ ទំនងជានឹងជួយដល់ទម្លាប់ក្នុងការអនុវត្តច្បាប់ក្នុងតុលាការជាតិ។ ទោះបីជាពុំមានតុលាការនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដើម្បី

ប្រតិបត្តិក្រមព្រហ្មទណ្ឌកម្ពុជាក្នុងឆ្នាំ១៩៥៦ក៏ដោយ ក៏ក្រមនេះនៅតែមានតម្លៃជាច្បាប់ព្រហ្មទណ្ឌនៅក្នុងប្រទេសជាដដែល នៅពេលដែលពួកខ្មែរក្រហមឡើងកាន់អំណាច។ ទោះជាយ៉ាងណាក៏ដោយ ក៏ការរុះរើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការឲ្យចាកចេញឲ្យអស់ពីទីក្រុង និងការធ្វើមនុស្សឃាតទៅលើពួកចៅក្រម ពួកមេធាវីការពារក្តីនានាពុំបានដកហូតនូវកាតព្វកិច្ចជាអន្តរជាតិរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការធានាថា ពួកដែលបានប្រព្រឹត្តនូវឧក្រិដ្ឋធ្ងន់ធ្ងរនឹងត្រូវបាននាំខ្លួនយកទៅកាន់តុលាការទៅតាមច្បាប់ក្នុងប្រទេសនោះឡើយ។ មិនថាជាការលើកទឹកចិត្តណាមួយក៏ដោយ ដែលនាំឲ្យជនជាប់ចោទរូបនេះ និងថ្នាក់ក្រោមរបស់គាត់បានទទួលស្គាល់នូវទង្វើនៅមន្ទីរស-២១នោះទេ។ គឺក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ នៅតែបានកំណត់និយមន័យយ៉ាងច្បាស់លាស់ថា អំពើរបស់ពួកនោះគឺជាបទល្មើសព្រហ្មទណ្ឌ។

[១៣:៤០:២៥]

ក្នុងមាត្រា៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់អំណាចឲ្យអង្គជំនុំជម្រះធ្វើការកាត់សេចក្តីទៅលើជនសង្ស័យនានា ពីការប្រព្រឹត្តិបទឧក្រិដ្ឋជាក់លាក់មួយចំនួនដែលផ្ទុយនឹងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ ភ័ស្តុតាងបង្ហាញហួសពីវិមតិសង្ស័យ ឧក្រិដ្ឋកម្មមានពីរក្នុងចំណោមឧក្រិដ្ឋទាំងនោះមាន មនុស្សឃាត និងអំពើទារុណកម្មត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១។

**អំពីមនុស្សឃាត**

មានអំពើមនុស្សចំនួនពីរដែលបានដាក់ជាបទឧក្រិដ្ឋនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ គឺអំពើមនុស្សដោយបានគិតទុកជាមុន ដែលកើតឡើងមកពីអំពើទាំងឡាយដែលបានប្រព្រឹត្ត ឬមានចេតនាគិតគូរទុកជាមុនក្នុងបំណងធ្វើឲ្យស្លាប់ និងការស្លាប់ដែលកើតមកពីអំពើដោយមានការគិតគូរទុកជាមុនក្នុងបំណងធ្វើឲ្យមានរបួស។

អំពើមនុស្សឃាតដោយគិតទុកជាមុនគឺជាមូលហេតុនៃការស្លាប់ភាគច្រើនបំផុតនៅមន្ទីរស-២១ ការស្លាប់ដោយការអំពើនានា ដែលបានគិតគូរទុកជាមុនដូចជា អំពើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការខ្វះអាហារ អនាម័យ និងការថែទាំផ្នែកវេជ្ជសាស្ត្រមិនបានគ្រប់គ្រាន់ ដែលបានតម្រូវដល់ពួកដែលមិនទាន់បានរស់នៅបានយូរល្មមត្រូវបានប្រហារជីវិតចោល។

**អំពើទារុណកម្ម**

ស្រដៀងគ្នានេះដែរ មានអំពើទារុណកម្មចំនួនពីរផ្សេងគ្នា ដែលបានដាក់បទឧក្រិដ្ឋនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ៥៦ ត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ គឺអំពើទារុណកម្ម ដែលត្រូវបានប្រព្រឹត្តដោយមាន

ចេតនា ដើម្បីឲ្យបានមកព័ត៌មានដែលមានប្រយោជន៍នៅក្នុងការប្រព្រឹត្តិបទឧក្រិដ្ឋ ឬមជ្ឈិម តាមរយៈការបង្ករបួសស្នាម និងអំពើទារុណកម្ម ដែលត្រូវបានប្រព្រឹត្តនៅក្នុងគំនិតមួយ ដើម្បីធ្វើការបង្ក្រាប ឬការធ្វើអំពើសាហាវយង់ឃ្នង។ អំពើទារុណកម្ម គឺត្រូវបានបង្កឡើងដោយមានការគិតគូរជាមុនទៅលើពួកអ្នកទោសនានានៅមន្ទីរស-២១ ដែលមានចេតនាដើម្បីឲ្យបានមកនូវចម្លើយសារភាព។ ព័ត៌មានដែលបានដកស្រង់ចេញពីចម្លើយសារភាពទាំងនេះ នាំឲ្យមានការចាប់ខ្លួនពួកអ្នកដែលត្រូវបានគេឆ្លើយដាក់ថាជាខ្មាំង។ តែពេលក្រោយមកពួកនេះត្រូវបានគេប្រើនូវអំពើទារុណកម្មទៅលើ និងសម្លាប់ចោល។ បន្ថែមលើនេះវាមិនមានការសង្ស័យអ្វីទៀតដែរ ពេញមួយរយៈកាលនៃការប្រតិបត្តិការនៅមន្ទីរស-២១ អំពើទារុណកម្មត្រូវបានគេប្រើជាឧបករណ៍ ដើម្បីបង្ក្រាបទៅលើពួកអ្នកទោស។

[១៣:៤៣:១២]

គំនិតអំពីអំពើសាហាវយង់ឃ្នងបានដំណើរការនៅពាសពេញគុកនេះទាំងនេះមូល ហើយបានរកឃើញនូវការសម្តែងចេញមកយ៉ាងស្អុតរន្ធត់នៅក្នុងទម្រង់ដ៏ឃោរឃៅនៃអំពើទារុណកម្ម ដែលត្រូវបានចេញបញ្ជាដោយជនជាប់ចោទរូបនេះ និងដែលត្រូវបានអនុញ្ញាតដោយពួកថ្នាក់ក្រោមរបស់គាត់។

ហើយបន្ទាប់ទៅនេះ ខ្ញុំប្រគល់ឲ្យសហការីរបស់ខ្ញុំធ្វើការសេចក្តីសន្និដ្ឋានទីពីរ ដែលជាផ្នែកភាគបញ្ចប់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីលៀម ស្មីត៖**

*(គ្មានការបកប្រែ)*

[១៣:៤៥:២០]

**លោក វីលៀម ស្មីត៖**

ខ្ញុំសូមលំឱនកាយជាមួយសហការីរបស់ខ្ញុំ គោរពពីទីនេះទៅ ដើម្បីបន្តជួយដល់អង្គជំនុំជម្រះធានាដល់ការស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះនៅមន្ទីរសន្តិសុខស-២១។ ប្រជាជនកម្ពុជាអាចនឹងសួរយ៉ាងត្រឹមត្រូវថា តើយុត្តិធម៌ហ្នឹងវាជាអ្វីទៅសម្រាប់បុរស ស្ត្រី និង កុមារ ដែលត្រូវបានគេសម្លាប់យ៉ាងឃោរឃៅ? ហើយថាតើយុត្តិធម៌វាមានន័យថាម៉េចសម្រាប់ទុក្ខសោករបស់គាត់ និងក្រុមគ្រួសាររបស់គាត់ដែលទទួលការឈឺចាប់ដ៏យូរអង្វែងនេះ។

ការសម្រេចសេចក្ដីរបស់អស់លោក លោកស្រី ចៅក្រមទាំងអស់ មិនអាចឲ្យអ្នកទាំងអស់គ្នាវិលមកសភាពដើមវិញបានទេ គ្រាន់តែអនុញ្ញាតឲ្យកុមារទាំងអស់នោះ គឺថាអាចក្រឡេកទៅមើលអ្វីៗថ្មីៗទាំងអស់ ឲ្យក្មេងៗទាំងអស់នោះលេងនៅតាមដងផ្លូវ ឲ្យយុវវ័យទាំងឡាយអាចមានការរាំរែកកំសាន្តបាន ឲ្យយុវវ័យទាំងអស់អាចមានសេចក្ដីស្រលាញ់គ្នាទៅវិញទៅមក ឲ្យមាតាបិតាទាំងអស់នោះឱបរឹតនូវកូនជាទីស្រលាញ់របស់ខ្លួន និងឲ្យមាតាបិតាទាំងអស់នោះមានមោទនភាពចំពោះអាយុជីវិតដែលនៅបន្សល់ជាចុងក្រោយពួកគាត់។

សម្រាប់ជនរងគ្រោះនៅស-២១ គឺថាបទពិសោធន៍ទាំងអស់នេះត្រូវបានកាត់ផ្ដាច់តែម្ដង។

ការងាររបស់យើងខ្ញុំក្នុងនាមជាសហព្រះរាជអាជ្ញា គឺដើមជួយដល់លោក លោកស្រី ចៅក្រមធានាឲ្យមាននូវយុត្តិធម៌ ញែកចេញពីគ្នាអំពីសាលក្រមទាំងអស់នេះចេញពីការវិនិច្ឆ័យសេចក្ដីទៅលើមនុស្សជាងដប់ពីរពាន់នាក់ ដែលជនជាប់ចោទបានសម្រេចនៅស-២១។

យុត្តិធម៌អាចនឹងប្រព្រឹត្តទៅបានដរាបណាមានការអនុវត្តនូវច្បាប់អ.វ.ត.កគឺច្បាប់ដែលទាមទារឲ្យមានសវនាការប្រកបដោយយុត្តិធម៌ ច្បាប់ទាមទារឲ្យមានការផ្ដន្ទាទោសដោយសំអាងទៅលើអង្គហេតុដែលលើសពីវិមតិសង្ស័យ និងច្បាប់ដែលតម្រូវឲ្យការផ្ដន្ទាទោសរបស់លោក លោកស្រី ចៅក្រមត្រូវតែស្របទៅនឹងបទដ្ឋានអន្តរជាតិនៃភាពត្រឹមត្រូវ។

ការផ្ដន្ទាទោសឲ្យបានត្រឹមត្រូវនៅក្នុងច្បាប់ព្រហ្មទណ្ឌ គឺមិនមែនជាការសងសឹកទេ ក៏ប៉ុន្តែជាការដាក់ទណ្ឌកម្ម និងជាការធ្វើឲ្យរាងចាល។ វាជាមធ្យោបាយមួយរបស់សង្គមដើម្បីបង្ហាញឲ្យឃើញថាមនុស្សទាំងអស់ត្រូវតែមានសេចក្ដីថ្លៃថ្នូរទទួលបាននូវការគោរព ហើយសេចក្ដីថ្លៃថ្នូរទាំងអស់នោះត្រូវតែគេគោរព។ វាជាមធ្យោបាយមួយក្នុងការបញ្ជូនសារទៅដល់អ្នកដទៃទាំងឡាយណា ដែលមានបំណងចង់ប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នានេះ ប្រឆាំងទៅនឹងមនុស្សជាតិជាទីស្រលាញ់របស់ខ្លួន។

[១៣:៤៨:២៧]

នៅក្នុងករណីនេះ សហគមន៍អន្តរជាតិក៏ដូចជាប្រទេសកម្ពុជា ស-២១គឺមិនត្រូវកើតមានឡើងជាថ្មីម្ដងទៀតឡើយ។ ដូច្នេះ ថាតើការវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវសម្រាប់ជនជាប់នោះគឺជាអ្វីទៅ? គឺវាអាស្រ័យទៅលើភាពធ្ងន់ធ្ងរទៅលើឧក្រិដ្ឋកម្ម ផលប៉ះពាល់មកលើជនរងគ្រោះ និងតួនាទីរបស់ជនជាប់ចោទ។ តើលោក លោកស្រី ចៅក្រម ជឿថា ជឿទេនៅពេលគាត់និយាយថា គាត់ជាចំណាប់ផ្ទូរនិងជាអ្នកទោសនៃរបបនោះពីឆ្នាំ១៩៧១ ដល់ ពាក់កណ្ដាលទសវត្សរ៍ទី៩០?

អ្នកទោស និងចំណាប់ផ្ទះដែលត្រូវបានគេបង្ខំឲ្យសម្លាប់មនុស្សធ្វើទារុណកម្មមនុស្សពីមួយថ្ងៃទៅមួយថ្ងៃ ប្រឆាំងទៅនឹងឆន្ទៈរបស់ខ្លួន មិនស្របទៅនឹងឆន្ទៈរបស់ខ្លួន នឹងស្ថិតនៅក្រោមការគំរាមកំហែងដល់ជីវិត ដែលគ្មានឱកាសគេចខ្លួននោះ។ គាត់ជាអ្នកប្រព្រឹត្តនូវបទឧក្រិដ្ឋកម្មទាំងអស់នេះ ចូលរួមសម្លាប់ជាប្រព័ន្ធតែម្តង។

លោក លោកស្រី ចៅក្រមទាំងអស់ យើងបានលើកឡើងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរហើយនិងលើកជូននៅក្នុងថ្ងៃនេះម្តងទៀត ដែលថាជនជាប់ចោទមិនមែនជាអ្នកទោស ហើយក៏មិនមែនចំណាប់ផ្ទះ ហើយក៏មិនមែនជាជនរងគ្រោះដែរ។ ភស្តុតាងបានបង្ហាញផ្ទុយពីនេះ វាបានបង្ហាញយ៉ាងច្បាស់ហើយថា គាត់គឺជាមនុស្សមួយដែលមានមនោគមវិជ្ជាខ្ពង់ខ្ពស់ ជាជនបដិវត្តន៍ បក្សកុម្មុយនីស្តកម្ពុជាពិតៗ ជាអ្នកគាំទ្រដែលបានចូលរួមអ្វីៗទាំងអស់ដើម្បីបុព្វហេតុរបស់គាត់។ គាត់រៀបចំខ្លួនជាស្រេច ដើម្បីធ្វើទារុណកម្មនិងសម្លាប់មនុស្សប្រកបដោយចេតនា សម្រាប់ជាចំណីអាហាររបស់បដិវត្តន៍នេះ ដោយមិនគិតឃើញថា អំពើនោះវាសាហាវយង់ឃ្នងបែបណានោះទេ។

លោក លោកស្រី ចៅក្រមជាទីគោរព, នេះគឺជាចំណុចដែលលេចធ្លោ ចំណុចខុសគ្នាយ៉ាងលេចធ្លោវាងសហព្រះរាជអាជ្ញាហើយនិងមេធាវីការពារ។ សេចក្តីសម្រេចរបស់អស់លោក លោកស្រីចៅក្រមមានសារសំខាន់ណាស់ដើម្បីជួយបង្កើតនូវ ដាក់ចេញនូវការទទួលខុសត្រូវនិងផលវិបាកនៃការសម្រេចទៅលើការផ្តន្ទាទោសមួយឲ្យបានត្រឹមត្រូវ។ ប៉ុន្តែសូមចងចាំថា ផ្នែកនេះសារណារបស់យើងខ្ញុំនឹងចង្អុលបង្ហាញជូនអស់លោក លោកស្រី ចៅក្រម និងវិសាលភាពនៃការចូលរួមរបស់ជនជាប់ចោទ។ ហើយបន្ទាប់មក ការលើកឡើងទីពីរថា តើគាត់បានចូលរួមនៅក្នុងឧក្រិដ្ឋកម្ម វាមានលក្ខណៈផ្លូវច្បាប់ដោយរបៀបណា? និងលើជូនអស់លោក លោកស្រីនូវកត្តាពាក់ព័ន្ធ ដើម្បីយកមកពិចារណានៅពេលធ្វើការផ្តន្ទាទោស។

[១៣:៥១:២៤]

ប៉ុន្តែ ដំបូងខ្ញុំសូមលើកឡើងអំពីសកម្មភាពរបស់ជនជាប់ចោទនៅក្នុងបរិបទមួយដ៏ទូលំទូលាយ។

នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យជនជាប់ចោទត្រូវបានគេដំឡើងឋានៈខ្ពង់ខ្ពស់ ហើយមានតួនាទីសំខាន់ មានជីវិតរស់នៅខ្ពង់ខ្ពស់នៅពេលដែលសមាជិកដទៃទៀតនៅក្នុងរបបនេះត្រូវបានគេបោសសម្អាតកម្ទេច។ នេះគឺវាមិនមែនជាការគាប់ជួននោះទេ។ ហើយលើសពីជនសាមញ្ញាធម្មតា លើសពីសមាជិកបក្សធម្មតា ហើយការដែលបានជាដំណែងមេសន្តិសុខ មិនមែនដោយការចៃដន្យ គឺថាគាត់បានទាមទារ

គាត់បានប្រឹតប្រៀងខ្លួនគាត់ ដើម្បីទទួលបានបុព្វសិទ្ធិនៅស-២១ ជាប្រធានស-២១ ដោយការបំពេញកិច្ចការយ៉ាងលំបាក និងការយកចិត្តទុកដាក់បំផុត។

ភ័ស្តុតាងបង្ហាញថា គាត់គឺជាអ្នកជឿដ៏មុតមាំនៅក្នុងបុព្វហេតុកុម្មុយនីស្តដែលចង់កំចាត់ចោលនូវខ្មាំងរបស់របបនេះ។ ហេតុដូច្នេះ គាត់បានរៀបចំនូវទំនាក់ទំនងដ៏រឹងមាំ ជិតជិតជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយបានប្រព្រឹត្តនូវឧក្រិដ្ឋឃោរឃៅព្រៃផ្សៃនៅស-២១ នៅក្រោមការត្រួតត្រារបស់អ្នកទាំងនោះ គាត់បានបន្តធ្វើការជាមួយអស់រយៈពេលជិតដប់ប្រាំឆ្នាំ ក្រោយពីរបបនេះដួលរលំទៅ។

បន្ទាប់ពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គាត់ទទួលបាននូវបុព្វសិទ្ធ ហើយគាត់បានទទួលតួនាទីដ៏គួរឲ្យទុកចិត្តនៅក្នុងកែវភ្នែលថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ដែលគាត់បានជួបគ្នានៅស្ថានីយអយស្ម័យយាននៅទីក្រុងភ្នំពេញនៅចុងខែមិថុនា ឆ្នាំ១៩៧៥ ក្នុងពេលនោះ គឺគាត់មានការបានចូលរួមពាក់ព័ន្ធដោយផ្ទាល់នៃការបង្កើតមន្ទីរសន្តិសុខស-២១។ គាត់គឺជាមនុស្សតែម្នាក់ក្នុងចំណោមមនុស្សពីរនាក់ដែលត្រូវបាន សុន សេន កោះទៅប្រជុំនៅស្ថានីយរថភ្លើងនៅថ្ងៃទី១៥ សីហា ៧៥ ទាក់ទងនឹងការបង្កើតមន្ទីរសន្តិសុខស-២១។ ជនជាប់ចោទខ្លួនឯងបាននិយាយថា គាត់គឺជាភ្នែកច្រមុះនៅស-២១។ គាត់បានជះឥទ្ធិពលដោយប្រើប្រាស់ឈ្មោះ ដែលអក្សរ២១ នេះ គឺជាលេខទំនាក់ទំនងផ្ទាល់របស់គាត់។

ភ័ស្តុតាងបានបង្ហាញថា មន្ទីរសន្តិសុខស-២១ គឺជាមោទនភាពវិជ្ជាជីវៈរបស់គាត់ ដោយសារវាជាឈ្មោះទំនាក់ទំនងរបស់គាត់ ជាតថភាពពិតគឺស-២១របស់គាត់។ ក្នុងការជ្រើសរើសបុគ្គលិកមន្ទីរស-២១ ជនជាប់ចោទជ្រើសរើសអ្នកស្មោះចម្លើយស្មោះបំផុតមកពីម-១៣ មកធ្វើការនៅស-២១ ដោយការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងអស់នេះ។ គាត់អាចជឿជាក់ទៅលើពួកគេទាំងអស់នេះ គាត់ចង់រៀបចំ និងគ្រប់គ្រងនូវម៉ាស៊ីននៅស-២១ ប៉ុន្តែគាត់មិនចង់ធ្វើកិច្ចដ៏ស្មោគរោគនេះដោយខ្លួនឯងនោះទេ។ គាត់រៀបចំខ្លួនសម្រាប់តួនាទីដ៏ហ្មត់ចត់ គាត់ប្រមូលនូវសៀវភៅជំនាញៗទាក់ទងទៅនឹងកម្មវត្ថុធ្វើទារុណកម្មប្រមូលព័ត៌មាន។

[១៣:៥៤:៥៤]

គួរឲ្យភ្ញាក់ផ្អើលនោះ សាមសិបប្អូនឆ្នាំក្រោយមក គឺគាត់អត់បានដកស្រង់សម្តីនេះនៅចំពោះមុខអង្គជំនុំជម្រះ នេះគឺជាការដែលគួរឲ្យហួសចិត្តបំផុត ដែលគាត់អះអាងថា គាត់អត់មានពេលបានអានសៀវភៅទាំងអស់នោះ។ ហើយគាត់ក៏បានប្រមូលឯកសារមកពីក្រសួង មកពីអគារ មកពីផ្ទះរបស់

អតីតមន្ត្រី លន់ នល់ ភ្នំពេញ នៅក្រោមការសួរចម្លើយគាត់ថា គាត់ប្រមូលទាំងអស់នេះដើម្បីចាប់ខ្លួនមន្ត្រីក្នុងរបបចាស់។

នៅដើមឆ្នាំ គាត់ជាអនុប្រធានស-២១ គាត់ធ្វើការពិបាកក្នុងការបង្កើតឲ្យមានប្រតិបត្តិការនេះ គាត់បង្រៀនរបៀបបច្ចេកទេសសួរចម្លើយ ហើយគាត់បណ្ដុះបណ្ដាលផ្នែកនយោបាយ គាត់ជាប្រធានផ្នែកសួរចម្លើយ គាត់ធ្វើការយកចិត្តទុកដាក់តាមដាន តាមស្វែងរកខ្មាំង ដោយបញ្ជាឲ្យមានការសួរចម្លើយនៅក្នុងនោះ។

នៅក្នុងរយៈប្រាំមួយខែនៅស-២១ ជនជាប់ចោទត្រូវបានបង្កើនតួនាទីទៅជាប្រធាន។ វាច្បាស់ណាស់ ដែលថាភ័ស្តុតាងបង្ហាញថា គាត់គឺជាអ្នកដែលមានជំនាញបច្ចេកទេសក្នុងការប្រមូលព័ត៌មាន ហើយគាត់ទទួលបាននូវការទុកចិត្តយ៉ាងខ្លាំងជាមួយនឹងថ្នាក់ដឹកនាំជាន់ខ្ពស់ ជាងអតីតប្រធានមុនឈ្មោះណាត ដែលក្រោយមកត្រូវបានជាប់នៅមន្ទីរសន្តិសុខស-២១។ ក្រោយពីតែងតាំងជាប្រធានស្ទើរតែបីឆ្នាំក្រោយមកជនជាប់ចោទគឺបានបំពេញតួនាទី គួរឲ្យទុកចិត្តបំផុតពីសំណាក់មេរបស់គាត់។

តាមរយៈភាពជាមេដឹកនាំពីខែមីនា ១៩៧៦ នៅស-២១ គាត់បានសម្លាប់នូវខ្មាំង ហើយជនជាប់ចោទបានក្លាយទៅជាទំនាក់ទំនងដ៏សំខាន់រវាងគោលនយោបាយព្រហ្មទណ្ឌរបស់របបនេះ និងការកាប់សម្លាប់អ្នកទាំងអស់នោះ។ នៅខាងក្រៅស-២១ គាត់ធ្វើការជិតដិតជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បន្តផ្តល់យោបល់ និងរាយការណ៍អំពីសារសំខាន់នៃការសារភាពរបស់អ្នកទោស ហើយដោយសម្របសម្រួលនូវអត្តសញ្ញាណ និងការកម្ទេចខ្មាំង ហើយសំខាន់បំផុតគឺថា គាត់បានដុតបញ្ឆេះការភ័យខ្លាចរបស់របបនេះ។ ដូចដែលយើងបានឮពីអ្នកជំនាញចិត្តសាស្ត្រ គឺគាត់មានទំនាក់ទំនងយ៉ាងជិតដិតជាមួយនឹងមេដឹកនាំទាំងនេះ។ គាត់មិនមែនដោយសារគ្រាន់តែផ្នែកមួយនៃកាតព្វកិច្ចរបស់គាត់ទេ ប៉ុន្តែដោយសារតែតម្រូវការចាំបាច់របស់គាត់ ដើម្បីទទួលបាននូវឱវាទ ហើយនិងចំណង់ចិត្តរបស់គាត់ក្នុងការយកចិត្ត យកថ្លើម និងទទួលបាននូវការសរសើរចំពោះកិច្ចការនេះ។

ក្នុងអំឡុងពេលដប់ប្រាំបីខែ ក្នុងនាមជាប្រធានជនជាប់ចោទបានរាយការណ៍ទៅឲ្យ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃអគ្គសេនាធិការនៃកងទ័ពកម្ពុជា នៅក្នុងអំឡុងពេលនេះ ជនជាប់ចោទបាននិយាយយ៉ាងមោទនភាពចំពោះ សុន សេន ដោយហៅគាត់ថា លោកគ្រូ សាស្ត្រាចារ្យ ឬក៏ជាមេដឹកនាំ។ មនុស្សទាំងពីរនេះបានចែករំលែកពិភាក្សាគ្នា ដើម្បីអនុវត្តនូវយុទ្ធសាស្ត្រកុម្មុយនីស្ត ហើយ សុន សេន បានណែនាំជនជាប់ចោទឲ្យក្លាយទៅជាសមាជិកពេញសិទ្ធិនៅក្នុងបក្សនៅក្នុងឆ្នាំ១៩៦៩។ ជនជាប់ចោទ

រៀបរាប់ សុន សេន ថាគឺជាអ្នកដែលមានឥទ្ធិពលខ្លាំងបំផុតមកលើគាត់ ហើយ សុន សេន បានពិចារណាជនជាប់ចោទគឺជាអ្នកដើរតាមដ៏ស្មោះស្ម័គ្ររបស់គាត់។

[១៣:៥៨:២៥]

ដូចដែលយើងបានលើកពីជនជាប់រួចមកហើយ សុន សេន ត្រូវបានជំនួសដោយ នួន ជា នៅក្នុងឆ្នាំ១៩៧៧ នៅពេលដែលមានសង្គ្រាមជាមួយនឹងប្រទេសវៀតណាម។ ជំនួសឲ្យការទទួលបានតួនាទីជាប្រធាននៅក្នុងរយៈពេលធ្វើការបោសសម្អាតដ៏តឹងតែងនេះ រហូតមកដល់ចុងបញ្ចប់នៃរបបនេះ។

ឥឡូវនេះ ខ្ញុំសូមពិភាក្សាអំពីវិសាលភាពរបស់អាជ្ញាធររបស់ជនជាប់នៅស-២១ នៅក្នុងពេលស៊ើបអង្កេត គាត់បាននៅស-២១ ហើយគាត់គឺជា គាត់គ្រាន់តែជាប្រធានដែលមានតែឈ្មោះតែប៉ុណ្ណោះ ហើយគាត់បានពន្យល់ពីអំណាចទាំងអស់នៅស-២១ថា បើខ្ញុំចង់ដឹងអ្វីមួយ ខ្ញុំអាចដឹងបាន ខ្ញុំអាចសួរអ្នកណាក៏បានឲ្យរាយការណ៍ប្រាប់ខ្ញុំ ខ្ញុំអាចបញ្ជាប់អ្វីៗ ដែលខ្ញុំចង់ដឹកនាំអ្វីទាំងអស់ ខ្ញុំអាចធ្វើបែបនោះបាន។ មានន័យថា គ្មានអ្វីនឹងអាចកើតឡើងបានទេនៅស-២១ ដោយគាត់មិនបានដឹង ឬមិនបានយល់ព្រមនេះទេ។

យើងក៏បានឃើញតាំងពីលើកដំបូងនៅក្នុងសវនាការដែលជនជាប់ចោទគឺថាជាមនុស្សហ្មត់ចត់ ជាមនុស្សប្រកបដោយហេតុផល និងជាមនុស្សគិតមមៃជាប់ជានិច្ច គាត់ជាអ្នកដែលមានចងចាំបានយ៉ាងល្អ ទោះបីគាត់ចាប់យកចោះៗក៏ដោយ។ មិនមានអ្វីគួរឲ្យសង្ស័យទេថា នៅក្រោយអំណាចរបស់គាត់គឺវិន័យត្រូវតែគោរព បញ្ជាត្រូវតែគោរពជាដាច់ខាត។ នេះគឺជាចំណុចគួរឲ្យកត់សម្គាល់ ដែលត្រូវចងចាំថា បុគ្គលិកនៅក្រោមការត្រួតត្រានៅស-២១ គឺមានរហូតទៅដល់ជាងពីរពាន់នាក់។ ភ័ស្តុតាងបានបង្ហាញថាបុគ្គលិកគោរពវិន័យនៅស-២១ គឺជាលទ្ធផលដោយសារការជ្រើសរើសដោយយកចិត្តទុកដាក់របស់ជនជាប់ចោទ និងជំនាញបណ្តុះបណ្តាល ហើយនិងការអនុវត្តនូវវិន័យរបៀបជាយោធារបស់គាត់ នូវគោលនយោបាយក្នុងការចាប់ចង និងសម្លាប់សម្រាប់អ្នកណាដែលមិនអនុវត្តតាមគោលនយោបាយដើម្បីបំពេញនូវកិច្ចការច្បាស់លាស់ ហើយអ្នកដែលមានកំហុសដូចជាដេកនៅពេលបំពេញការងារ ឬក៏បង្ហាញឈ្មោះអ្នកទោសឲ្យបានគេដឹង ត្រូវតែទទួលទារុណកម្ម។

យើងបានឮសួរអតីតអ្នកយាមនៅស-២១ ឈ្មោះ សោម ម៉េត, គក ស្រស់, ចៀម សឿ, សេក ដន, ប្រាក់ ខន បានផ្តល់សក្ខីកម្មចំពោះការអនុវត្តដ៏អត់មេត្តានូវវិន័យទាំងអស់នេះ ដើម្បីធ្វើឲ្យបុគ្គលិកទាំងអស់មានការភ័យខ្លាច។ វិន័យទាំងអស់នេះត្រូវបានរៀបចំឡើងដើម្បីទប់ស្កាត់កុំឲ្យអ្នកទោសរត់ វា

ជាកិច្ចការមួយដ៏លំបាក ដែលជនជាប់ចោទត្រូវទទួលខុសត្រូវទៅលើអ្នកទោសជាង១.៥០០នាក់ នៅបរិវេណស-២១ ហើយអាចលើសច្រើនជាងនេះទៅទៀតនៅឯព្រៃស។ គាត់ធានាឲ្យបានច្បាស់ថា ក្រិត្យក្រមត្រូវតែយកពិចារណាឲ្យបានហ្មត់ចត់។

ហ៊ុយ ស្រែ ប្រធានមន្ទីរសន្តិសុខព្រៃស ហើយដែលជាអ្នកផ្តល់ប្រឹក្សាដ៏ជិតដិតរបស់ជនជាប់ចោទត្រូវបានចាប់ខ្លួន បន្ទាប់ពីមានការរត់គេចខ្លួនរបស់អ្នកប្រតិបត្តិការវិទ្យុទាក់ទងមួយ។ ជនជាប់ចោទបានសម្លាប់ ហ៊ុយ ស្រែ។ ហើយទោះបីសាមសិបឆ្នាំក្រោយមកក៏ដោយ ដែលគាត់បានផ្តល់សក្ខីកម្មថា ការស្លាប់របស់ ហ៊ុយ ស្រែ គឺមិនសមហេតុផលនេះទេ។ ផ្ទុយទៅវិញ ការរំលោភសេពសន្ថវៈទៅលើអ្នកទោស គឺអ្នករំលោភទៅលើអ្នកទោស គឺមិនត្រូវបានផ្តន្ទាទោសនេះទេ។ ទោះជាយ៉ាងណាក៏ដោយ វិន័យទាំងអស់នេះ គឺជនជាប់ចោទបានអនុវត្តដ៏ហ្មត់ចត់។

បុគ្គលិកមន្ទីរសន្តិសុខឈ្មោះ ណាត ដែលមកពីកងពល០៣ និងមនុស្សរបស់ជនជាប់ចោទគឺម-១៣។ មនុស្សរបស់ ណាត ត្រូវបានបោសសម្អាតនិងសម្លាប់ចោល ផ្ទុយទៅវិញមនុស្សជាទីទុកចិត្តរបស់ជនជាប់ចោទរស់រានមានជីវិត។

យើងដឹងតាមរយៈបញ្ជីអ្នកទោសរួម និងរបាយការណ៍ទាក់ទងទៅនឹងស្ថានភាពខ្មាំងនៅក្នុង ស-២១ ដែលយ៉ាងហោចណាស់មានអ្នកជាប់ឃុំឃាំង១៥៥នាក់ ដែលជាអតីតបុគ្គលិកស-២១ ត្រូវបានសម្លាប់ចោល។ ទោះបីជាជនជាប់ចោទបានអះអាងថា ការចាប់ខ្លួន និងការសម្លាប់បុគ្គលិក គឺត្រូវតែមានតែមានការយល់ព្រមពីថ្នាក់លើ វាច្បាស់ណាស់ដែលថា គាត់គឺបានផ្តួចផ្តើមក្នុងការចាប់ខ្លួន និងសម្លាប់អ្នកទាំងនោះ។ គាត់បានផ្តល់សក្ខីកម្មថា សំណើរបស់គាត់មិនដែលបានគេបដិសេធម្តងណាឡើយ។ ជាការអនុវត្ត វាគឺជាសេចក្តីសម្រេចរបស់គាត់ដែលថាជាបុព្វហេតុចម្បងក្នុងការសម្លាប់បុគ្គលិករបស់គាត់។ ទោះបីក្នុងន័យនេះក៏ដោយ ដែលគាត់មានគំនិតរបបក្នុងការចៀសវាងនូវការផ្តន្ទាទោសចំពោះអ្នកដែលគាត់មានបំណងផ្តន្ទាទោសអ្នកដែលមិនគោរពវិន័យរបស់គាត់។

[១៤:០៣:៤៣]

ឥឡូវនេះ ខ្ញុំងាកទៅលើភស្តុតាងដែលនិយាយអំពីភាពជ្រុលហួសហេតុ ការគោរពវិន័យ ការមិនមានការក្នុងការដែលជនជាប់ចោទអនុវត្តចំពោះគោលនយោបាយជ្រុលនិយមនៅក្នុងស-២១ របស់បក្សកុម្មុយនីស្តកម្ពុជា។

ក្នុងនាមជាប្រធាន គាត់មានអំណាចផ្តាច់មុខទៅលើបុគ្គលិករបស់គាត់ក្នុងប្រតិបត្តិការ ជនជាប់

ចោទត្រូវតែអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដោយមិនមានឧបសគ្គអ្វីនោះឡើយ។ នេះតម្រូវឱ្យបុគ្គលិករបស់គាត់ធ្វើការស៊ើបអង្កេត សួរចម្លើយ ធ្វើទារុណកម្ម និងកម្ទេចអ្នកដែលគាត់គិតថាជាខ្មាំងរបស់បដិវត្តន៍។ គាត់មេខ្លោងតួនាទីសំខាន់នៅស-២១ ដើម្បីធានាកុំឱ្យមានខ្សែបណ្តាញខ្មាំងនៅក្នុងបក្ស។ ក្នុងពេលសវនាការជនជាប់ចោទបានសារភាពថា គាត់ទទួលខុសត្រូវចំពោះក្នុងការបណ្តុះបណ្តាលគោលនយោបាយ និងបណ្តុះបណ្តាលទៅលើបច្ចេកទេសសួរចម្លើយ។ ក្នុងនាមជាគ្រូមួយដែលបានទទួលការបណ្តុះបណ្តាលជាអ្នកស៊ើបអង្កេតយ៉ាងប្រិតប្រៀន ជាអ្នកជឿនៅក្នុងមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា ជនជាប់ចោទគឺសមរម្យនឹងទទួលមុខនាទីនេះ។ គាត់ក៏បានដឹងថា ពេលវេលារបស់គាត់ គឺបានចំណាយក្នុងបទពិសោធន៍នេះច្រើនជាងអ្នកដទៃ ជាពិសេសគាត់ក្មេងគាត់មិនមែនជាមនុស្សអ្វីសោះនោះទេ ហើយការជ្រើសរើសអ្នកដែលក្មេងៗ ដែលអាចនឹងបង្កការឈឺចាប់ទៅលើអ្នកទោស។

លោក លោកស្រីចៅក្រមបានពិនិត្យទៅលើសៀវភៅកំណត់ដៃរបស់មន្ទីរស-២១ ដែលគាត់បានរៀបរាប់ ហើយយើងឃើញមានការរៀបរាប់អំពីការអនុវត្តទាំងអស់នោះ។ ការធ្វើទារុណកម្មមិនអាចចៀសវាងបាននោះទេ ភាពខុសគ្នានោះ គឺថាច្រើន ឬក៏តិចតែប៉ុណ្ណោះ ចំពោះការអនុវត្តបទទារុណកម្ម។

អ្នកសួរចម្លើយប្រាក់ ខន បានផ្តល់ថា វគ្គអប់រំនយោបាយ និងការសួរចម្លើយត្រូវបានបញ្ចូលគ្នាដើម្បីឱ្យបុគ្គលិកទាំងអស់មានជំហរដាច់ខាតចំពោះខ្មាំង ដើម្បីឱ្យពួកគេទាំងអស់គ្នាចាត់ទុកអ្នកនោះថាជាសត្វ ដូចដែលជនជាប់ចោទបានបញ្ជាក់ បញ្ហានេះវាមានភាពងាយស្រួលសម្រាប់ឱ្យអ្នកទាំងអស់នោះមានភាពសាហាវក្នុងការធ្វើទារុណកម្ម និងទាញយកចម្លើយសារភាព។ ជនជាប់ចោទបានយល់យ៉ាងច្បាស់ថា អមនុស្សធម៌ចំពោះជនរងគ្រោះ គឺជាចំណុចសំខាន់នៅក្នុងវគ្គអប់រំ។ គាត់បានរំលោភវិជ្ជាជីវៈក្នុងនាមជាគ្រូ ហើយអនុញ្ញាតឱ្យក្មេងៗរាប់រយនាក់ប្រព្រឹត្តអំពើឃោរឃៅលើជនរងគ្រោះរាប់ពាន់នាក់។

[១៤:០៦:២៨]

ជនចាប់ចោទបានសារភាពទៅលើការអនុវត្តដ៏ខ្ជិចខ្ជៀន ក្នុងការជ្រើសរើសក្មេងៗពីភូមិ ដែលជាវណ្ណៈក្រីក្រ ហើយគាត់និងបក្សជឿទៅលើក្មេងៗ ដែលអ្នកទាំងអស់នោះមានប្រវត្តិមួយដ៏ល្អ មិនមាននិន្នាការបរទេស សក្តិភូមិ នាយទុន ឬក៏ក្រុង។ ពួកគេងាយស្រួលក្នុងការដឹកមុខ។ ខ្ញុំលើកសម្តីរបស់ជនជាប់ចោទ គាត់លើកឡើងថា ក្មេងៗដូចក្រដាស់សដែលអាចសរសេរអ្វីៗបានទាំងអស់។

លោកលោកស្រីចៅក្រម, គាត់បានធ្វើការដុសខាត់បុគ្គលិករបស់គាត់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៅស-២១។ ភ័ស្តុតាងបានបង្ហាញថា ជនជាប់ចោទ គឺជាអ្នកគ្រប់គ្រងដ៏ល្អបំផុតចំពោះការធ្វើទារុណកម្ម និងការសម្លាប់។ គាត់បានដឹងថា គាត់មិនអាចទទួលជោគជ័យទេនៅក្នុងប្រតិបត្តិការរបស់គាត់ លើកលែងតែគាត់លូកដៃចូលទៅក្នុងតួនាទី និងប្រតិបត្តិការបញ្ជាប្រចាំថ្ងៃនៅទីនោះផងដែរ។

ចំពោះបុគ្គលម្នាក់ដែលគាត់ថា គាត់ស្អប់ការងារនេះខ្លាំង វាមិនអាចឲ្យយើងយល់ឃើញថាហេតុអ្វីបានជាគាត់បំពេញការងារដ៏មានប្រសិទ្ធភាព។ នៅពេលដំណើរការស៊ើបអង្កេត ជនជាប់ចោទគាត់ហាក់ដូចជាធ្វើល្ងង់ មិនដឹងអំពីការងាររបស់ស-២១ប្រចាំថ្ងៃ ហើយគាត់បានទាត់ចោលទៅលើការងារទាំងអស់នោះថា គាត់ដឹងតិចតួចណាស់។ គាត់បានលើកឡើងផងដែរ អំពីអនុប្រធាន ហ៊ី ដែលគ្រប់គ្រងនៅទីនោះ នៅក្នុងគុក។ប៉ុន្តែ នៅពេលដែលសវនាការបានបន្ត យើងឃើញមានភ័ស្តុតាងច្រើន និងសាក្សីច្រើន។ ជនជាប់ចោទនៅពេលនោះ បានសារភាពថា គាត់បានចូលរួមនៅក្នុងការងារទាំងអស់នេះ ហើយគាត់មានតួនាទីរបស់គាត់ គឺវាមានលក្ខណៈហ្មត់ចត់ ហើយនិងគិតគូរទៅលើចំណុចពិស្តារ ហើយគាត់មានវិធីចាត់ចែងមន្ទីរស-២១ ដ៏មានប្រសិទ្ធភាព។ នៅពេលដែលចង់បានសេចក្តីសម្រេចនៅស-២១ ជនជាប់ចោទជាអ្នកចេញ។

ដូចដែលបានបង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ឧទាហរណ៍ច្រើននៃការផ្តួចផ្តើមរបស់គាត់ទាក់ទងទៅនឹងការចាត់ចែងមន្ទីរស-២១ នៅក្នុងនោះរួមមាន ការបញ្ជាឲ្យសួរចម្លើយ ធ្វើទារុណកម្ម និងការសម្លាប់ សេចក្តីសម្រេចក្នុងការបង្កើតក្រុមសួរស្ត្រី ហើយនិងជ្រើសរើសយកក្មេងៗដើម្បីមកបណ្តុះបណ្តាលជាអ្នកយាម។ សេចក្តីសម្រេចក្នុងការកសាងមន្ទីរអប់រំ ការព្រួយបារម្ភរបស់ជនជាប់ចោទចំពោះការគាស់សាកសព វាអាចលាតត្រដាងទៅលើភ័ស្តុតាងនៅតាខ្មៅ ហើយគាត់អាចសម្រេចនៅក្នុងការចាត់ចែង ការសុំឲ្យស្នើមានមណ្ឌលកាប់សម្លាប់។ ការភ័យខ្លាច និងវិន័យដែលថាគាត់មិនអាចគ្រប់គ្រងបុគ្គលិក ហើយនិងការទទួលខុសត្រូវរបស់គាត់នៅក្នុងការផលិតទិន្នផលនៅព្រៃសផងដែរ។

[១៤:០៩:៤០]

នៅពេលនេះ គឺខ្ញុំសូមរៀបរាប់អំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងតួនាទីឧក្រិដ្ឋស-២១។ ដូចដែលយើងបានឮហើយ សកម្មភាពទាំងអស់នេះពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ឃុំខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម ការវិភាគចម្លើយសារភាព និងការសម្លាប់អ្នកទោស។ លក្ខណៈនៃការពាក់ព័ន្ធនៅ

នឹងសកម្មភាពទាំងអស់នេះ បានបង្ហាញយ៉ាងច្រើនថា គាត់ប្ដេជ្ញាយ៉ាងដាច់ខាត និងមានភាពសប្បាយចំពោះឧក្រិដ្ឋកម្មទាំងអស់នេះ។

ជាដំបូង ខ្ញុំសូមលើកឡើងអំពីការចាប់ខ្លួន គឺជាទិដ្ឋភាពមួយទៀតនៃប្រតិបត្តិការមន្ទីរស-២១ ដែលគាត់ព្យាយាមបង្រួមទៅលើកិច្ចការទាំងអស់នេះ។ គាត់ព្យាយាមធ្វើការលើកឡើងថា តួនាទីរបស់មន្ទីរស-២១ គឺគ្រាន់តែទទួលអ្នកទោសតែប៉ុណ្ណោះ មិនមែនជាការផ្ដួចផ្ដើម និងការចូលរួមការចាប់ខ្លួននោះទេ។

ជាសង្ខេបជនជាប់ចោទ បានលើកឡើងថា តួនាទីរបស់ស-២១ គឺជាតួនាទីប្រតិកម្មទៅតាមស្នើ ហើយឆ្លើយតបទៅនឹងការចាប់ខ្លួន ដែលស្នើឡើងដោយអ្នកដទៃ និងទទួលយកអ្នកទោសតែប៉ុណ្ណោះ។ ប៉ុន្តែសក្ខីកម្មពីមន្ទីរស-២១ ជាពិសេសពីបុគ្គលិក និងឯកសារផ្សេងៗបង្ហាញថា តួនាទីរបស់មន្ទីរស-២១ និងជនជាប់ចោទមានលក្ខណៈសកម្មជាងមុន ជាជាងអ្វីដែលគាត់សារភាព។

ភ័ស្តុតាងទាំងអស់បានបង្ហាញអំពីសកម្មភាពរបស់គាត់ ដែលនាំឲ្យមានការចាប់ខ្លួនទៅលើបុគ្គលជាច្រើន។ គាត់មិនមែនជាអ្នកប្រធានគុកតែប៉ុណ្ណោះទេ គាត់ជាអ្នកស្រាវជ្រាវយ៉ាងសកម្មផងដែរ។ តើជនជាប់ចោទគាត់អាចបញ្ជាចាប់ខ្លួនអ្នកទោស ឬក៏ស្នើសុំចាប់អ្នកទោសដែរឬទេ? គឺជាចំណុចពាក់ព័ន្ធ។ បញ្ហានោះគឺថាជនជាប់ចោទជាអ្នកផ្ដួចផ្ដើមការចាប់ខ្លួនរាប់រាយ ប្រសិនបើមិនរាប់ពាន់ តាមរយៈការសួរចម្លើយ និងតាមរយៈការធ្វើទារុណកម្ម គាត់បង្កើត និងប្រើប្រាស់ទារុណកម្ម ដែលវាខុសច្បាប់ដើម្បីទាញយកព័ត៌មានហើយដើម្បីបង្កើតខ្សែក្បត់ ហើយនិងស្នើសុំប្រសិនបើមិនបញ្ជាឲ្យមានការចាប់ខ្លួនជនសង្ស័យបន្ថែម។ នៅពេលដែលគាត់ស្នើសុំការចាប់ខ្លួន និងការសម្លាប់ យ៉ាងហោចណាស់បុគ្គលិក ១៥៥រូបរបស់គាត់គាត់បានលើកឡើងឈ្មោះទាំងអស់នោះទៅឲ្យមេរបស់គាត់ចាប់អារម្មណ៍ ហើយគាត់បានស្នើសុំ ឬក៏ផ្ដល់ជាយោបល់ ហើយនៅក្នុងករណីជាច្រើន ជួយសម្របសម្រួលទៅលើការចាប់ខ្លួនទាំងអស់នោះ។

ជាការពិតណាស់ ដូចលោក លោកស្រីចៅក្រមស្ដាប់ឮហើយ គាត់គឺជាអ្នកចូលរួមដោយផ្ទាល់នៅក្នុងការចាប់ខ្លួនអ្នកសំខាន់។ ហើយគាត់គ្រាន់តែប្រើប្រាស់ចំណុចនេះជាលេស ឬជាពុតត្បុតតែប៉ុណ្ណោះ ឧទាហរណ៍នៅក្រោមលេសថាយកទៅពិនិត្យសុខភាព លេខាភូមិភាគឥសាន្ត ម៉ែន សាន ហៅយ៉ា គាត់ត្រូវបានគេល្បួងយកទៅផ្ទះរបស់ជនជាប់ចោទដើម្បីចាប់ខ្លួន។ លេខាមជ្ឈិមបក្ស ប៉ង់ ត្រូវបានគេចាប់ខ្លួន នៅពេលដែលគាត់ទៅទស្សនកិច្ចក្នុងពិធីការងារនៅស-២១។ ការចាប់ខ្លួនដទៃៗទៀត តម្រូវ

ឲ្យមានការរៀបចំផ្នែកសម្ភារៈ។ ជនជាប់ចោទ បាននិយាយថា គាត់បានចូលរួមនៅក្នុងការចាប់ខ្លួន កុយ ធួន ផងដែរ។

លោកចៅក្រម លោកក៏បានឃើញភ័ស្តុតាងបង្ហាញអំពីតួនាទីរបស់ជនជាប់ចោទ ដែលវាមិនកម្រិតទៅត្រឹមការរៀបចំផែនការចាប់តែប៉ុណ្ណោះទេ។ គាត់គឺបានណែនាំនិងអនុវត្តរៀបចំការបោសសម្អាតធំធេង។

នៅក្នុងកំណត់ប្រជុំថ្ងៃ១៦ ខែកញ្ញា ឆ្នាំ១៩៧៦ ដែលមាន សុន សេន និងមេដឹកនាំយោធាជាន់ខ្ពស់ចូលរួមនោះ ជនជាប់ចោទបានបង្ហាញ និងរៀបចំវិធីសាស្ត្រនៅក្នុងការចាប់ខ្លួនកម្មាភិបាលជាច្រើនទៀត។ យើងឃើញថាកំណត់ហេតុទាំងអស់នោះ បានកត់ត្រានូវយោបល់របស់គាត់ ដែលចង់ឲ្យមានការចាប់បន្ថែម២៩រូបទៀត ដែលនៅក្នុងនោះ គឺគាត់ជាអ្នកកំណត់អត្តសញ្ញាណ។ តួនាទីយ៉ាងសកម្មជាមុនរបស់ជនជាប់ចោទ នៅក្នុងការបោសសម្អាត គឺបានបង្ហាញនៅក្នុងលិខិតចំនួនប្រាំបួន ផ្ញើជូនទៅកាន់គាត់ ដែលគាត់បានសរសេរ និងចុះហត្ថលេខាដោយ ស៊ូ ម៉េត ជាមេបញ្ជាការកងពល ៥០២។

លិខិតទាំងអស់នេះបង្ហាញថា ជនជាប់ចោទបានបញ្ជូនចម្លើយសារភាពនៅស-២១ និងបញ្ជីខ្សែក្បត់ ហើយនៅក្នុងនោះ បានលាតត្រដាងប្រាប់ស៊ូ ម៉េត។ នៅលើឯកសារទាំងអស់នេះ ស៊ូ ម៉េត បានធ្វើការស៊ើបអង្កេតទៅលើបុគ្គលិករបស់ខ្លួននៅក្នុងកងពល៥០២ ហើយបញ្ជូនបុគ្គលិកបន្ថែមទៀតមកមន្ទីរស-២១មកសួរចម្លើយ។ យ៉ាងហោចណាស់មនុស្ស៣០០នាក់ ត្រូវបានគេបោសសម្អាតពីកងពល៥០២ ហើយត្រូវបានគេបញ្ជូនទៅសួរចម្លើយ និងសម្លាប់ចោលនៅមន្ទីរស-២១។ ជនជាប់ចោទបានព្យាយាមពង្រួមនៃភាពសំខាន់នៃឯកសារទាំងអស់នេះ។ គាត់បានលើកឡើងថា លិខិតទាំងអស់នេះបញ្ជូនទៅសុន សេន ហើយសំណើការចាប់ខ្លួនទាំងអស់ត្រូវការ ការយល់ស្របពីសុន សេន។ ជនជាប់ចោទបានទទូចថា សុន សេន មិនបានចុះហត្ថលេខាទៅលើលិខិតរបស់ ស៊ូ ម៉េត នោះទេ ដោយសារតែតាក់តិច ដែលគាត់ប្រើជាមួយ នួន ជា ដើម្បីលាក់ឈ្មោះ។ ចំណុចពន្យល់នេះ វាមិនគួរឲ្យជឿនោះទេ។

[១៤:១៥:០០]

នៅពេលដែលយើងពិចារណាទៅលើឯកសារដទៃទៀតដែលបានបង្ហាញថា តួនាទីរបស់ សុន សេន គឺវាពាក់ព័ន្ធនឹងការបោសសម្អាត។ យើងខ្ញុំសូមលើកឡើងថាលិខិតរបស់ ស៊ូ ម៉េត បានបង្ហាញថា ជនជាប់ចោទបានចូលរួមយ៉ាងសកម្មនៅក្នុងការសម្របសម្រួលការបោសសម្អាតធំធេងមានចំពោះ

មេបញ្ជាការកងពល។ ដោយសារតែ សុន សេន ជាអ្នកផ្តល់ការយល់ព្រមទៅលើការបោសសម្អាតនោះ វាបញ្ជាថានៅពេលនោះគឺគាត់មិនត្រឹមតែធ្វើការជួយទៅលើការស៊ើបអង្កេតទេ គឺគាត់បានជួយសម្រួលទៅលើការងារទាំងអស់នេះ។ ឯកសារផ្សេងៗទៀតនៅក្នុងសំណុំរឿងបង្ហាញថា មេដឹកនាំយោធា និងរដ្ឋបាលឆ្លើយតបដោយផ្ទាល់ទៅនឹងជនជាប់ចោទ។ ឧទាហរណ៍សមមិត្ត ក្រឹម ពីកំពង់សោមផែកំពង់សោមបានចុះហត្ថលេខាលើរបាយការណ៍ ដែលផ្ញើទៅកាន់ជនជាប់ចោទនៅឆ្នាំ១៩៧៧។ ជនជាប់ចោទសារភាពថា សមមិត្ត សាន មកពីកងពល៣១០ សរសេរលិខិតជូនគាត់ ដែលមានអមបញ្ជីចាប់ខ្លួនមកជាមួយ។ យោបល់របស់ជនជាប់ចោទ គឺបានស្នើសុំឲ្យមានការលើកឡើង និងដោះស្រាយទៅលើហេតុការណ៍ទាក់ទងទៅនឹងបញ្ហាសន្តិសុខ ដែលក្នុងនោះធ្វើការស៊ើបអង្កេតទៅលើខិតប័ណ្ណរិះគន់អង្គការដែលបានចែកចាយនៅក្នុងភ្នំពេញ។ ជនជាប់ចោទបានចូលរួមនៅក្នុងកិច្ចប្រជុំនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ជាមួយ ប៉ង់ និង សុន សេន ដែលគាត់ទាំងពីរនាក់នោះ បានចូលរួមផងដែរ។

លោក លោកស្រីចៅក្រមជាទីគោរព, ជាសង្ខេបយើងឃើញថាវាបង្ហាញយ៉ាងច្បាស់ថាជនជាប់ចោទដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់អត្តសញ្ញាណទីតាំង និងចាប់ខ្មាំង។ នៅពេលដែលគាត់ធ្វើដូច្នោះ គឺគាត់ត្រូវរក្សាការទាក់ទងជាច្រើនជាមួយនឹងមេដឹកនាំបក្ស ហើយនិងប្រធាន និងមេដទៃៗទៀតនៅកងពល និងអង្គភាពផ្សេងៗនៅទូទាំងប្រទេស។ ចំពោះការចូលរួមផ្ទាល់របស់ជនជាប់ចោទទាក់ទងទៅនឹងការឃុំខ្លួនអ្នកទោសនៅមន្ទីរស-២១ លោកចៅក្រមបានស្តាប់ឮសាក្សី សួស ធី ដែលបានពន្យល់ថា ជនជាប់ចោទទទួល និងចុះហត្ថលេខលើបញ្ជីអ្នកទោសដែលបានរៀបចំឡើងដោយបុគ្គលិក។

ចំណុចនេះ គឺអាចអនុញ្ញាតឲ្យជនជាប់ចោទតាមដានអំពីចលនា និងចំនួននៃអ្នកទោសនៅក្នុងមន្ទីរស-២១។ នៅពេលដែលអ្នកទោស នៅពេលដែលគុកកាន់តែមានមនុស្សច្រើនឡើង គាត់បានបញ្ជាហ៊ី ដែលជាអនុប្រធានឲ្យសម្លាប់អ្នកទោសដែលមានចំនួនច្រើនលើសលុបនោះ ដើម្បីទុកកន្លែងសម្រាប់អ្នកថ្មី។

[១៤:១៧:៤៩]

នៅក្នុងបន្ទាប់សវនាការនេះជនជាប់ចោទបានឆ្លើយថា ការធ្វើដូច្នេះបានធ្វើឡើងដើម្បីមិនឲ្យមានការចំណាយច្រើនទៅលើម្ហូបអាហារចិញ្ចឹមអ្នកទោសទាំងអស់នោះ។ ជនជាប់ចោទបានដឹងពេញលេញទៅលើស្ថានភាពអមនុស្សធម៌ និងអាក្រក់ដែលវាកើតឡើងចំពោះអ្នកទោស។ គាត់បានទៅទស្សនា ឬដើរមើលទីតាំងធំៗជាពិសេសបន្ទាប់សួរចម្លើយ។ គាត់សារភាពថា បានឃើញរបួសរបស់អ្នកទោស

ដែលទទួលរងទារុណកម្ម ហើយគាត់បានឃើញអំពីស្ថានភាពស្គមស្គាំង និងឈឺរបស់អ្នកទោស ប៉ុន្តែគាត់មិនបានចាត់វិធានការទៅលើស្ថានភាពអាក្រក់ទាំងអស់នោះទេ។

សាក្សី និងជនជាប់ចោទបានបញ្ជាក់ផងដែរថា គាត់ជាអ្នកកំណត់ និងអនុញ្ញាតក្រឹត្យក្រមក្នុងការឃុំអ្នកទោស។ ទាំងអស់នេះរួមទាំងការហាមមិនឲ្យអ្នកទោសដើរ បដិសេធមិនផ្តល់អាហារគ្រប់គ្រាន់ មិនផ្តល់សម្លៀកបំពាក់ អនាម័យ និងការថែទាំសុខភាព។ ទោះបីតែគាត់យកចិត្តទុកដាក់ចំពោះអ្នកទោសជាច្រើនជាក់លាក់ក៏ដោយ គឺគាត់បដិសេធទៅលើអ្នកទោសជាច្រើនទៀត ដូចដែលគាត់ប្រាប់តុលាការ ហើយគាត់មិនអាចធ្វើការងារនេះឲ្យមានប្រសិទ្ធភាពទេ ប្រសិនបើគាត់ទទួលស្គាល់មនុស្សធម៌របស់អ្នកទោសទាំងអស់នេះ។ មិនថាក្មេង ឬក៏ចាស់នោះទេ គឺគាត់បានឆ្លើយថា គាត់ចាត់ទុកអ្នកទាំងអស់នោះជាសត្វ។

ការចាប់ខ្លួននិងឃុំខ្លួនអ្នកទោសនៅស-២១ គ្រាន់តែជាការចាប់ផ្តើមនៃការចូលរួមរបស់ជនជាប់ចោទតែប៉ុណ្ណោះ។ ដូចដែលយើងបានឮហើយ ការសួរចម្លើយខ្លាំងអ្នកទោស ដែលមានគោលបំណងក្នុងការទាញយកចម្លើយសារភាពជាពិសេសជាចំណុចមួយសំខាន់នៅក្នុងហ្នឹង វាទាមទារមានអ្នកមានជំនាញដូចជនជាប់ចោទ អ្នកជំនាញក្នុងការធ្វើទារុណកម្ម ដែលមានបទពិសោធន៍យ៉ាងច្រើន និងមានការប្តេជ្ញាយ៉ាងមុតមាំ។ គាត់បានបណ្តុះបណ្តាលអ្នកសួរចម្លើយកូនចៅគាត់ ហើយនិងគ្រប់គ្រងការងារ គាត់បានដឹងបញ្ជាបែបណាត្រូវចេញ ដើម្បីឲ្យអ្នកសួរចម្លើយនីមួយៗអនុវត្ត ហើយគាត់ មានតែគាត់ទេដែលបានដឹង ហើយបញ្ជាក់ថា តើនៅពេលណាដែលការសួរចម្លើយនោះវាបានបញ្ចប់។ ជាពិសេសជនជាប់ចោទបានធ្វើការចាត់ចែងទៅលើអ្នកទោស សួរចម្លើយអ្នកទោសសំខាន់ៗ ដែលគាត់ជាអ្នកគ្រប់គ្រងដោយផ្ទាល់ ឬក៏តាមដានដោយផ្ទាល់។

ជាដំបូងគាត់បានសារភាពថា គាត់សួរចម្លើយអ្នកទោសម្នាក់ គឺលេខាភូមិភាគឧត្តរ កុយ ធួន។ នៅក្នុងពេលសវនាការ គាត់ទទួលស្គាល់ថា គាត់សួរចម្លើយពីរនាក់ទៀត ម៉ា ម៉េងឃាង ហើយនិងឈិត អ៊ីវ។ ប្រហែលជាមានចំនួនច្រើនជាងនេះទៀត។ ចំពោះអ្នកទោសសំខាន់ៗដែលគាត់មិនសួរចម្លើយដោយផ្ទាល់ ភ័ស្តុតាងបង្ហាញថាជនជាប់ចោទបានតាមដានយ៉ាងយកចិត្តទុកដាក់ទៅលើការសួរចម្លើយទាំងអស់នោះជារៀងរាល់ថ្ងៃ ហើយចេញការណែនាំនូវពេលជាច្រើន។

[១៤:២០:៥៥]

ឆន្ទៈរបស់ជនជាប់ចោទក្នុងការសួរចម្លើយអ្នកទោសដោយខ្លួនគាត់ ហើយនិងការយកចិត្តទុក

ដាក់ដឹងប៉ងល់ទៅលើចំណុចល្អិតល្អន់ទៅលើដំណើរការសួរចម្លើយនោះ បង្ហាញថាគាត់គឺជាប្រធានដែលយកចិត្តទុកដាក់នៅក្នុងការងារស-២១។ ប៉ុន្តែការគ្រប់គ្រងដំណើរការរបស់គាត់មិនមែនបង្ហាញជាយន្តការវិជ្ជមាននោះទេ។ ការមិនខ្វល់នឹងការឈឺចាប់របស់ជនរងគ្រោះបង្ហាញថា គាត់ជាបុគ្គលម្នាក់ដែលដាក់ខ្លួន ដាក់កាយទៅគោលបំណងរបស់ស-២១ ហើយគាត់ធ្វើការមិនយកចិត្តទុកដាក់ចំពោះស្ថានភាពលំបាករបស់អ្នកទោស។ គាត់មិនបានកាត់បន្ថយទៅលើចំណុចទាំងអស់នេះ។

អ្នកទោសធំៗជាច្រើន រួមទាំង ហ៊ូ នឹម, សៀត ឆែ, មាឃ ទូច បានសរសេរមកកាន់ជនជាប់ចោទសុំឱ្យមានក្តីមេត្តា ហើយសុំអង្វរគាត់ឱ្យទុកជីវិត និងគ្រួសាររបស់ពួកគេ។ ជនជាប់ចោទមិនខ្វល់ឡើយ ភ័ស្តុតាងបង្ហាញថា គាត់បានសរសេរលិខិតទៅវិញ ហើយស្តីបន្ទោសឱ្យពួកគេ និងសើចចំអកដល់ពួកគេ។

នៅពេលដែល សៀត ឆែ លើកឡើងថា គេចាប់ខ្លួនគាត់ខុសទេនោះ។ ជនជាប់ចោទឆ្លើយតបថាគាត់ធ្វើការនៅទីនេះជារៀងរាល់ថ្ងៃ។ គាត់មិនដែលដឹងថា មានករណីណាមួយដែលគេចាប់អ្នកទោសខុសនោះឡើយ។ ជាបុគ្គលម្នាក់ដែលរឹងប៉ឹងនិងដាច់ខាត ជនជាប់ចោទគ្មានក្តីមេត្តាធម៌ចំពោះ-- សូម្បីតែមិត្តភក្តិជិតស្និតរបស់ខ្លួន និងគូកនរបស់ខ្លួន។

សាស្ត្រាចារ្យដំបូងបំផុតរបស់ខ្លួន កែ គឹមហួត និងប្រពន្ធរបស់គាត់ឈ្មោះ ឌឹម សារឿន ត្រូវបានគេចាប់ខ្លួននាំមកស-២១។ អ្នកទាំងពីរត្រូវបានគេធ្វើទារុណកម្មយ៉ាងខ្លោចផ្សា។ ហួត ត្រូវបានគេបង្ខំឱ្យបរិភោគលាមក ហើយ សារឿន ត្រូវបានគេចាប់រំលោភដោយប្រើឈើ។ ជនជាប់ចោទគាត់មិនឆ្លើយតបទៅលើចំណុចទាំងអស់នេះ ហើយគាត់បដិសេធថាគាត់មិនបានដឹងទៅលើចំណុចទាំងអស់នេះ។ ហើយទាំងអស់នេះ យើងអាចពិចារណាតាមរយៈចំណាររបស់គាត់លើការធ្វើទារុណកម្មរបស់ កែ គឹមហួត។

ចំណាររបស់ជនជាប់ចោទ បញ្ជាឱ្យធ្វើទារុណកម្ម និងបង្គាប់សំណួរទៅដល់អ្នកសួរចម្លើយ យើងឃើញមាននៅក្នុងចម្លើយសារភាពជាច្រើនដែលបន្សល់ទុកពីមន្ទីរស-២១។ នៅក្នុងករណីនេះ លោកចៅក្រមឃើញតែចំនួនតិចប៉ុណ្ណោះនៅលើចម្លើយទាំងអស់នោះ ប៉ុន្តែវាជាគំរូតំណាងដែលបង្ហាញថាជនជាប់ចោទមិនមានក្តីមេត្តាទាល់តែសោះចំពោះអ្នកទោស។

[១៤:២៣:៣៩]

លោកចៅក្រមនៅចាំហើយចំពោះចំណារដ៏សាហាវដែលគាត់ផ្តល់ជូនអ្នកសួរចម្លើយឱ្យសួរស្ត្រី

វៀតណាមមួយរូប។ ខ្ញុំសូមដកស្រង់សម្តី “សួរឱ្យល្អិតល្អន់ ឱ្យហ្មត់ចង់ ហើយសមល្មម ប្រើទារុណកម្មសមល្មមដើម្បីរកខ្សែក្បត់។ វាយរហូតដល់គាត់ ស្ត្រីរូបនោះឈប់និយាយថា គាត់ទៅវៀតណាមជាមួយជីតាដើម្បីព្យាបាលមហារីក និងបញ្ហាបាត់រដូវ”។

លោក លោកស្រីចៅក្រម ជាទីគោរព, លោក លោកស្រីចៅក្រមចាំចំណារដែលជនជាប់ចោទបានបង្គាប់បញ្ជាវិធីសាស្ត្រសួរចម្លើយលើ ម៉ែន សាន ហៅ យ៉ា។ បន្ទាប់ពីបញ្ជាឱ្យធ្វើទារុណកម្ម យ៉ា ជនជាប់ចោទបានចំអកឡកឡឺយ ដែលជនរូបនោះ គាត់ព្យាយាមរាយការណ៍ទៅថ្នាក់លើថា ចម្លើយទាំងអស់នោះបានទទួលពីការធ្វើទារុណកម្ម។ បន្ទាប់ពីទ្រាំលែងបានជាមួយ យ៉ា ជនជាប់ចោទបញ្ជាឱ្យ ប៉ុន ដែលជាអ្នកសួរចម្លើយឱ្យប្រើវិធីក្តៅ ហើយបានបញ្ជាក់ប្រាប់ ប៉ុន ថា ប្រសិនបើធ្លោយធ្លោះឱ្យ យ៉ា ស្លាប់ អ្នកសួរចម្លើយនឹងមិនទទួលការរំលោភទៅលើក្រឹត្យក្រមវិន័យបដិវត្តន៍ឡើយ។

មេធាវីដើមបណ្តឹងក្រុមទី១ បានលើកឡើងកាលពីម្សិលមិញថា ការអះអាងរបស់ជនជាប់ចោទចំពោះគោលបំណងនៃការធ្វើចំណារគឺវាមិនមានអ្វីដែលឱ្យយើងជឿជាក់នោះឡើយ។ ទោះបីជាបទចោទមិនបញ្ចូលឧក្រិដ្ឋកើតឡើងនៅមន្ទីរម-១៣ ក៏ដោយ លោកចៅក្រមបានអាននូវភស្តុតាងដែលបង្ហាញថាជនជាប់ចោទបានធ្វើទារុណកម្មអ្នកទោសដោយផ្ទាល់នៅមន្ទីរសន្តិសុខម-១៣ មុនពេលដែលគាត់ចាប់ផ្តើមការងារនៅមន្ទីរស-២១។

លោក លោកស្រីចៅក្រមនឹងចាំសក្ខីកម្មរបស់ជនជាប់ចោទទាក់ទងទៅនឹងការសួរចម្លើយយ៉ាងយូរ និងការធ្វើទារុណកម្មទៅលើរូបលោក ផាប ប៊ិនសុន ដែលជាអ្នកទោសនៅម-១៣។ ជនជាប់ចោទបានលើកឡើងថា ខ្ញុំសូមដកស្រង់សម្តីគាត់ វាឱ្យខ្ញុំចំណាយពេលជិតមួយខែដើម្បីបញ្ចប់។ ដូច្នេះហើយការធ្វើទារុណកម្ម ការវាយតប់ និងការសួរចម្លើយត្រូវបានធ្វើឡើង។ ខ្ញុំព្យាយាមធ្វើអស់ពីសមត្ថភាពរបស់ខ្ញុំ។

លោក លោកស្រីចៅក្រមចាំហើយអំពីសក្ខីកម្មរបស់អ្នកទោសបារាំងឈ្មោះ ហ្វ្រង់ស្វ័រ ប៊ីហ្សូ ដែលបានជាប់នៅម-១៣ ក្នុងរយៈឆ្នាំទីមួយនៃប្រតិបត្តិការរបស់មន្ទីរនេះនៅក្នុងឆ្នាំ១៩៧១។ បន្ទាប់ពីបង្កើតទំនាក់ទំនងពិសេសជាមួយនឹងជនជាប់ចោទ នៅយប់ថ្ងៃបុណ្យណូអែល ជនជាប់ចោទបានលួចនិយាយប្រាប់ ប៊ីហ្សូ អំពីការទារុណកម្មដែលជនរូបនេះប្រព្រឹត្តដោយផ្ទាល់។ ប៊ីហ្សូ បាននិយាយឡើងវិញទៅលើការសន្ទនានៅក្នុងសៀវភៅរបស់គាត់ ដែលជនជាប់ចោទនិយាយទៅកាន់គាត់។

[១៤:២៦:៤២]

ខ្ញុំសូមដកស្រង់សម្តី "មនុស្សភាគច្រើនដែលមានទីនេះ វាជាទទួលខុសត្រូវរបស់ខ្ញុំក្នុងការសួរចម្លើយពួកគេ ដើម្បីរកខ្សែទំនាក់ទំនងរបស់ពួកគេ ព័ត៌មានអ្វីដែលពួកគេមកស៊ើបការណ៍ ហើយអ្នកណាជាអ្នកជួលពួកគេ? ប្រសិនបើមានអ្នកក្បត់ម្នាក់ណាមួយនោះ គឺគេនឹងធ្វើការប៉ះពាល់ទៅដល់ការតស៊ូរបស់យើង។ តើលោកគិតយ៉ាងម៉េចដែរ នៅក្នុងការលាតត្រដាងនូវអ្វីដែលលោកបានលើកឡើងនេះ? ប៊ីហ្សូ បាននិយាយថា តើលោកមានបានវាយដែរទេ? ជនជាប់ចោទគាត់កាត់ ហើយបាននិយាយថា ខ្ញុំមិនអាចទ្រាំនឹងការបោកបញ្ឆោតនោះទេ ខ្ញុំគួរធ្វើឲ្យពួកគេភិតភ័យ បង្អត់ពួកគេ ហើយវាពិបាកណាស់។ ខ្ញុំត្រូវតែបង្ខំខ្លួនខ្ញុំ ហើយអ្នកមិនអាចគិតទេ ថាតើពួកគេនោះភរខ្ញុំ ធ្វើឲ្យខ្ញុំខឹងយ៉ាងណា ហើយនៅពេលដែលខ្ញុំសួរពួកគេ ខ្ញុំព្យាយាមចៀសវាងការនិយាយជាមួយពួកគេ ហើយបានបដិសេធទៅលើចំណុចមួយចំនួន នៅពេលដែលពួកគេមិនប្រាប់ព័ត៌មានទាំងឡាយនោះ ខ្ញុំបានវាយពួកគេ។ ខ្ញុំវាយពួកគេរហូតដល់ខ្ញុំដង្ហក់"។

សាក្សីដទៃៗទៀត ជនជាប់ឃុំមួយរូប និងអ្នកយាមគុកពីររូបនៅម-១៣ បានមកផ្តល់សក្ខីកម្មនៅក្នុងរឿងក្តីនេះ ហើយវាមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុមូលដ្ឋានដែលជនជាប់ចោទបញ្ជាក់ថា លោកខ្លួនឯង ចូលរួមនៅក្នុងទារុណកម្មនៅម-១៣។ យើងអាចសន្និដ្ឋានយ៉ាងសមហេតុផលថា ការអនុវត្តបែបនោះ វាកើតឡើងនៅម-១៣ ក្នុងរយៈពេលប្រតិបត្តិការបួនឆ្នាំ។

[១៤:២៨:៣៥]

បន្ថែមទៅលើចំណុចនេះ នៅស-២១ គាត់ ជនជាប់ចោទ គាត់បានសារភាពថា គាត់បានវាយអ្នកទោសនៅក្នុងពេលសួរចម្លើយ។ ឈិត អ៊ីវ នៅក្នុងចំណោមអ្នកទោសមួយដែរ។ ភស្តុតាងបានបង្ហាញថាការអនុវត្តទៅលើការបំពានរូបរាងកាយនៅតែបន្ត។ យើងបានស្តាប់សក្ខីកម្មរបស់ ឡាច មាន, ឈុន ផល ហើយនិងអានភស្តុតាងរបស់លោក ញឹម អេន ផងដែរ។ បុគ្គលិកស-២១ ដែលនៅនោះបានឃើញជនជាប់ចោទវាយតប់អ្នកទោសនៅក្នុងឆ្នាំ១៩៧៧ ដោយប្រើដំបង។ ប្រហែលជាវារយៈពេលក្នុងរយៈពេលពីរឆ្នាំនៅក្នុងប្រតិបត្តិការនៃមន្ទីរនោះ។

អតីតអ្នកយាមម្នាក់ឈ្មោះ សោម ម៉េត បានបញ្ជាក់ថានៅក្នុងឆ្នាំ១៩៧៨ ជនជាប់ចោទបានធាក់និងវាយអ្នកទោសដោយរំពាត់ផ្តៅ ប្រសិនគាត់គិតថាអ្នកទោសមិនលាតត្រដាងព័ត៌មានគ្រប់គ្រាន់។

ជនជាប់ចោទមិនបានបដិសេធទៅនឹងចម្លើយទាំងអស់នេះទេ។ ពេលដទៃទៀត ជនជាប់ចោទគាត់រីករាយនឹងការបំពានអំណាចរបស់គាត់។

លោក លោកស្រីចៅក្រម ចាំចម្លើយរបស់ ប៊ូ ម៉េង ដែលបានផ្តល់សក្ខីកម្មថា “ថ្ងៃមួយនោះ ខ្ញុំមិនដឹងថាខ្ញុំធ្វើខុសអ្វីផង គាត់បានស្នើខ្ញុំ បញ្ជាខ្ញុំ ហើយនិង អៀម ចាន់ ឲ្យវាយគ្នាទៅវិញទៅមក។ ពេលនោះ គាត់ឲ្យដំបងទុយោជ័រខ្មៅឲ្យវាយគ្នាទៅវិញទៅមក ហើយគាត់អង្គុយមើលយើងវាយគ្នាទៅវិញទៅមកពេលនោះគាត់ឲ្យដំបងទុយោជ័រខ្មៅឲ្យវាយគ្នាទៅវិញទៅមក ហើយគាត់អង្គុយមើលយើងវាយគ្នាទៅវិញទៅមក។ បន្ទាប់មកគាត់បញ្ជាឲ្យយើងឈប់។” ជនជាប់ចោទបានបញ្ជាក់ថា គាត់ផ្តល់បញ្ជាដូច្នេះ ប៉ុន្តែគាត់មិនបានចាំថាហេតុអ្វីបានជាគាត់បញ្ជាឲ្យវ៉ៃគ្នានោះទេ។

លោក លោកស្រីចៅក្រម, ថាតើយើងយល់ដូចម្តេច ចំពោះការចូលរួមដោយផ្ទាល់នៅក្នុងការវាយតប់ ការធ្វើទារុណកម្មអ្នកទោស ជាងរយៈពេលប្រាំពីរឆ្នាំកន្លះនេះ វាបង្ហាញជាភ័ស្តុតាងយ៉ាងច្បាស់ថា ទឡ្ហីករណ៍ទាំងអស់នេះ គឺបាន គាត់បានលើកឡើងថា គាត់ត្រូវបានគេបង្ខំឲ្យមានឆន្ទៈនៅក្នុងការបំពេញការងាររបស់គាត់នៅស-២១នោះទេ ប៉ុន្តែនេះមិនមែនការពិតឡើយ។ ហេតុអ្វីបានជាគាត់ចូលរួមដោយខ្លួនឯងនៅក្នុងការធ្វើទារុណកម្ម ការវាយតប់នៅពេលដែលគេមិនបញ្ជា ឬក៏គេមិនឲ្យគាត់ធ្វើនោះផង? ចម្លើយគឺគាត់លើកឡើងថា “គាត់មានជំនឿដ៏ក្លៀវក្លាក្នុងការបន្តឲ្យសម្រេចនូវគោលបំណងរបស់បក្ស ហើយបាននាំឲ្យមានអំពើហិង្សាមិនសមហេតុផលចំពោះអ្នកទោស។

ទោះបីជានៅពេលនោះក៏ដោយ ដោយសារតែឧត្តមភាពរបស់គាត់ គាត់មិនបានចូលរួមនៅក្នុងទារុណកម្មជារៀងរាល់ថ្ងៃនោះទេ។ យើងខ្ញុំសូមលើកឡើងថា ការបង្កការឈឺចាប់មិនមែនអ្វីដែលគាត់ស្អប់នោះទេ វាគឺជាអ្វីដែលគាត់យល់ឃើញថា វាមានភាពចាំបាច់ ហើយជាការសប្បាយចិត្តសម្រាប់រូបគាត់។

នៅពេលនេះ ខ្ញុំសូមលើកឡើងអំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងការវិភាគព័ត៌មានដែលកើតចេញពីការធ្វើទារុណកម្ម និងការសួរចម្លើយ គឺយើងហៅថា ចម្លើយសារភាពដ៏ស្មុគស្មាញ។

ចម្លើយសារភាពទាំងអស់នេះ គឺជាឈាមដែលហូរចេញពីយន្តការឧក្រិដ្ឋរបស់ស-២១ ជនជាប់ចោទមានអំណាចដោយខ្លួនឯងក្នុងការវិភាគចំណារ ចម្លើយឯកសារទាំងអស់នេះរាប់ពាន់ទំព័រ ហើយបានសំយោគខ្លឹមសាររបស់វា ជារបាយការណ៍រួមសម្រាប់មេរបស់ខ្លួន។ ការងារដ៏ល្អិតល្អន់បានបន្សល់ទុកមួយផ្នែកតូចតែប៉ុណ្ណោះ ប៉ុន្តែការយកចិត្តទុកដាក់របស់គាត់ម៉ត់ចត់លើចំណុចទាំងឡាយនោះ គឺឃើញតាមរយៈការប្រឹងប្រែងរបស់គាត់ ហើយវាជាចំណុចមួយគួរឲ្យយើងភ្ញាក់ផ្អើល។ លទ្ធផលរបស់ការងាររបស់គាត់នោះ គឺយើងបង្ហាញឃើញថា មានការទាញយកចម្លើយ និងឈ្មោះអ្នកផ្សេងដែល

អ្នកទាំងអស់នោះត្រូវបានគេយកសម្លាប់នៅពេលក្រោយ។ ជាងកៅសិបភាគរយនៃជនរងគ្រោះទាំងអស់នេះ តាមពិតទៅយើងមិនឃើញថា មានការគ្រោះថ្នាក់ទៅដល់បក្សឡើយ នៅដើមដំបូងជនជាប់ចោទបានរាយការណ៍ថា បានរាយការណ៍ព័ត៌មានទាំងអស់ទៅមេរបស់ខ្លួន សុន សេន នៅពេលដែល នួន ជា កាន់កាប់បន្ទាប់ពី សុន សេន ជនជាប់ចោទបានរាយការណ៍ទៅកាន់ នួន ជា ដោយខ្លួនឯងជាជាងតាមទូរស័ព្ទ។

[១៤:៣៣:១៧]

ជនជាប់ចោទបានអះអាងថា ត្រឹមឆ្នាំ១៩៧៨ នួន ជា បានយកចិត្តទុកដាក់តិចតួច ហើយគាត់មិនសូវយកចិត្តទុកដាក់ទៅលើចម្លើយសារភាព។ យើងឃើញថា ការយកចិត្តទុកដាក់ទាំងឡាយនៅក្នុងចម្លើយសារភាព គឺមានរហូតដល់ចុងឆ្នាំ១៩៧៨ ពេលនេះហើយគឺជា មានការច្របូកច្របល់ ហើយមានការភ័យខ្លាចចាប់ផ្តើមកើនឡើង។ រូបភាពដែលជនជាប់ចោទព្យាយាមផាត់ពណ៌នោះ គឺទាក់ទងទៅនឹងចម្លើយសារភាពមួយចំនួន ហើយនិងព័ត៌មានដែលទទួលបានអំពីសំណួរ ជាពិសេសដែលណែនាំឡើងដោយថ្នាក់ដឹកនាំ មានអ្នកទោសជាច្រើនពាន់នាក់ឆ្លងកាត់ស-២១ ជារៀងរាល់ថ្ងៃគឺជាការគ្រប់គ្រងដ៏ល្អិតរបស់ សុន សេន និង នួន ជា គឺជាកត្តាសំខាន់ ចំណុចសំខាន់គឺអ្នកទោសសំខាន់បំផុតជនជាប់ចោទបានទទួលការណែនាំជាក់លាក់ ប៉ុន្តែអ្នកទោសភាគច្រើនគាត់ប្រើគំនិតផ្តួចផ្តើមរបស់គាត់ ហើយនិងវិធីសាស្ត្រផ្ទាល់ខ្លួន ហើយអនុវត្តឆន្ទានុសិទ្ធិរបស់គាត់ ជាពិសេសចំពោះការសួរចម្លើយ និងទារុណកម្ម។ ជនជាប់ចោទអះអាងថា គោលបំណងតែមួយនៃចំណាររបស់គាត់ គឺអនុញ្ញាតឲ្យមេដឹកនាំ អាចនឹងក្តាប់បាននូវសារសំខាន់នៃចម្លើយសារភាពហើយ គឺអាចទាក់ទងទៅនឹងខ្លឹមសារលម្អិត។ ការអះអាងនេះមិនសមស្របទេ។ ជនជាប់ចោទពាក់ព័ន្ធនឹងស-២១ គឺអង្កេតអ្នកទោស ហើយនិងវាយតម្លៃចម្លើយរបស់គេបញ្ជូនទៅថ្នាក់លើ ជាពិសេសគាត់បានបញ្ជាក់ថា គឺគាត់ជាមនុស្សគួរឲ្យទុកចិត្ត ហើយគឺជាអ្នកជំនាញខាងសន្តិសុខហើយនិងការសួរចម្លើយ។

តុលាការបានឃើញឧទាហរណ៍មួយចំនួនច្រើន ទាក់ទងនឹងចម្លើយសារភាព ហើយនិងរបាយ-ការណ៍សង្ខេបនៅក្នុងសេចក្តីសន្និដ្ឋាន ហើយបានស្នើសុំឲ្យមានការអនុញ្ញាតដើម្បីឲ្យមានការចាប់ខ្លួនថែមទៀត។ ជនជាប់ចោទមានរូបថតគ្រប់ទាំងអស់ ទោះបីជាឥឡូវនេះសាមសិបឆ្នាំក្រោយពីបទល្មើសក៏ដោយ កំណត់ហេតុជាលម្អិតទំនាក់ទំនងរវាងមេដឹកនាំកម្មាភិបាលបក្សក៏ដោយ គាត់ក៏បានកំណត់អំពីផែនការ ហើយក៏ជាដំណោះស្រាយចុងក្រោយដែលថា អាចជាការកំណត់នូវខ្សែក្បត់ ហើយគាត់ទទួល

ស្គាល់ ហើយអាចនឹងបញ្ចូលនូវការបង្ហាញអំពីគំនិតក្បត់ដែលគាត់បានចងក្រង ហើយបញ្ជាក់ពីបទឧក្រិដ្ឋដែលកើតឡើងនៅស-២១ ឯកសារដែលមានចំណងជើងថា "ផែនការរួមចុងក្រោយមួយនោះ"។ ផែនការនេះដែលរៀបរៀងឡើងដោយជនជាប់ចោទ ដែលចងក្រងតាមការណែនាំរបស់ជនជាប់ចោទគឺប៉ុន គឺជំរុញឲ្យមានចម្លើយសារភាព ឲ្យមាន ឲ្យអ្នកនោះឆ្លើយបញ្ជាក់អំពីផែនការក្បត់របស់គេនោះ។ ផែនការនេះគឺចុះនៅថ្ងៃទីនៅឆ្នាំ១៩៧៨ គឺការងារគឺពង្រីកនូវបញ្ញាញាណដែលចងក្រងដោយក្រុមសួរចម្លើយរបស់គាត់ ដើម្បីជួយដល់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដើម្បីសម្លាប់ខ្មាំងរបស់របបឲ្យកាន់តែច្រើនឡើង។ នេះហើយក្នុងពេលមួយ នៅពេលដែលគាត់និយាយថា គាត់ខកចិត្តជាមួយបក្សនោះក៏ដោយគាត់ថាគាត់មានការភ័យខ្លាចកាលនោះក៏ដោយ។

[១៤:៣៧:០១]

ឥឡូវនេះខ្ញុំនឹងចូលទៅដល់តួនាទីរបស់ជនជាប់ចោទនៅក្នុងការសម្លាប់ជនរងគ្រោះ១២.០០០នាក់នៅស-២១។ បទឧក្រិដ្ឋនៅស-២១ គឺជាមនុស្សឃាត គឺជាបទឧក្រិដ្ឋមួយ គឺអ្នកទោសនៅស-២១ គឺគេប៉ងដើម្បីសម្លាប់ដោយមិនគិតពីភេទប្រវត្តិ ឬក៏អ្វីនោះទេ នេះគឺជាភ័ស្តុតាងដែលមានបង្ហាញនៅក្នុងភ័ស្តុតាងដែលបញ្ជាក់ថា ជនជាប់ចោទបញ្ជាឲ្យមានការសម្លាប់ គឺជាស្ថានភាពមួយដែលមិនមានក្តីមេត្តា ហើយជាការងារដែលមានប្រសិទ្ធភាព បញ្ជីអ្នកទោសដែលមានកុមារប្រាំបួននាក់ បញ្ជាឲ្យពូ ប៉េង សម្លាប់ទាំងអស់សម្លាប់ឲ្យហ្មត់ សួរចម្លើយបួន ហើយសម្លាប់ចោលទាំងអស់ នេះជាចំណាររបស់គាត់ ហើយគាត់បញ្ជាក់ថា "កម្ទេច"។

តាមពិត ដោយសារទំហំការងាររបស់គាត់ ដើម្បីរៀបចំការចាប់ខ្លួន ការឃុំខ្លួនទារុណកម្ម និងសម្លាប់ជាមធ្យម ជាពិសេសគឺ៣០០អ្នកទោសក្នុងមួយខែ គឺការសម្លាប់។ ដូចដែលយើងកត់សម្គាល់ពីខាងដើម ជនជាប់ចោទបានបង្រៀនផ្ទាល់ទៅបុគ្គលិកអំពីការសួរចម្លើយទារុណកម្ម ហើយគាត់អាចសម្រេចគោលការណ៍របស់គាត់ គឺអាចធ្វើឲ្យបានមានប្រសិទ្ធភាព។ គាត់រៀបចំបុគ្គលិករបស់គាត់សម្ភារៈឲ្យអស់ពីសមត្ថភាពដើម្បីធានាបក្សកុម្មុយនីស្តកម្ពុជាអាចចាប់មនុស្សហើយសម្លាប់ខ្មាំងឲ្យបានច្រើនបំផុតតាមតែអាចធ្វើទៅបាន។ ដូចដែលបើយើងបានពិភាក្សាហើយ គឺជនជាប់ចោទបានអះអាងថា ការយល់ព្រមរបស់ថ្នាក់លើរបស់គាត់ត្រូវការជាចាំចំពោះការទារុណកម្ម និងការសម្លាប់។ ភ័ស្តុតាងនេះ គឺមិនសំខាន់ទេ ទោះបីជាជនជាប់ចោទទទួលខុសត្រូវលើប្រតិបត្តិការទាំងស្រុងនៃស-២១។

ក្នុងករណីណាក៏ដោយ បើសិនជាតើត្រូវការបញ្ជាពីថ្នាក់លើដែរឬអត់? ជនជាប់ចោទបានបញ្ជា

បន្តបញ្ជាហើយអនុវត្ត ហើយគាត់បានទទួលស្គាល់ថា បន្ទាប់ពីមានឧប្បត្តិហេតុមួយ គាត់បានបញ្ជូន ហ៊ាជាអនុប្រធាន ដែលបានបញ្ជូនអ្នកទោសទៅសម្លាប់ ដោយមិនបានបញ្ចប់ចម្លើយសារភាព។ សុន សេន បានតម្រូវថាឱ្យមានការឯកភាពជាមុនពីជនជាប់ចោទដើម្បីនឹងសម្លាប់អ្នកទោស ប៉ុន្តែដោយមិនគិតពីហេតុការណ៍នេះយើងដឹងទាំងស្រុង ហើយគាត់បានជាអ្នកឯកភាពបង្កើតស-២១ ថ្នាក់ដឹកនាំមានការរវល់ច្រើន ហើយគេពិបាកនឹងពិនិត្យករណីនីមួយៗខុសតែពីរអ្នកទោសសំខាន់ៗ។ ប៉ុន្តែ អ្នកទោសភាគច្រើនគេបានទុកចិត្តឱ្យជនជាប់ចោទ អនុវត្តការសម្រេចរបស់គាត់ដោយមិនពិភក្សាជាមួយថ្នាក់លើនោះទេ។ មេថ្នាក់លើបានអនុញ្ញាតឱ្យជនជាប់ចោទសម្លាប់អ្នកណាម្នាក់ កាលណាដល់ពេលត្រូវធ្វើដូច្នោះ។

[១៤:៤០:២៤]

លោក លោកស្រីចៅក្រម នៅពេលដែលយើងពិនិត្យមើលភ័ស្តុតាងជនជាប់ចោទ បានផ្តួចផ្តើមគំនិតដោយប្រសិទ្ធភាព ហើយបានព្យាយាមដោយមានការពេញចិត្ត ដោយមានមោទនភាព ហើយមិនមានចម្ងល់អ្វីទេ គាត់គឺជាអ្នកចូលរួមដ៏មានឆន្ទៈក្នុងបទឧក្រិដ្ឋនេះ។ មេធាវីការពារបានបង្កើតនូវចម្ងល់ថាជនជាប់ចោទបានធ្វើការងារហ្នឹងគឺដោយមានភាពស្ទាក់ស្ទើរ ហើយគាត់ធ្វើការងារហ្នឹងក្នុងភាពភ័យខ្លាចនោះទេ។ មេធាវីការពារបានស្នើឱ្យអង្គជំនុំជម្រះឱ្យងាកឆ្ងាយ ហើយឱ្យទទួលស្គាល់ទ្រឹស្តីមួយដែលមានមូលដ្ឋានតិចតួចសោះនៅក្នុងនោះ ហើយទោះបីជានៅក្នុងគំនិតនៃការទទួលស្គាល់របស់ជនជាប់ចោទក៏ដោយ។

ក្រៅពីអ្វីដែលថា ជាគោលនយោបាយឧក្រិដ្ឋរបស់ខ្មែរក្រហមនោះ គឺជនជាប់ចោទគឺអ្នកមានជំនឿមុតមាំនៅក្នុងមនោគមវិជ្ជាខ្មែរក្រហមហើយទទួលការអប់រំពីបដិវត្តនោះ។ ផ្អែកលើប្រវត្តិទស្សនវិជ្ជាកុម្មុយនីស្តហើយបង្ហាញថា គាត់ជាបុគ្គលមួយរូបមានជំនាញ ហើយស្ថិតនៅក្នុងស្មារតីនៃបដិវត្តន៍ ហើយមានជំនាញខាងសន្តិសុខនៅក្នុងរបបនេះ គឺឱ្យអនុវត្តទៅដោយប្រសិទ្ធភាព។ គាត់អះអាងថា គាត់ជឿបដិវត្តតាំងពីដំបូងមក ប៉ុន្តែគាត់ជាប់អន្ទាក់នៅក្នុងរបបនោះបន្ទាប់បីឆ្នាំ១៩៧១ ប៉ុន្តែភ័ស្តុតាងទាំងអស់បានបង្ហាញថា មិនដូច្នោះទេ។ ដោយហេតុមេធាវីការពារ បានបញ្ជាក់ហើយថាមិនមាននរណាម្នាក់ចងក្លាយទៅជាអ្នកសម្លាប់រង្គាលនោះទេ ប៉ុន្តែនៅក្នុងករណីនេះជនជាប់ចោទបានបង្កើតនូវភាពងប់ងល់មួយនៅក្នុងមនោគមវិជ្ជាបក្សកុម្មុយនីស្តកម្ពុជា ដែលគាត់ចង់ធ្វើអ្វីទាំងអស់ដើម្បីពង្រីកនយោបាយនោះ។ តាមពិតលក្ខណៈ ហើយនិងទំហំនៃបទឧក្រិដ្ឋនៅក្នុងស-២១ មិនអាចបង្ហាញយុត្តិកម្មបានទេ ថាតើជនជាប់ចោទនោះអាចយល់ពីគោលបំណង ឬមិនយល់ថាចង់បានបែបណានោះទេ។

កម្រិតនៃការចូលក្នុងបទឧក្រិដ្ឋនៅក្នុងម-១៣ និងស-២១ មិនបានផ្តល់ការសង្ស័យណាមួយដែលបញ្ជាក់ថា គាត់មិនមែនជាអ្នកគាំទ្របក្សកុម្មុយនីស្តកម្ពុជា ហើយធ្វើការងារនោះមិនពេញចិត្ត ហើយគាត់ជាចំណាប់ចិត្តនៃរបបនោះនោះឡើយ។

[១៤:៤៣:១៨]

ដូចដែលខ្ញុំបានជម្រាបខាងដើម លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ មានឱកាសមួយដើម្បីអង្កេតអំពីការជឿជាក់របស់ជនជាប់ចោទ ហើយផ្អែកទៅលើចម្លើយសារភាពមួយចំនួនដែលគាត់បានមើល ពិនិត្យមើលនៅក្នុងឆ្នាំ១៩៧១ នៅពេលដែលគេដោះលែងគាត់ គាត់ជឿថា គឺជាមនុស្សតែម្នាក់គត់ដែលគាត់បានដោះលែង។ ខ្ញុំសូមដកស្រង់ "ខ្ញុំដឹងថានៅចំពោះមុខខ្ញុំ គឺជាមនុស្សម្នាក់ដូចជាមិត្តរបស់ខ្ញុំដែរ គឺជាអ្នកម៉ាក្សស៊ីសនិយមដែលគាត់បានរៀបចំប្រគល់ជីវិតរបស់គាត់ដើម្បីប្រទេសគាត់ ហើយដើម្បីបដិវត្ត"។ នៅពេលដែល ប៊ីហ្សូ ពិនិត្យឃើញនោះគឺ ប្រាំមួយខែ បន្ទាប់ពីជនជាប់ចោទបានកាន់កាប់ម-១៣ គឺជាពេលដែលគាត់បានប្រព្រឹត្តការវាយដំទៅលើអ្នកជាប់ទោសដូចដែល ប៊ីហ្សូ ប្រាប់យើង។ ការជឿជាក់របស់គាត់ទៅលើបក្សកុម្មុយនីស្តកម្ពុជា។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី និងប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤៤នាទី ដល់ម៉ោង ១៥:០៥នាទី]*

[១៥:០៦:៣០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អញ្ជើញសវនាការអន្តរជាតិដើម្បីបន្តនូវសេចក្តីថ្លែងការណ៍នៃសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន។

ខ្ញុំបានបញ្ឈប់សេចក្តីសន្និដ្ឋានរបស់ខ្ញុំនៅពេលយើងសម្រាក ហើយខ្ញុំបានរៀបរាប់អំពីភស្តុតាងជាក់លាក់ដែលបញ្ជាក់អំពីជំនឿដែលជនជាប់ចោទមានចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរម-១៣។ ហើយយើងបានលើកឡើងអំពីមតិយោបល់ និងការជឿជាក់របស់លោក ហ្វ្រង់ស្វ័រ ប៊ីហ្សូ ផងដែរ។ ការជឿជាក់នៅក្នុងមនោគមវិជ្ជាបក្ស គឺនៅតោងជាប់ជនរូបនេះបន្ទាប់ពីម-១៣ និងក្នុងអំឡុងពេលស-២១ ហើយក្រោយមកទៀត ដូចដែលខ្ញុំលើកឡើងពីមុនទំនាក់ទំនងជិតស្និទ្ធជាមួយ សុន សេន គាត់នៅតែមាន។ ហើយយើងឃើញថា ជនជាប់ចោទគឺជាអ្នកគ្រប់គ្រងផ្ទាល់ហើយជាអ្នកចូលរួមផ្ទាល់ទៅលើឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងប្រទេសនេះទាំងមូលក្នុងកម្រិតខ្ពស់។ នៅពេលជំនុំជម្រះ នៅពេលដែលសួរគាត់ជនជាប់ចោទបានឆ្លើយតបថា គឺជាពេលមួយដែលខ្ញុំកំពុងតែរង់ចាំដើម្បីលាតត្រដាងការពិតជូនពិភពលោក និងប្រទេសកម្ពុជា ខ្ញុំមានការតក់ស្លុតនៅពេលដែលខ្មាំងឆ្លើយដាក់ សុន សេន ខ្ញុំមានការបារម្ភចំពោះគាត់។ ក្រោយមកនៅថ្ងៃទី២៥ ខែមិថុនាឆ្នាំ១៩៨៦ ខ្ញុំនៅតែមានសេចក្តីគោរពទៅលើគាត់ធំធេង ហើយនៅតែស្មោះត្រង់ចំពោះគាត់។

សុន សេន រួមជាមួយនឹងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៅក្នុងបក្ស ជាគំរូនៃគោលនយោបាយឧក្រិដ្ឋនៃបដិវត្តន៍ គាត់ជាអ្នកផ្តួចផ្តើមនៃការបង្កើតមន្ទីរស-២១ ហើយគ្រប់គ្រងទៅលើប្រតិបត្តិការរបស់មន្ទីរនេះ។ យោងតាមសម្តីរបស់ជនជាប់ចោទ គាត់គឺជាបុគ្គលមួយរូបដែលគំរាមកំហែងអាយុជីវិតរបស់គាត់ប្រសិនបើគាត់មិនបំពេញការងារដោយប្រុងប្រយ័ត្ន ជនរូបនោះគឺមិនផ្តល់ឱកាស និងជម្រើសដល់គាត់ក្នុងការរត់ចេញពីការភ័យខ្លាចនៃមន្ទីរម-១៣ និងស-២១។

បន្ទាប់មក ក្រោយពីរយៈពេលជាច្រើនឆ្នាំបន្ទាប់ពីការដួលរលំនៃរបបនេះជនជាប់ចោទនៅតែគោរពជនរូបនោះ ហើយនៅខ្លាចភ័យព្រួយចំពោះសុវត្ថិភាពរបស់ជនរូបនោះ។ តើឱ្យយើងទទួលយកនៅចំណុចនេះយ៉ាងដូចម្តេច បើជនរូបនេះអាចមានការគោរពធំធេង និងស្មោះត្រង់ចំពោះជនរូបនោះដែលជនរូបនោះបានបង្ខំជនជាប់ចោទឱ្យប្រព្រឹត្តអំពើដ៏ញញើតក្រោមការគំរាមកំហែងសម្លាប់បុរសដែលធ្វើការបង្ខំជនជាប់ចោទឱ្យធ្វើការប្រព្រឹត្តអំពើឃោរឃៅ ព្រួយបារម្ភសោកនាដកម្មទៅលើប្រជាជនជាច្រើន។

[១៥:១០:១២]

មិនមានភាពស្ទាក់ស្ទើរឡើយ ហើយមិនមានការគំរាមកំហែងឡើយជនជាប់ចោទ និង សុន សេន គឺជាបងប្អូនរួមអាវុធក្នុងចលនាមនោគមវិជ្ជា ដែលនាំទៅរកផ្លូវខុស ហើយបានរៀបចំខ្លួនក្នុងការលក់ខ្លួន ព្រលឹងចិត្តរបស់ខ្លួន ហើយនិងមនុស្សធម៌របស់ខ្លួន។ ជនជាប់ចោទ បាននិយាយជាច្រើននៅក្នុងសវនាការហើយជាទូទៅបានគេចចេញពីចម្លើយចំពោះសំណួរដោយផ្ទាល់ វាមានប្រយោជន៍នៅពេលឱ្យជនរូបនេះនិយាយដោយសេរីដើម្បីឱ្យជនរូបនេះ ធ្លាយមាត់លើពាក្យកុហករបស់ខ្លួនថាខ្លួនជាពេជ្ឈឃាដដែលគ្មានឆន្ទៈ និងពោរពេញដោយការភ័យខ្លាចនៅមន្ទីរស-២១។

ឧទាហរណ៍ នៅពេលដែលផ្តល់ចម្លើយអំពីវត្តមានរបស់ជនបក្សកុម្មុយនីស្តកម្ពុជានៅក្នុងវគ្គអប់រំនយោបាយរយៈពេលពីរសប្តាហ៍នៅចុងឆ្នាំ១៩៧៨ គាត់ពន្យល់អំពីអារម្មណ៍ដែលគាត់បានជួបជាមួយ ប៉ុល ពត ការនិយាយដូច្នេះគឺជាការធ្លោយចេញពីមាត់របស់ជនជាប់ចោទ។ លោកលើកឡើងមុនថាសមាជិកបក្សនឹងច្រណែនប្រសិនបើបក្សជនបានជួប ប៉ុល ពត តើលោកពិចារណាជាបុព្វសិទ្ធិរបស់លោក ឬក៏យ៉ាងម៉េចនៅពេលដែលមានវត្តមានរបស់ ប៉ុល ពត។ ខ្ញុំសូមនិយាយដោយស្មោះត្រង់ថា នៅពេលនោះខ្ញុំមានអារម្មណ៍ចម្លែកនៅពេលដែលខ្ញុំទៅរៀន ដែលខ្ញុំរៀនជាមួយកម្មាភិបាលប្រាំពីររូបក្នុងរយៈពេលបីឆ្នាំ តែនៅពេលនេះខ្ញុំជួបបុគ្គលទីមួយក្នុងជួរបក្សជាលើកដំបូង ខ្ញុំមានអារម្មណ៍ចម្លែកណាស់ ប៉ុន្តែខ្ញុំពិបាកក្នុងការនិយាយ និងរៀបរាប់អារម្មណ៍នោះណាស់នៅពេលនោះ។ សំណួរ៖ ថាតើលោករីករាយទេនៅពេលដែលមានវត្តមានរបស់ ប៉ុល ពត? ឆ្លើយ៖ អារម្មណ៍ចម្លែកនោះមានន័យថា គឺជាអារម្មណ៍មួយដ៏ល្អ។

លោក លោកស្រីចៅក្រម, អារម្មណ៍ដ៏ល្អនេះគឺនិយាយអំពីការដែលគាត់ជួប ប៉ុល ពត។ ប្រសិនបើជនជាប់ចោទខឹងបុគ្គលណាម្នាក់ដែលធ្វើឱ្យខ្លួនប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងឆន្ទៈរបស់ខ្លួន បុគ្គលនោះគឺ ប៉ុល ពត បងធំទីមួយជាមេដឹកនាំចលនាបក្សកុម្មុយនីស្តកម្ពុជា ដែលរួមជាមួយអ្នកដទៃទៀតបង្កើតផែនការ បង្កើតឧក្រិដ្ឋកម្មស-២១ដែលជាផ្នែកមួយដ៏សំខាន់ ប្រសិនបើជនជាប់ចោទមានមោទនភាពនៅពេលដែលជួប ប៉ុល ពត ដោយសារតែគាត់មានភាពស្មោះស្ម័គ្រ និងគាត់មានការគោរពចំពោះ សុន សេន ការនិយាយដោយស្មោះត្រង់នេះផ្តល់ឱ្យយើងយល់យ៉ាងច្បាស់អំពីជំនឿរបស់គាត់ដែលគាត់មាន ហើយនិងសមត្ថភាពរបស់គាត់ក្នុងការប្រព្រឹត្តអំពើគួរឱ្យខ្លាច។

[១៥:១៣:០៩]

ខ្ញុំសូមជម្រាបលោក លោកស្រីចៅក្រមថា កិច្ចប្រជុំនោះគឺវាកើតឡើងនៅឆមាសទីពីរនៅឆ្នាំ

១៩៧៨ នៅពេលដែលជនជាប់ចោទចង់ឲ្យគេជឿថា គាត់មានការស្រងាកចិត្តខាងខ្លាំងជាមួយគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ ចម្លើយរបស់គាត់នៅពេលក្រោយនៅចុងសវនាការ គាត់និយាយថា ជនជាប់ចោទនិយាយថា គាត់រីករាយដែលជួប ប៉ុល ពត ដោយសារតែ ប៉ុល ពត គាត់បាននិយាយថា មិនមានការប្រហារជីវិតច្រើនទៀតទេ ដែលវាជាការព្យាយាមមួយនៅការគេចកែនូវចម្លើយរបស់គាត់ ដែលវាទំនងជាដាក់បន្ទុកទៅលើគាត់។

មោទនភាពនិងការសរសើរបក្ស យើងឃើញថាគាត់មានមោទនភាពដែលគាត់បានសិក្សាចេញពីបក្ស។ នៅក្នុងចម្លើយដ៏វែងគាត់បានលើកឡើងនៅក្នុងករណីនេះ គាត់បានផ្តល់ចន្លោះតូចៗឲ្យយើងច្របាច់ចូលគ្នាដើម្បីរកការពិតជាងនេះ។ គាត់បានផ្តល់ការយល់ឃើញលើរូបថតរបស់គាត់នៅស-២១ ដែលគាត់អង្គុយក្នុងឯកសណ្ឋាននៅខាងក្រោយមីក្រូហ្វូនអប់រំបុគ្គលិកសិស្ស និងគោលនយោបាយបក្ស ហើយគាត់លើកឡើងថា ប្រសិនបើអ្នកមើលរូបថតនៅពេលនេះវាហាក់ដូចខ្ញុំមានអារម្មណ៍មោទនភាពណាស់ដែលនៅពេលនោះ ខ្ញុំអាចណែនាំឲ្យគេរក្សាវណ្ណៈឲ្យបានរឹងមាំ។ ហើយគាត់បានលើកឡើងថាមានគាត់គឺជាជនមួយរូបដែលគេអនុញ្ញាតឲ្យប្រើប្រាស់ឧបករណ៍និយាយមីក្រូហ្វូនបង្រៀនទៅដល់បុគ្គលិក។

ដូច្នេះ វាបង្ហាញយ៉ាងច្បាស់ថា ជនជាប់ចោទមានមោទនភាពក្នុងការទទួលយកការណែនាំ ហើយមានមោទនភាពក្នុងការបញ្ជូនការណែនាំបន្ត។ គាត់ក៏បានជម្រាបលោក លោកស្រីចៅក្រមអំពីមោទន-ភាពដែល សុន សុន ទទួលយកសំណើ គាត់ចង់ប្តូរស-២១ទៅទីតាំងវិទ្យាល័យពញាយ៉ាត គាត់មានភាពមោទនភាពនៅស-២១ និងស-២៤ក្នុងឆ្នាំ១៩៧៨ នៅពេលនោះដែលគាត់និយាយថា គាត់មានភាពស្រងាកចិត្តនឹងបក្ស។ គាត់បានិយាយថា គាត់ចង់លើកកេរ្តិ៍ឈ្មោះព្រៃស និងស-២១ នៅក្នុងឋានានុក្រមនៃបក្សកុម្មុយនីស្តកម្ពុជា តាមរយៈផ្តល់ស្រូវលើសលប់ទៅឲ្យបក្សមជ្ឈិមពីព្រៃស។ ពេលនោះដែរយើងឃើញថា អ្នកទោសនៅស-២១ និងស-២៤ បានស្លាប់ដោយសារអត់អាហារ។ តើអាចឲ្យបុគ្គលម្នាក់មានមោទនភាពលើមេរបស់ខ្លួនយ៉ាងដូចម្តេច? តើអាចឲ្យបុគ្គលម្នាក់មានមោទនភាពលើការបង្កើត និងការប្រតិបត្តិការមន្ទីរសម្លាប់រង្គាលយ៉ាងដូចម្តេច? តើអាចឲ្យបុគ្គលម្នាក់មានមោទនភាពក្នុងការបំពាក់បំប៉នបុគ្គលិកខ្លួន ឲ្យធ្វើទារុណកម្មនិងសម្លាប់យ៉ាងដូចម្តេច? តើឲ្យបុគ្គលម្នាក់មានមោទនភាពលើកេរ្តិ៍ឈ្មោះរបស់មន្ទីរដ៏អាក្រក់នេះយ៉ាងដូចម្តេច?

ចំណុចទាំងអស់នេះគឺដោយសារតែគាត់ជឿលើបក្ស គាត់ជឿទៅលើមនោគមវិជ្ជា ហើយគាត់

ពេញចិត្តទៅលើការងាររបស់គាត់ដែលបក្សក៏ជឿទៅលើគាត់ផងដែរ។ ជំនឿរបស់គាត់នៅក្នុងមនោគមវិជ្ជាបក្ស គឺជាភ័ស្តុតាងយ៉ាងច្បាស់នៅក្នុងការធ្វើសេចក្ដីសម្រេច ដែលគាត់បានធ្វើឡើងក្នុងខ្សែជីវិតរបស់គាត់។ សេចក្ដីសម្រេចដែលបង្ហាញអំពីទំនុកចិត្ត និងការដាក់ចិត្តដាក់កាយរបស់គាត់នៅក្នុងបដិវត្តបន្ទាប់ពីគាត់បានបញ្ចប់ការងារនៅម-១៣ នៅក្នុងពាក់កណ្ដាលឆ្នាំ១៩៧៥។ គាត់បានដឹងយ៉ាងច្បាស់ថាការងារបន្ទាប់របស់គាត់នឹងទាមទារឲ្យគាត់ធ្វើការធ្វើទារុណកម្មបន្ត និងសម្លាប់ខ្មាំងដែលចោទប្រកាន់ថាជាខ្មាំងបក្ស។ នៅពេលនោះគាត់គឺជាបុរសមានវ័យក្មេងគាត់នៅលីវ គាត់បានរៀបការជាមួយស្ត្រីដែលគាត់បានជ្រើសរើសនៅចុងឆ្នាំ១៩៧៥ ដែលពេលនោះមិនចំពេលដែលជាការយល់ឃើញអំពីការងាររបស់គាត់នាពេលអនាគតនោះទេ។ នៅពេលដែលគាត់រៀបការគាត់បានចាប់ផ្ដើមចូលរួមនៅក្នុងការធ្វើទារុណកម្ម ការសម្លាប់ក្រុមទីមួយនៃអ្នកទោសដែលត្រូវបានគេដកចេញមកពីតាខ្មៅបញ្ចូលនៅក្នុងទីតាំងបណ្ដោះអាសន្នស-២១ ក្នុងទីក្រុងភ្នំពេញ។ ចំនួនស្លាប់ដែលកើនឡើងយ៉ាងលឿននៅមន្ទីរស-២១ មិនបានធ្វើឲ្យជនជាប់ចោទពុំចង់រៀបការឡើយ។

[១៥:១៧:៤៤]

នៅក្នុងឆ្នាំ១៩៧៦ ប្រពន្ធរបស់គាត់បានផ្ដល់កំណើតទៅដល់កូនទីមួយ ហើយនៅក្នុងឆ្នាំ១៩៧៨ គាត់ផ្ដល់ប្រពន្ធរបស់គាត់ផ្ដល់កូនទីពីរ។ គាត់គឺជាឪពុកដែលមានកូនពីររូបខណៈកូនដទៃទៀត ត្រូវបានគេចាប់ខ្លួនសម្លាប់ចោលជាមួយឪពុកម្ដាយនៅស-២១។ ម៉្យាងវិញទៀត គាត់បាននិយាយថា គាត់មិនត្រឹមតែចង់ចញ្ចឹមក្មេងនោះទេ គាត់ចង់ឲ្យពួកគេចូលរួមក្នុងបដិវត្តបក្សកុម្មុយនីស្តកម្ពុជា តាមសម្ដីរបស់គាត់គាត់ចង់ឲ្យពួកគេ-- ដកស្រង់សម្ដីរបស់គាត់គឺចង់ឲ្យពួកគេស្រលាញ់បដិវត្ត និងចូលរួមបដិវត្ត។ ហេតុអ្វីបានជាគាត់មានការកាត់ផ្ដាច់គួរឲ្យខ្លាចចំពោះមនុស្សធម៌ជុំវិញខ្លួនគាត់ គាត់ដឹងថាគាត់កំពុងតែចិញ្ចឹមបីបាច់កូនរបស់គាត់ ប៉ុន្តែគាត់បានបញ្ឈប់ និងបង្អត់អាហារសម្លាប់អ្នកដទៃ។

វាជាការផ្ទុយគ្នាទាំងស្រុងដែលជនជាប់ចោទបាននិយាយថា គាត់ឲ្យតុលាការជឿថា គាត់ស្អប់បក្សកុម្មុយនីស្តកម្ពុជា ហើយនៅពេលជាមួយគ្នាគាត់បែជាបានរៀបការ ហើយបានចិញ្ចឹមកូនរបស់គាត់ ហើយជឿទៅលើបក្សនិងគោលនយោបាយបក្ស។ ការប្ដេជ្ញាយ៉ាងពិតប្រាកដ និងដាច់ខាតចំពោះបក្សក្នុងអំឡុងពេលនៅស-២១បានបញ្ជាក់ដោយភ័ស្តុតាងពីអ្នកសាក្សីជំនាញនៅក្នុងសវនាការនេះ។

នៅក្នុងរបាយការណ៍រួមបណ្ឌិត កាស៊ិន បូណាត បណ្ឌិត ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្គៀលបូ គឺបានផ្ដល់ចម្លើយជំនាញថា ជនជាប់ចោទប្ដេជ្ញាចំពោះបដិវត្ត បក្សកុម្មុយនីស្តកម្ពុជាក្នុងពេលនៅស-២១។ នៅពេល

រៀបរាប់ពិភាក្សាអំពីហេតុអ្វីបានជនជាប់ចោទបានអនុវត្តតាមបញ្ជាក្នុងការធ្វើទារុណកម្មនិងសម្លាប់។

[១៥:១៩:៤២]

ពួកអ្នកជំនាញបានលើកឡើងថា ខ្ញុំដកស្រង់សម្តី “ការជំរុញចិត្តលើអំពើទាំងអស់របស់ជនជាប់ចោទនោះ គឺមិនមែនជាភាពចាំបាច់ក្នុងការគោរពបញ្ជានោះទេ។ ការគោរពបញ្ជាគឺជាផលវិបាកនៃអំពើរបស់គាត់ គឺប៉ុន្តែវាជាផលវិបាកនៃភាពចាំបាច់ដែលឲ្យបុគ្គលម្នាក់ជឿទៅលើចំណុចណាមួយនោះ”។

ទោះបីពួកគេទទួលយកការភ័យខ្លាចយកមកពិចារណាក៏ដោយ ពួកគេបានលើកឡើងថា-- អ្នកជំនាញបានលើកឡើងថា ជំនឿនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា មិនមែនការភ័យខ្លាចទេដែលជាចលករចម្បងរបស់ជនជាប់ចោទ។ អ្នកជំនាញសន្និដ្ឋានថា ជនជាប់ចោទ ឃើញខ្លួន-- ថាជនជាប់យល់ថា ខ្លួនឯងជាអ្នកការពារមជ្ឈិមបក្ស ហើយតួនាទីរបស់គាត់នេះវាមានន័យចំពោះគាត់។ បន្ថែមពីនេះ ជនជាប់ចោទបានបញ្ជាក់ជូនអ្នកជំនាញថាគាត់នៅតែមានជំនឿទៅលើមនោគមវិជ្ជាបក្ស បន្ទាប់ពីបិទស-២១។

នៅពេលអ្នកជំនាញសួរគាត់អំពីស្លាប់ឪពុករបស់គាត់នៅក្នុងឆ្នាំ១៩៨០ គាត់បានឆ្លើយតបថា គាត់បានបដិសេធមិនឲ្យមានអារម្មណ៍ឡើយ ពីព្រោះយើងមិនអាចជាជនបដិវត្តន៍ ហើយមានអារម្មណ៍នោះទេ។ ដូច្នេះ ភាពជឿជាក់នៃយោបល់ទាំងអស់នេះ គឺយើងត្រូវយកមកពិចារណា ដែលគាត់បានចំណាយរយៈពេលសាមសិបម៉ោងជាមួយជនជាប់ចោទ។ វាគឺជាបរិយាកាសឯកជនមួយដែលអនុញ្ញាតឲ្យមានជិតស្និតជាងនៅក្នុងតុលាការ ហើយបានសួរទៅលើជនជាប់ចោទយ៉ាងក្បោះក្បាយជាងនៅដំណាក់កាលស៊ើបអង្កេត។

ដូច្នេះ នៅពេលដែលជនជាប់ចោទនិយាយកាន់តែច្រើន គាត់ហាក់ដូចជាលាតត្រដាងនូវការពិតដោយមិនដឹងខ្លួន។ អង្គហេតុទាំងអស់នេះ គឺវាទាក់ទងទៅនឹងរយៈពេល និងទីកន្លែងដែលអ្នកជំនាញគាត់បានសម្ភាសន៍ជាមួយជនជាប់ចោទ ហើយពេលនោះដែលអនុញ្ញាតឲ្យអ្នកជំនាញធ្វើការរកឃើញនូវចំណុចជឿជាក់ ដែលតុលាការមិនមាននូវភ័ស្តុតាងទាំងអស់នេះ។ តុលាការក៏បានស្តាប់សក្ខីកម្ម របស់អ្នកជំនាញ ដេវីដ ឆេនឌ័ល័រ ដែលគាត់ជាអ្នកប្រាជ្ញាល្បីមួយរូបស្រាវជ្រាវលើការងារផ្ទៃក្នុងស-២១ និងបក្សកុម្មុយនីស្តកម្ពុជា។ អ្នកជំនាញបានពិនិត្យចម្លើយសារភាពរាប់រយ រួមទាំងចំណាររបស់ជនជាប់ចោទ គាត់បានផ្តល់យោបល់យ៉ាងរឹងមាំថា ជនជាប់ចោទមានជំនឿទៅលើការងាររបស់គាត់នៅស-២១ ហើយគាត់មិនមែនស្អប់ការងារនោះឡើយ។

[១៥:២២:១៧]

នៅពេលដែលមេធាវីការពារក្ដីសួរអំពីការចូលចិត្តរបស់ការងាររបស់ជនជាប់ចោទនៅ ស-២១ ថា តើវាជាមាគ៌ារបស់បក្ស ឬក៏យ៉ាងម៉េច? អ្នកជំនាញ ដេវីដ ឆេនដ័ល័រ បានឆ្លើយថា ខ្ញុំសូមដកស្រង់សម្ដី វាមិនត្រឹមតែជាផ្នែកមួយនៃមាគ៌ាបក្សនោះទេ វាជាផ្នែកមួយនៃមាគ៌ាបក្សដែលជនជាប់ចោទទទួលយកមកបំពេញដោយគ្មានបញ្ហា។ ការងារនេះត្រូវចិត្ត និងសមត្ថភាពរបស់គាត់ ហើយគាត់ គឺជាបក្ខជនបដិវត្តន៍មួយរូប។ បណ្ឌិត ឆេនដ័ល័រ គាត់បានពន្យល់បន្ថែមអំពីវិជ្ជាជីវៈដែលជនជាប់ចោទបំពេញការងាររបស់ខ្លួននៅស-២១ រួមទាំងភាពសប្បាយ ភាពក្លៀវក្លា និងមោទនភាព និងផ្តួចផ្តើមការងាររបស់ជនរូបនោះ។ គាត់ប្រាប់ថា ជនជាប់ចោទប្រាប់ថា គាត់ចង់ឲ្យមេរបស់គាត់ និងសហគមន៍អន្តរជាតិចាត់ទុក ស-២១ ថាជា “មន្ទីរ អង្គការមួយដ៏មានវិជ្ជាជីវៈ ហើយដែលមានអ្នកគ្រប់គ្រងគួរឲ្យគោរព ហើយគាត់មានមោទនភាព”។

យើងបានសួរជាច្រើនទៅលើអ្នកជំនាញ ហើយយើងគួរផ្តោតទម្ងន់ធ្ងន់ទៅលើចម្លើយរបស់លោក ដេវីដ ឆេនដ័ល័រ ទាក់ទងទៅនឹងការស្រាវជ្រាវនៅស-២១។ សាស្ត្រាចារ្យ ឆេនដ័ល័រ គាត់បានសមត្ថភាពពិសេស ក្នុងការផ្តល់ដល់តុលាការទាក់ទងទៅនឹងការវិភាគនៃប្រតិបត្តិការស-២១ យ៉ាងគួរឲ្យជឿជាក់ រួមទាំងថា តើមន្ទីរស-២១ អនុវត្តគោលនយោបាយបក្សយ៉ាងដូចម្ដេច ហើយតើជនជាប់ចោទចូលរួមយ៉ាងដូចម្ដេច?

ចុងក្រោយ នៅថ្ងៃចុងក្រោយនៃការដេញដោល ជនជាប់ចោទហាក់ដូចជាសារភាពថា នៅពេលដែលគាត់នៅស-២១ គាត់ពិតជាជឿលើគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅពេលដែលមេធាវីការពារក្ដីសួរគាត់ថា តើអ្នកសារភាពថាអ្នកជាបុរសមួយរូបដែលទទួលការជឿជាក់ពីមេ អនុវត្តការងារដោយប្តូរផ្តាច់ ហើយគ្មានមេត្តាធម៌ដែរឬទេ? និងអនុវត្តការធ្វើទុក្ខបុកម្នេញរបស់បក្សកុម្មុយនីស្តកម្ពុជាលើប្រជាជនដែរឬទេ? តើលោកសារភាពលើចំណុចនេះដែរឬទេ? និងទទួលស្គាល់ដែរឬទេ? ជនជាប់ចោទឆ្លើយថា គាត់សារភាពទាំងស្រុងលើចំណុចនេះ។

លោក លោកស្រី ចៅក្រម, ប្រសិនបើគាត់មានន័យដូច្នោះមែន វាបង្ហាញថាជនជាប់ចោទបានសម្រេចចិត្តក្នុងទទួលយកនូវការពិត ប្រសិនបើជនជាប់ចោទនាពេលនេះនិយាយថា គាត់បានអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាតាមឆន្ទៈ មិនមែនអនុវត្តដោយភាពស្ទាក់ស្ទើរនោះឡើយ។ ប្រសិនបើគាត់ មានន័យថា គាត់ជឿលើគោលនយោបាយកម្មេច ថាជាមធ្យោបាយមួយដ៏ត្រឹមត្រូវ ដូច្នេះហើយចម្លើយរបស់គាត់មានការផ្លាស់ប្តូរ។

លោក លោកស្រី ចៅក្រម ជាទីគោរព, វាជាការបត់ចុះ បត់ឡើងនូវអ្វីដែលគាត់បានសារភាព ក្នុងអំឡុងពេលនៃការស៊ើបអង្កេតក្នុងសវនាការ។ ដូចដែល លោក លោកស្រី ចៅក្រម បានជ្រាប គាត់បានរៀបរាប់ដដែលៗថា គាត់ស្អប់ការងាររបស់គាត់ គាត់រស់ដោយភ័យខ្លាច គាត់ត្រូវបានគេបង្ខំ បញ្ជាឲ្យធ្វើទារុណកម្ម សម្លាប់ ហើយគ្មានជម្រើស និងឱកាសក្នុងការរត់គេចខ្លួន។ តើទាំងអស់ហ្នឹង គាត់ចង់និយាយថា ជាពាក្យ “ភក្តីភាព” ឬយ៉ាងម៉េច? បើសិនជាដូច្នេះមែន ពាក្យហ្នឹងវាគ្មានន័យអ្វីឡើយ។ ប៉ុន្តែប្រសិនបើគាត់នៅថ្ងៃចុងក្រោយ គាត់ធ្វើការផ្លាស់ប្តូរការសារភាពរបស់គាត់ ដោយផ្អែកទៅលើមូលហេតុ និងបំណង ដែលគាត់បានចូលរួមប្រព្រឹត្តឧក្រិដ្ឋ ដូច្នេះចំណុចនេះយើងស្វាគមន៍។

[១៥:២៥:៣៥]

ប៉ុន្តែលោក លោកស្រី ចៅក្រម វាយឺតៗពេលណាស់ទៅហើយ ការឈឺចាប់ដើមបណ្តឹងរដ្ឋប្បវេណីទទួលរងតាមរយៈការអង្គុយស្តាប់ពាក្យភូតភរនេះ មិនអាចកែប្រែ និងនិយាយឡើងវិញទេ។ យ៉ាងហោចណាស់ យើងទទួលស្គាល់ថា ជនជាប់ចោទគាត់ជួយឲ្យការកត់ត្រាអង្គហេតុបានត្រឹមត្រូវ។ ជាអកុសល ដរាបណាជនជាប់ចោទ គាត់ប្រាប់ថាគាត់ផ្លាស់ប្តូរចម្លើយសារភាពរបស់គាត់ដោយឆន្ទៈ និងហេតុផលរបស់គាត់នៅក្នុងចម្លើយសារភាព យើងអនុញ្ញាត និងស្នើសុំឲ្យគាត់ធ្វើដូច្នេះ។ ហើយវាក៏ជាផលល្អសម្រាប់ជនរងគ្រោះផងដែរ។ សំណួរសំខាន់ ហើយនិងស្រពេចស្រពិល ដែលគ្មានចម្លើយដែលបន្សល់ទុកនៅក្នុងសវនាការនេះ ហើយទុកឲ្យសាធារណជនធ្វើការសម្រេច និងពិចារណា ថាតើគាត់មានន័យយ៉ាងម៉េច? ដោយមិនគិតអំពីភាពសង្ស័យថា ជនជាប់ចោទទទួលស្គាល់ពេញលេញលើតួនាទីរបស់គាត់នៅ ស-២១ ដែរឬទេ? ភ័ស្តុតាងទាំងឡាយអំពីតួនាទីរបស់គាត់មានភាពច្បាស់លាស់ និងមិនស្រពេចស្រពិលឡើយ។

ចម្លើយ និងឯកសារដែលលោក លោកស្រី ចៅក្រម ស្តាប់ និងបានអានបង្ហាញថា គាត់គឺជាជនចូលរួមដ៏មានឆន្ទៈ ប្រព្រឹត្តឧក្រិដ្ឋកម្ម មិនមែនគាត់ត្រូវបានគេបញ្ជាឲ្យធ្វើដូច្នោះទេ គាត់គឺជាជនដែលមានជំនឿទៅលើភាពត្រឹមត្រូវនៃបញ្ជាទាំងអស់នោះ។

ដូច្នេះយើងឃើញថា គាត់គឺជាឧក្រិដ្ឋជនវក់នឹងការងារ ហើយគាត់ដឹងច្បាស់នូវអ្វីដែលកើតឡើងចំពោះមុខគាត់តាមរយៈប្រព័ន្ធនៃក្រឹតក្រមដ៏តឹងរ៉ឹង និងការរាយការណ៍ជាហូរហែ គាត់មានប្រសិទ្ធភាពក្នុងការអនុវត្តឧក្រិដ្ឋកម្មរបស់គាត់។ យើងមិនមែនស្នើសុំថា ជនជាប់ចោទគឺជាបិសាច និងមនុស្សអាក្រក់នោះទេ ហើយក៏យើងមិននិយាយថា គាត់មិនមែនជាមនុស្សដែរ។ ប៉ុន្តែ យើងសូមបដិសេធការ

អះអាងរបស់គាត់ថា គាត់គឺជាអ្នកទោសនៃរបបនេះ ហើយជាអ្នកចូលរួមដោយគ្មានឆន្ទៈ នៅក្នុងឧក្រិដ្ឋកម្ម។ ផ្អែកទៅលើភស្តុតាងទាំងឡាយ ការអះអាងដូច្នេះ គឺមិនមានមូលដ្ឋានទាល់តែសោះ ៕

*(មានបញ្ហាបច្ចេកទេស)*

*[សវនាការបានផ្អាកនៅម៉ោង១៦:០៤ នាទីរសៀល]*